ISSN 1560-7615 / ISBN 978-99950-52-06-5


# ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២៤ លេខ ២ | ខែមិថុនា ឆ្នាំ២០២០ | តម្លៃ ១.៥០០៛


30th ANNIVERSARY CDRI 1990 - 2020

# កត្តារាំងការសម្រេចអត្ថប្រយោជន៍បានដោយជោគជ័យនៃកម្មវិធីប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ករណីសិក្សានៃគម្រោងទឹកនិងអនាម័យនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

## សេចក្តីផ្តើម

ការប្រែប្រួលអាកាសធាតុ និងភាពក្រីក្រ នៅតែបន្តចោទបញ្ហាធំធេង និងជាបន្ទាន់ដល់ប្រទេសកំពុងអភិវឌ្ឍន៍នានា។ ថ្វីបើការបោះជំហានធំៗក្នុងប៉ុន្មានទសវត្សរ៍កន្លងមក បានលើកស្ទួយប្រជាជនជាច្រើនលាននាក់ ឲ្យចាកផុតពីភាពក្រីក្រក្តី ប៉ុន្តែបើសិនពុំមានសកម្មភាពរួមគ្នាដើម្បីសម្រាលការប្រែប្រួលអាកាសធាតុនោះទេ ជោគជ័យដែលសម្រេចបាន គឺអាចបាត់បង់ទៅវិញយ៉ាងលឿន។ ការប្រមើលឃើញនេះគួរឲ្យព្រួយបារម្ភណាស់។ ការប៉ាន់ស្មានមួយចំនួននាពេលថ្មីៗ បានអះអាងថា នៅឆ្នាំ២០៣០ ការប្រែប្រួលអាកាសធាតុ អាចញាំងប្រជាជនប្រមាណ ១០០លាននាក់ ឲ្យធ្លាក់ចូលវិញក្នុងភាពក្រីក្របំផុត ហើយគ្រោះមហន្តរាយផ្នែកធាតុអាកាស អាចបង្ខំឲ្យប្រជាជនប្រមាណ ២០០លាននាក់ ត្រូវចាកចេញពីកន្លែងរស់នៅសព្វថ្ងៃ (Khoday and Ali, 2018)។ ជាចម្លើយតប រដ្ឋាភិបាល អង្គការអភិវឌ្ឍន៍អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា កំពុងពន្លឿនកម្មវិធីធ្វើអន្តរាគមន៍ផ្សេងៗនៅតាមមូលដ្ឋាន ដើម្បីកាត់បន្ថយភាពក្រីក្រ និងកសាងសមត្ថភាពបន្សាំរបស់សហគមន៍ក្នុងមូលដ្ឋាន ឲ្យចេះរៀបចំជីវភាពអាចធន់ទ្រាំបានកាន់តែប្រសើរនឹងការប្រែប្រួលអាកាសធាតុ។



*សួនបន្លែតាមផ្ទះទទួលបានជោគជ័យ ក្នុងកម្មវិធីរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ធំ ខែតុលា ឆ្នាំ២០១៨*

នៅតាមប្រទេសកំពុងអភិវឌ្ឍន៍នានា មានកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុកាន់តែច្រើនឡើង ផ្តោតលើការកសាងភាពធន់របស់ ក្រុមងាយរងគ្រោះនៅតាមមូលដ្ឋានដែលមានជាអាទិ៍ ជនក្រីក្រ គ្រួសារមានស្ត្រីជាមេគ្រួ មនុស្សចាស់ ជនពិការ និងកុមារ។ ក្រុមងាយរងគ្រោះអាចពិបាកជួយ ឬឈោងដល់ណាស់ ទោះបីមានអន្តរាគមន៍ដែលគេបានធ្វើផែនការយ៉ាងល្អ និងអនុវត្តចំចំណុចក្តី។ របាំងចម្បងៗរារាំងការសម្រេចបានអត្ថប្រយោជន៍ដោយជោគជ័យ រួមមាន ប្រព័ន្ធស្រោចស្រពនិងរំដោះទឹកមិនគ្រប់គ្រាន់ ជំនាញនិងការអប់រំកម្រិតទាប ការមិនមានប្រភពទឹកប្រើប្រាស់ អសន្តិសុខស្បៀង កង្វះចំណាប់អារម្មណ៍និងការអប់រំពីការប្រែប្រួលអាកាសធាតុ ដែលនាំឲ្យខ្វះខាតភាពត្រៀមទប់ទល់នឹងគ្រោះមហន្តរាយ (ការរាំងស្ងួត ទឹកជំនន់) កង្វះបណ្តាញនិងការចែករំលែកព័ត៌មាន ការវិវត្តក្នុងកម្មសិទ្ធិដីធ្លីនិងភាពគ្មានដីធ្លី លទ្ធភាពមានតិច ឬគ្មានសោះ ដើម្បីទទួលបានធនធាន និងសេវាហិរញ្ញវត្ថុ (Nang and Ouch 2014; Nyahunda and Tirivangasi 2019)។

អត្ថបទនេះរៀបរៀងដោយ បណ្ឌិត លន់ ពេជ្រតារា អ្នកស្រាវជ្រាវ និងជានាយកមជ្ឈមណ្ឌល, នង មុនិន្ទ អ្នកស្រាវជ្រាវ, ឆាំង ម៉ារ៉ុង ជំនួយការស្រាវជ្រាវ, ឌួង ស៊ីវមុយ ជំនួយការស្រាវជ្រាវ, នៃមជ្ឈមណ្ឌលធនធានធម្មជាតិ និងបរិស្ថាន។
សូមយោងអត្ថបទនេះថា៖ Lonn Pichdara, Nong Monin, Chhaing Marong and Duong Sivmuy. 2020. "Factors Hindering Successful Benefits Realisation of Cambodia's Climate Change Program: Case Study of a Water and Sanitation Project, Kampong Svay District, Kampong Thom Province." *Cambodia Development Review* 24 (1): 1–6.

## មាតិកា


កត្តារាំងការសម្រេចអត្ថប្រយោជន៍បានដោយជោគជ័យ
នៃកម្មវិធីប្រែប្រួលអាកាសធាតុនៅកម្ពុជា ........................ ១
ការចុះកម្មសិក្សានៅក្រៅប្រទេស៖ ករណីសិក្សាពីនិស្សិតកូរ៉េនៅកម្ពុជា ........................ ៦
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ........................ ១០
– ស្ថានភាពក្នុងប្រទេស ........................ ១៣
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........................ ២៤

កម្ពុជា ស្ថិតក្នុងចំណោមប្រទេស ត្រូវប៉ះពាល់ខ្លាំងជាងគេដោយសារគ្រោះធម្មជាតិ និងតែងរងគ្រោះ សឹងតែជាលក្ខណៈរដូវកាលដោយទឹកជំនន់ ការរាំងស្ងួត និងខ្យល់ព្យុះ។ ភាពងាយរងគ្រោះនេះ កាន់តែធ្ងន់ធ្ងរឡើងដោយសារប្រជាជន ៧៧% ក្នុងនេះមានទាំងជនក្រីក្រភាគច្រើនផង កំពុងរស់នៅក្នុងតំបន់ជនបទ និងពឹងផ្អែកកម្រិតខ្ពស់លើ កសិកម្មស្រោចស្រពដោយទឹកភ្លៀង (ភាគច្រើនស្រូវ) ដើម្បីបានស្បៀងអាហារ និងប្រាក់ចំណូល (Yusuf and Francisco 2009; NIS 2019)។ ខេត្តកំពង់ធំដែលនៅជាប់បឹងទន្លេសាប ក្នុងតំបន់កណ្តាលប្រទេសកម្ពុជា ស្ថិតក្នុងចំណោមខេត្តក្រីក្រ និងតែងប៉ះពាល់ខ្លាំងជាងគេដោយទឹកជំនន់ និងការរាំងស្ងួត។ គ្រោះធម្មជាតិដែលកើតមានជារឿយៗទាំងនេះ តែងបង្កការខូតខាតធ្ងន់ធ្ងរ ជាពិសេសទៅលើប្រភពទឹក និងប្រព័ន្ធអនាម័យដែលមិនទាន់បានកែលំអ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទិន្នផលដំណាំ ផលិតកម្មសត្វចិញ្ចឹម ហើយអាចប៉ះពាល់ដល់ជីវិតមនុស្សទៀតផង (NCDM 2020)។

នៅខេត្តកំពង់ធំ ស្រុកកំពង់ស្វាយតែងងាយរងគ្រោះដោយការរាំងស្ងួត។ ជាចម្លើយតប ក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពី សម្ព័ន្ធកម្ពុជានៃការប្រែប្រួលអាកាសធាតុ (CCCA) និង អង្គការការីតាសកម្ពុជា បានអនុវត្តកម្មវិធីសាកល្បងមួយ (ដែលមានទាំងគម្រោងតូចៗជាច្រើនផង) នៅតាមឃុំតែងប៉ះពាល់ខ្លាំងជាងគេ ដើម្បីកែលំអប្រព័ន្ធផ្គត់ផ្គង់ទឹកនិងអនាម័យខ្នាតតូច និងសន្តិសុខស្បៀង នៅរដូវប្រាំង ហើយជាពិសេសដើម្បី ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធផ្អែកទឹក (អណ្តូង ប្រព័ន្ធប្រមូលនិងស្តុកទឹកភ្លៀង) និង កសាងបង្គន់អនាម័យ និងសួនបន្លែតាមផ្ទះ។

អត្ថបទនេះ ផ្អែកលើការសិក្សាបែបគុណវិស័យមួយដើម្បីវាយតម្លៃពីផលប៉ះពាល់ នៃបណ្តាកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា រួមទាំង កម្មវិធីសាកល្បងនៅស្រុកកំពង់ស្វាយ របស់ក្រសួងអភិវឌ្ឍន៍ជនបទផង (CDRI, MRD and UNDP 2019)។ អត្ថបទនេះរៀបរាប់ដោយសង្ខេបនូវ បទពិសោធន៍សំខាន់ៗដែលរៀនសូត្របាន និងធ្វើការពិភាក្សាពីកត្តាចម្បងៗដែលរារាំងជនក្រីក្រ និងជនងាយរងគ្រោះ បានទទួលផលពីកម្មវិធីជំនួយក្នុងការអនុវត្តតាមសកម្មភាពគាត់បានឃើញគេធ្វើបង្ហាញ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធធន់មាំល្អ (អណ្តូងជីក អណ្តូងខួង បង្គន់ សួនបន្លែតាមផ្ទះ) ក្រោយពេលកម្មវិធីអន្តរាគមន៍បានចប់អស់។ ការពិភាក្សាបញ្ចប់ដោយ ការផ្តល់មតិមួយចំនួន សម្រាប់កម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុនាពេលអនាគត។

## ប្រវត្តិកម្មវិធី

កម្មវិធីសាកល្បងផ្អែកហេដ្ឋារចនាសម្ព័ន្ធធន់ល្អនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានអនុវត្តឡើងក្នុង ៨ភូមិ នៅ ៨ឃុំ (យកមួយភូមិក្នុងមួយឃុំ) ក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ពីឆ្នាំ២០១៥ ដល់ ២០១៩ ដើម្បីកែលំអលទ្ធភាពមានពេញៗមួយឆ្នាំនូវទឹកស្អាត និងប្រព័ន្ធអនាម័យ និងជួយទ្រទ្រង់សមត្ថភាពប្រជាជនក្នុងមូលដ្ឋាន ក្នុងការធ្វើផែនការ និងកសាងជីវភាព អាចធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ។ កម្មវិធីនេះផ្តោតលើ គ្រួសារក្រីក្រ គ្រួសារមានស្ត្រីជាមេគ្រួ ជនចាស់ជរា គ្រួសារជាទូទៅ ហើយនិងមន្ត្រីរបស់ក្រសួងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (Khim and Chin 2016)។ កម្មវិធីមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់កំណត់អ្នកទទួលផល ដែលមាន ជនក្រីក្រ ជនចាស់ជរា ស្ត្រីជាមេគ្រួសារ ដែលធ្វើការនៅក្នុង ឬនៅជិតភូមិ (ពោលគឺ អ្នកមិនបានធ្វើចំណាកស្រុកដើម្បីទៅបម្រើការងារ) អ្នកមានកម្លាំងពលកម្មគ្រប់គ្រាន់ សម្រាប់ថែទាំសម្ភារបរិក្ខារ អ្នកពេញចិត្តធ្វើសួនបន្លែ និងពេញចិត្តចូលរួម និងបន្តអនុវត្ត ក្រោយពេលជំនួយទ្រទ្រង់ដោយផ្ទាល់បានចប់អស់ទៅ។

ហេដ្ឋារចនាសម្ព័ន្ធធន់នឹងការប្រែប្រួលអាកាសធាតុ ដែលមានផ្តល់ក្នុងកម្មវិធីនេះ មានសរុប ១១អណ្តូងជីក ៥អណ្តូងខួង ៨បង្គន់ និងប្រព័ន្ធប្រមូល/ស្តុកទឹកភ្លៀង និង ១៦សួនបន្លែតាមផ្ទះ។ បច្ចេកទេសខួង អាចផ្តល់នូវអណ្តូងមានជម្រៅជ្រៅជាង មានទឹកពេញៗមួយឆ្នាំ និងគ្មានការបំពុល (រូបភាព១ និង ២)។ បង្គន់ត្រូវបានកសាងនៅលើដីខ្ពស់មិនងាយលិចទឹក នៅក្នុងសាលារៀន និងកន្លែងធ្វើពិធីជាប្រពៃណីផ្សេងៗ ដែលអ្នកភូមិគ្រប់គ្នាអាច

រូបភាព១៖ អណ្តូងជីក



រូបភាព២៖ អណ្តូងខួងជម្រៅជ្រៅសម្រាប់ការផ្គត់ផ្គង់ទឹកពេញៗមួយឆ្នាំ



រូបភាព៣៖ បង្គន់និងប្រព័ន្ធប្រមូល/ស្តុកទឹកភ្លៀង សម្រាប់ឲ្យមានអនាម័យល្អ



រូបភាព៤៖ សួនបន្លែមានប្រព័ន្ធស្រោចស្រពតាមដំណក់ទឹក



ប្រើប្រាស់បាន (រូបភាព៣)។ សួនបន្លែបានធ្វើឡើងដោយមានប្រព័ន្ធស្រោចស្រពតាមដំណក់ទឹក (ដើម្បីប្រើទឹកអស់តិច និងងាយថែទាំ) សម្រាប់ការផលិតបន្លែនៅរដូវប្រាំង និងរដូវវស្សា (រូបភាព៤)។

## ការជ្រើសរើសកន្លែងសិក្សា និងការប្រមូលទិន្នន័យ

ភូមិបួន (ក្នុងចំណោមភូមិគោលដៅទាំង ៨ នៃគម្រោងស្រាវជ្រាវ) ក្នុងបួនឃុំ នៅស្រុកកំពង់ស្វាយ ត្រូវបានជ្រើសរើសសម្រាប់ការសិក្សា (រូបភាព៥) ក្នុងនេះ ភូមិបីស្ថិតនៅជិតស្ទឹងសែន (ងាយស្រួលក្នុងការយកទឹក និងធ្វើនេសាទ) ដែលហូរចាក់ទៅបឹងទន្លេសាប រីឯភូមិមួយទៀត ស្ថិតនៅឆ្ងាយពីប្រភពទឹក។ ស្រុកកំពង់ស្វាយទាំងមូល ងាយជួបការរាំងស្ងួត និងកង្វះទឹកធ្ងន់ធ្ងរ។

ទិន្នន័យប្រភពទី១ បានប្រមូលយកពី ១៣សម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ និងការពិភាក្សាតាមក្រុមស្នូល បីលើក (មួយលើកមានពី ៦ ទៅ ១០នាក់) ជាមួយអ្នកទទួលផលពីកម្មវិធី។ ទិន្នន័យប្រភពទី២ បានមកពីទិន្នន័យឃុំឆ្នាំ២០១៨ ជំរឿនឆ្នាំ២០១៩ និងមូលដ្ឋានទិន្នន័យជំរឿនឆ្នាំ២០០៨ (NIS 2018, 2019, 2010)។ អ្នកចូលរួមក្នុងការសិក្សា ត្រូវបានជ្រើសរើសដើម្បីតំណាងឲ្យអ្នកពាក់ព័ន្ធគ្រប់ប្រភេទ គឺមាន គ្រួសារក្រីក្រ គ្រួសារមានស្ត្រីជាមេគ្រួ កុមារ (អាយុក្រោម ១៥ឆ្នាំ) ជនចាស់ជរា (អាយុ ៦៥-៧០ឆ្នាំ) ជនពិការ គ្រួសារទូទៅ អាជ្ញាធរភូមិឃុំ និង បុគ្គលិកបច្ចេកទេសនៃក្រសួងអភិវឌ្ឍន៍ជនបទ។ ទិន្នន័យបានយកមកវិភាគ ដោយប្រើការវិភាគតាមប្រធានបទ។

រូបភាព៥៖ ផែនទីភូមិសិក្សា




ប្រភព៖ ការរៀបចំផែនទីដោយអ្នកនិពន្ធ ផ្អែកលើ NIS 2010

## ស្ថានភាពប្រជាសាស្ត្រនៅកន្លែងសិក្សា

ភូមិទាំងបួនមានប្រជាជនសរុប ៩៣៨គ្រួសារ ត្រូវជា ៤.៦៩៤នាក់ ក្នុងនេះមានពាក់កណ្តាលជាស្រី ៦៧% ស្ថិតក្នុងអាយុបម្រើការងារ (១៥-៦៥ឆ្នាំ) (តារាង១)។ ម៉្យាងទៀតមានប្រមាណ ៧៦% ចេះអក្សរ ៥១% បានបញ្ចប់បឋមសិក្សា និង ២១% បានបញ្ចប់មធ្យមសិក្សា (NIS 2018)។ គ្រួសារនានាមានសមាជិកជាមធ្យម បួននាក់ (NIS 2019)។

មុខរបរចម្បងរបស់អ្នកភូមិ គឺ ធ្វើស្រែ។ មានអ្នកភូមិតែមួយភាគតូច (១០%) ប៉ុណ្ណោះ ដែលអាចធ្វើស្រែបានពីរដងក្នុងមួយឆ្នាំ ព្រោះដីស្រែគាត់ ឬមួយមានការស្រោចស្រព ឬមួយស្ថិតនៅជិតប្រឡាយរំដោះទឹក។ ការចិញ្ចឹម មាន់ ជ្រូក គោ ជាប្រភពចំណូលទី២ និងផ្តល់សាច់ហូប។ ម៉្យាងទៀត តាមធម្មតាអ្នកភូមិមានដាំបន្លែ និងដើមឈើយកផ្លែ ដូចជា ខ្ទឹម ត្រកួន ចេក ល្ហុង ខ្នុរ ស្វាយ នៅជុំវិញផ្ទះ។ នៅភូមិដំរីស្លាប់ មានប្រមាណ ៣០គ្រួសារ បានធ្វើចំណាកស្រុកទៅធ្វើការនៅថៃពេញមួយឆ្នាំ បើតាមសំដីប្រធានភូមិ។ អ្នកភូមិក៏ពឹងផ្អែកលើការនេសាទ ដើម្បី

តារាង១៖ ភូមិសិក្សានៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

| ឃុំ | ភូមិ | គ្រួសារសរុប | ប្រុសសរុប | ស្រីសរុប |
|---|---|---|---|---|
| កំពង់គោ | បូពឹង | 192 | 449 | 468 |
| ដំរីស្លាប់ | ដំរីស្លាប់ | 181 | 391 | 394 |
| ត្រពាំងឫស្សី | ល្វាជោម | 230 | 640 | 565 |
| ក្ដីដូង | ពាមគ្រែង | 335 | 873 | 914 |
| **សរុប** | | **938** | **2,353** | **2,341** |

ប្រភព៖ (NIS, 2018)

ទ្រទ្រង់ សន្តិសុខស្បៀងក្នុងគ្រួសារដែរ។ អ្នកភូមិមិនមានការតភ្ជាប់នឹងបណ្ដាញផ្គត់ផ្គង់អគ្គិសនីទេ។ អាគុយរថយន្ត (៦៦%) និងផ្ទាំងសូឡា ជាប្រភពទូទៅនៃថាមពលសម្រាប់បំភ្លឺ ហើយគេប្រើអុសជាទូទៅ សម្រាប់ចម្អិនអាហារ (NIS 2018)។ គ្រួសារប្រមាណ ៥០% មានបង្គន់តាមផ្ទះ។

## លទ្ធផលរកឃើញ៖ កត្តាសំខាន់ៗរារាំងការសម្រេចបានអត្ថប្រយោជន៍

អ្នកចូលរួមក្នុងការសិក្សា បានបញ្ជាក់ពីការពេញចិត្តលើកម្មវិធីសាកល្បង ហើយសំណូមពរឲ្យពង្រីកវាទៅគ្រប់ភូមិនៅក្នុងខេត្ត។ សួនបន្លែតាមផ្ទះបានទទួលអត្ថប្រយោជន៍ពីស្ត្រីនិងកុមារ ពីព្រោះអ្នកទាំងនេះមានពេលច្រើននៅផ្ទះ ហើយអាចថែទាំសួន។ ប៉ុន្តែការសិក្សាបានរកឃើញ កត្តារារាំងបួនដែលប៉ះពាល់ដល់ការចូលរួមរបស់អ្នកទទួលផល៖ ធាតុអាកាសក្ដៅពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ រចនាសម្ព័ន្ធ/សមត្ថភាពគ្រួសារ (ការផ្គត់ផ្គង់ពលកម្ម និងហិរញ្ញវត្ថុក្នុងគ្រួសារ) ការជួសជុលសម្ភារបរិក្ខារខូច ឬមានបញ្ហា (ពឹងផ្អែកលើជំនួយបច្ចេកទេសពីរដ្ឋាភិបាល) និងយុទ្ធសាស្ត្រចិញ្ចឹមជីវិត និងអាទិភាពរបស់គ្រួសារក្រីក្រ។ កត្តាទាំងនេះមានលំអិតនៅខាងក្រោម៖

### *សីតុណ្ហភាពក្ដៅពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ*

ការថែទាំសួនបន្លែតាមផ្ទះ បានជួបបញ្ហាប្រឈមដោយសារធាតុអាកាសក្ដៅខ្លាំងណាស់ យោងតាមសំដីមន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តម្នាក់។ នៅពេលមានរលកកំដៅនៅខែឧសភា ២០១៩ សីតុណ្ហភាពឡើងដល់ ៤២អង្សាសេ ធៀបនឹង សីតុណ្ហភាពប្រចាំខែមធ្យមត្រឹម ៣០អង្សាសេ និងឡើងដល់ ៣៤អង្សាសេម្ដងម្កាល។ ទឹកសឹងតែខ្វះខាតជានិច្ចនៅរដូវប្រាំង ពីព្រោះអណ្ដូងភាគច្រើន រាប់ទាំងអណ្ដូងជ្រៅៗផង រីងទឹកអស់។ អ្នកភូមិរាយការណ៍ថា រដូវភ្លៀងមកដល់កាន់តែយឺតយ៉ាវ ហើយខែមិថុនា និងកក្កដា ដែលពីដើមរៀងមកជាខែភ្លៀង ឥឡូវនេះនៅរាំងស្ងួតទាំងស្រុង។ ប្រធានភូមិម្នាក់និយាយថា៖

> គម្រោងអភិវឌ្ឍន៍របស់ក្រសួងអភិវឌ្ឍន៍ជនបទ បានជួយកែលំអស្ថានភាពអនាម័យ។ ប៉ុន្តែអណ្ដូងថ្មីៗដោះស្រាយកង្វះទឹកបានតែមួយភាគប៉ុណ្ណោះ ពីព្រោះគម្រោងបានផ្ដល់តែ ៨អណ្ដូង ហើយអ្នកភូមិកសាងបានតែ ១៣អណ្ដូងទៀត។ ដើម្បីដោះស្រាយបញ្ហានេះ ប្រជាជនទិញទឹកពីអ្នកផ្គត់ផ្គង់ឯកជនក្នុងថ្លៃ ១៣.០០០រៀល សម្រាប់ទឹកមួយធុងចំណុះ ៥.០០០លីត្រ។ អ្នកភូមិសឹង ១០០% ប្រើអណ្ដូង [ជាប្រភពទឹកចម្បង]។

> តាមសំដីបុគ្គលិកក្រសួងអភិវឌ្ឍន៍ជនបទ៖
> ការជីក និងស្ដារជួសជុលស្រះទឹកឲ្យបានច្រើនទៀត អាចជួយស្តុកទឹកបានកាន់តែច្រើន សម្រាប់ការប្រើប្រាស់ក្នុងឃុំនៅរដូវប្រាំង។

### *រចនាសម្ព័ន្ធ/សមត្ថភាពគ្រួសារ (មានកម្លាំងពលកម្ម និងលទ្ធភាពរកបានហិរញ្ញវត្ថុ)*

គម្រោងសាកល្បង ដែលផ្ដល់សួនបន្លែតាមផ្ទះឲ្យគ្រួសារក្រីក្រ និងគ្រួសារជនចាស់ជរា គឺមានជោគជ័យកម្រិតទាបត្រឹម ៣០% ទៅ ៤០% ពីព្រោះការថែទាំសួនបន្លែតាមផ្ទះ (ថែទាំកូនបន្លែ ស្រោចទឹក ដកស្មៅ បំពេញធុងទឹក ធ្វើជីកំប៉ុស្ត ...) មានការងារហត្ថកម្មច្រើនគួរសម ដូច្នេះត្រូវមានកម្លាំងកាយក្នុងកម្រិតណាមួយ។ ដោយមូលហេតុនេះ គ្រួសារមានជនពិការ និង/ឬ ជនចាស់ជរា ឬគ្រួសារពុំមានកម្លាំងពលកម្មគ្រប់គ្រាន់ អាចជួបបញ្ហាប្រឈមក្នុងការគ្រប់គ្រងសួនបន្លែតាមផ្ទះ។

> តាមសំដីស្ត្រីម្ចាស់ផ្ទះម្នាក់នៅភូមិជំរីស្លាប់៖
> ខ្ញុំទទួលបានសួនបន្លែតាមផ្ទះមួយ ពីគម្រោងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ហើយខ្ញុំជួបបញ្ហាប្រឈមមួយចំនួន។ ទី១ ទាំងប្ដីខ្ញុំនិងរូបខ្ញុំ គឺកាន់តែចាស់ ហើយមិនមានកម្លាំងគ្រប់គ្រាន់សម្រាប់ដាំបន្លែទេ តាំងពីមុនពេលគម្រោងបានចាប់ផ្ដើមម្លេះ។ ដាំបន្លែ ជាការងារនឿយហត់គួរសម។ យើងខ្ញុំ បានដាំបន្លែក្នុងសួនតាមផ្ទះនេះពីរលើកមកហើយ ប៉ុន្តែគួរឲ្យស្ដាយដំណាំទាំងអស់បានខូចខាត ហើយយើងខ្ញុំមិនដឹងថា វាយ៉ាងម៉េច និងមកពីហេតុអ្វីទេ ទោះបីបានធ្វើតាម ការណែនាំក្នុងពេលបណ្ដុះបណ្ដាលនោះហើយក្ដី។ នៅពេលបុគ្គលិកគម្រោងចុះមកមើល ខ្ញុំបានប្រាប់គាត់តាមការពិត និងសុំឲ្យគាត់យកសួនតាមផ្ទះនេះទៅឲ្យគ្រួសារផ្សេងដែលមានកម្លាំងដាំបន្លែវិញ។

ប្រព័ន្ធស្រោចស្រពប្រើដំណក់ទឹក សម្រាប់ស្រោចសួនបន្លែតាមផ្ទះក្នុងគម្រោងសាកល្បងនេះ វាមានតម្លៃខ្ពស់ដែលអាចជាបញ្ហាប្រឈមសម្រាប់សហគមន៍ ដើម្បីកសាងវានៅតាមភូមិផ្សេងៗទៀត។ ប៉ុន្តែបុគ្គលិកក្រសួងអភិវឌ្ឍន៍ជនបទបានផ្ដល់មតិថា អ្នកភូមិអាចប្រើធនធានក្នុងមូលដ្ឋាន ដូចជា បង្គោលឈើជាដើម ជាជាងទៅទិញសម្ភារបរិក្ខារថ្លៃៗ។

### *ជំនួយបច្ចេកទេសពីរដ្ឋាភិបាល*

ប្រជាជនភាគច្រើនដែលរស់នៅក្នុងគ្រួសារក្រីក្រ តែងមានកម្រិតអប់រំទាប មានជំនាញធ្វើការកម្រិតទាប ឬគ្មានសោះ និងត្រូវការជំនួយហិរញ្ញវត្ថុ។ នៅកម្រិតទាបបំផុត គ្រួសារក្រីក្រជាងគេត្រូវការជាប់រហូត និងដោយផ្ទាល់ នូវជំនួយកម្រិតគ្រួសារ ដើម្បីកែលំអស្ថានភាពខ្លួន។ អ្នកភូមិខ្លះមានតម្រូវការច្បាស់ទែងនូវសមត្ថភាព ជួសជុលអណ្ដូងខូច គ្រប់គ្រងសួនបន្លែតាមផ្ទះ និងធ្វើផែនការថវិកាសម្រាប់ទិញគ្រឿងបន្លាស់។ ទោះបីមានការបង្កើតគណៈកម្មាធិការភូមិ (ឃុំមួយមានគណៈកម្មាធិការនេះមួយ) ដើម្បីថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធក្ដី ក៏ការថែទាំបានជួបឧបសគ្គដោយសារកង្វះខាតចំណេះធ្វើ និងបន្ទុកចំណាយជាប់ទាក់ទិន។

យោងតាម ការពិភាក្សាតាមក្រុមស្នូល ជាមួយសមាជិកក្រុមប្រឹក្សាឃុំ នៅឃុំសាន់គរ៖

អណ្ដូងនៅឆ្ងាយពីផ្ទះ។ អ្នកភូមិខ្លះប្រើវា ប៉ុន្តែមិនព្រមថែទាំវាទេ។ "ការលំបាកក្នុងគម្រោង រួមមាន អណ្ដូងខូចគ្មានគ្រឿងបន្លាស់ និងគ្មានអ្នកណាអាចជួសជុលវាបាន" យោងតាមសំដីមេឃុំនៅឃុំសាន់គ។

ការថែទាំ អណ្ដូង បង្គន់ ប្រព័ន្ធប្រមូលនិងស្ដុកទឹក និង សួនបន្លែតាមផ្ទះ គឺជាបញ្ហាប្រឈមចម្បង ហើយសកម្មភាពថែទាំទាំងនេះត្រូវមានសហប្រតិបត្តិការពី អ្នកទទួលផល អ្នកប្រើប្រាស់ឯទៀតៗ និងអាជ្ញាធរក្នុងមូលដ្ឋាន។

## *យុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់គ្រួសារក្រីក្រ និងក្រីក្រខ្លាំង (អាទិភាពខុសៗគ្នា)*

គ្រួសារក្រីក្រតាមធម្មតាផ្ដល់អាទិភាពដល់ ប្រាក់ចំណូលបានពីការងារមានប្រាក់ឈ្នួល។ គ្រួសារខ្លះបានចាកចេញពីភូមិខ្លួនទៅរកការងារនៅកន្លែងផ្សេង ដែលផ្ទុយពីលក្ខណៈវិនិច្ឆ័យ "ត្រូវធ្វើការនៅក្នុង ឬនៅជិតភូមិ" សម្រាប់ជ្រើសរើសអ្នកទទួលផលដែលសាកសមនឹងកម្មវិធី។ គ្រួសារខ្លះទៀតបានបាត់បង់ការប្ដេជ្ញាចិត្ត ហើយបានផ្ដល់អាទិភាពដល់ប្រាក់កម្រៃប្រចាំថ្ងៃដោយបម្រើការជាអ្នកស៊ីឈ្នួលធ្វើស្រែវិញ។ សួនបន្លែតាមផ្ទះពិតជាដំណើរការមិនបានល្អទេ សម្រាប់គ្រួសារក្រីក្រ។ ផ្ទុយទៅវិញ គ្រួសារមធ្យម និងគ្រួសារធូរធារ មានកម្លាំងពលកម្មច្រើនជាង និងប្រភពចំណូលច្រើនមុខជាង ដូច្នេះគាត់មានមធ្យោបាយបង្កើត និងគ្រប់គ្រងសួនបន្លែតាមផ្ទះបានជោគជ័យ។

យោងតាមមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទម្នាក់៖

> មានហេតុផលជាច្រើនបង្ហាញថា ហេតុអ្វីបានជាអ្នកភូមិ[ខ្លះ]បានបរាជ័យក្នុងការធ្វើសួនបន្លែតាមផ្ទះ។ ពួកគាត់គិតថា សួនបន្លែតាមផ្ទះជាប្រភពចំណូលទី២ ឬទី៣ គឺមិនមែនជាប្រភពចម្បងទេ។ ពួកគាត់មានជម្រើសផ្សេងទៀត ដើម្បីបានប្រាក់ចំណូលខ្ពស់ជាងនេះច្រើនណាស់ គឺពី ការងារបានប្រាក់ឈ្នួល ការងារក្នុងរោងចក្រកាត់ដេរនៅទីក្រុង ឬការងារនៅក្នុងព្រៃ។ ដូច្នេះគាត់គ្មានការចាំបាច់អ្វី នឹងថែទាំសួនបន្លែតាមផ្ទះនោះទេ ព្រោះគាត់អាចរស់បានដោយគ្មានវា។

> យោងតាមអភិបាលស្រុកកំពង់ស្វាយ៖
> "អាទិភាពខ្ពស់បំផុតសម្រាប់សហគមន៍នានាក្នុងស្រុកនេះ គឺស្ដារជួសជុលផ្លូវតាមដងប្រឡាយ៣០កញ្ញា ពីព្រោះវាជាផ្លូវចម្បង សម្រាប់ដឹកជញ្ជូនស្រូវអង្ករទៅទីផ្សារ ហើយវាផ្ដល់អត្ថប្រយោជន៍ដល់ស្រុកទាំងមូលផង"

## សេចក្ដីសន្និដ្ឋាន

អ្នកទទួលផល ពីកម្មវិធីអន្តរាគមន៍លើការប្រែប្រួលអាកាសធាតុនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានបញ្ជាក់ប្រាប់ពីការគាំទ្ររបស់គាត់ដល់កម្មវិធី ហើយបានសំណូមពរថា ការផ្ដល់ អណ្ដូង បង្គន់ សួនបន្លែតាមផ្ទះ និង ប្រព័ន្ធប្រមូលនិងស្ដុកទឹកភ្លៀង គួរពង្រីកបន្ថែមក្នុងខេត្តទាំងមូល។ ប៉ុន្តែទិដ្ឋភាពខ្លះនៃកម្មវិធីដំណើរការមិនបានល្អដូចការគិតទុកទេ ព្រោះអត្ថប្រយោជន៍ដែលគេចង់បានគេមិនអាចសម្រេចវាបានពេញលេញ។ ការសិក្សានេះរកឃើញថា មានកត្តាបួនដែលរារាំងលទ្ធភាពរបស់គ្រួសារក្រីក្រ ដើម្បីទទួលបានអត្ថប្រយោជន៍ពេញលេញពីកម្មវិធីអន្តរាគមន៍ ពោលគឺ កង្វះកម្លាំងពលកម្មក្នុងគ្រួសារជនចាស់ជរា កំដៅខ្លាំងពេក អាទិភាពខុសគ្នា/ការបាត់បង់ការប្ដេជ្ញាចិត្ត ក្នុងចំណោមគ្រួសារក្រីក្រ និងកង្វះចំណេះធ្វើផ្នែកបច្ចេកទេសនិងជំនួយគាំទ្រជាហិរញ្ញវត្ថុ។

លទ្ធផលរកឃើញបង្ហាញថា អន្តរាគមន៍ផ្សេងៗទៅអនាគតដើម្បីកសាងសមត្ថភាពបន្សាំរបស់ ប្រជាជនរស់នៅក្នុងភាពក្រីក្រ និងក្រុមងាយរងគ្រោះផ្សេងទៀត ឲ្យចេះកសាងយុទ្ធសាស្ត្រចិញ្ចឹមជីវិតធន់នឹងការប្រែប្រួលអាកាសធាតុ គឺគួរពិចារណាលើចំណុចដូចតទៅ៖

១. ហេដ្ឋារចនាសម្ព័ន្ធធន់នឹងការប្រែប្រួលអាកាសធាតុ៖ ការបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ នៃផ្លូវនានាដែលជួយឲ្យប្រជាជនក្នុងមូលដ្ឋាន អាចទៅដល់កន្លែងគាត់ចង់ទៅ និងការបង្កើនលទ្ធភាពមានប្រភពទឹកកាន់តែប្រសើរ គឺជាធាតុផ្សំគន្លឹះពីរ។ ការជីកស្រះឲ្យបានច្រើនថែមទៀតសម្រាប់ស្ដុកទឹកទុកប្រើនៅរដូវប្រាំង ក៏ជាអាទិភាពមួយដែរ ពីព្រោះអណ្ដូងភាគច្រើនត្រូវរីងស្ងួតអស់។ ការស្ដារជួសជុលផ្លូវតាមដងប្រឡាយ៣០កញ្ញា នៅស្រុកកំពង់ស្វាយ នឹងជួយបង្កើនស្ថិរភាពក្នុងជីវភាពរស់នៅ ពីព្រោះវាជាផ្លូវចម្បងសម្រាប់ដឹកជញ្ជូនស្រូវអង្ករទៅទីផ្សារ។

២. ជម្រើសចិញ្ចឹមជីវិតមានច្រើនមុខ៖ ដោយសារគ្រួសារក្រីក្រផ្ដល់អាទិភាពខ្ពស់ដល់ការងារមានប្រាក់ឈ្នួល រួមទាំងការធ្វើចំណាកស្រុកទៅរកការងារធ្វើផង អន្តរាគមន៍បន្សាំនឹងការប្រែប្រួលអាកាសធាតុផ្សេងៗ គួរមានជួយបង្កើតជម្រើសច្រើននូវការងារផ្ដល់ប្រាក់ឈ្នួលមានចីរភាព សម្រាប់គ្រួសារក្រីក្រនៅក្នុងសហគមន៍។

៣. ការបណ្ដុះបណ្ដាលពីការថែទាំសម្ភារបរិក្ខារ៖ ប្រជាជនក្នុងមូលដ្ឋាន ដែលទទួលផលពីគម្រោង និងគណៈកម្មការថែទាំ គួរនៅតែទទួលបានការបណ្ដុះបណ្ដាល ពីរបៀបថែទាំជួសជុលសម្ភារបរិក្ខារ និងសំណង់ផ្សេងៗ ដែលគម្រោងបានផ្ដល់ឲ្យ មានជាអាទិ៍ អណ្ដូង/ម៉ាស៊ីនបូមទឹក សួនបន្លែតាមផ្ទះ ប្រព័ន្ធប្រមូលនិងស្ដុកទឹកភ្លៀង។ វិធីនេះអាចជួយកាត់បន្ថយការពឹងផ្អែកលើជំនួយបច្ចេកទេស ពីក្រសួងអភិវឌ្ឍន៍ជនបទ និងជួយឲ្យឃុំកាន់តែមានភាពឯករាជ្យក្នុងពេលអនុវត្តគម្រោង។ ការធ្វើផែនការថវិកាសម្រាប់ទិញគ្រឿងបន្លាស់ ដោយមានជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសហគមន៍ផង គួរតែអនុវត្តឲ្យបាន។

## ឯកសារយោង

Anshory Yusuf, A., & Francisco, H. (2009). *Climate Change Vulnerability Mapping for Southeast Asia.* Economy and Environment Program for Southeast Asia (EEPSEA). Singapore. http://www.eepsea.org

CDRI, MRD, UNDP (2019). *Impact of Climate Change Programs in Cambodia: Vulnerability, Poverty, and*

*តទៅទំព័រ ១៨*

# ការចុះកម្មសិក្សានៅក្រៅប្រទេស៖ ករណីសិក្សាពីនិស្សិតកូរ៉េនៅកម្ពុជា

## សេចក្តីផ្តើម

តាំងពីដើមរៀងមក ចល័តភាពរបស់និស្សិតអន្តរជាតិជាលក្ខណៈគោលមួយ នៃអន្តរជាតូបនីយកម្មឧត្តមសិក្សា។ តាំងពីទសវត្សរ៍ទី៨០ មកចំនួននិស្សិតអន្តរជាតិចុះឈ្មោះចូលរៀនធៀបនឹង ចំនួននិស្សិតថ្នាក់ឧត្តមសិក្សាចុះឈ្មោះចូលរៀនសរុបទូទាំងសកលលោក មាននៅក្នុងចន្លោះពី ពីរទៅបីភាគរយ។ ក្នុងនោះ ចំនួននិស្សិតថ្នាក់ឧត្តមសិក្សាអន្តរជាតិ បានកើនមួយជាប្រាំពី ០,៨លាននាក់ នៅឆ្នាំ១៩៨០ ដល់ជាង ៥លាននាក់នៅឆ្នាំ២០១៨ ហើយគេរំពឹងថា ចំនួននេះនឹងឡើងដល់ ៨លាននាក់ នៅឆ្នាំ២០២៥ (OECD, 2017; Dennis, 2018)។ ទិន្នន័យផ្លូវការចុងក្រោយរបស់ វិទ្យាស្ថានអប់រំអន្តរជាតិ (IIE, 2019) បានបង្ហាញថា ប្រទេសគោលដៅចម្បងៗរបស់និស្សិតអន្តរជាតិ សុទ្ធតែជាប្រទេសអភិវឌ្ឍន៍ លើកលែងតែប្រទេសចិនដែលទើបឡើងដល់លំដាប់ទី៣ នៅក្នុងតារាង (រូបភាព១)។

សព្វថ្ងៃនេះ ព័ត៌មានអំពីចល័តភាពរបស់និស្សិតអន្តរជាតិចេញពីប្រទេសអភិវឌ្ឍន៍ ទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ឬរវាងប្រទេសកំពុងអភិវឌ្ឍន៍ នៅមានតិចតួចណាស់ ទោះបីជានិន្នាការនេះកើតមានជាយូរណាស់មកហើយ និងទទួលបានការយកចិត្តទុកដាក់ពីសំណាក់សាធារណជន និងអ្នកស្រាវជ្រាវនាពេលថ្មីៗនេះ។ ទោះជាយ៉ាងនេះក្តី ចំណុចផ្តោតនៃប្រធានបទនេះគឺ ចល័តភាពចេញពីប្រទេសមិនសូវអភិវឌ្ឍន៍ ទៅកាន់ប្រទេសជឿនលឿនផ្នែកសេដ្ឋកិច្ច ដែលមានប្រព័ន្ធឧត្តមសិក្សាល្អប្រសើរ (Knight 2014; Jiani 2016)។ រីឯការពិភាក្សាលើនិន្នាការបញ្ច្រាសនៃនិស្សិតចេញពីប្រទេសជឿនលឿន ដែលមានប្រព័ន្ធឧត្តមសិក្សាខ្លាំង ទៅកាន់ប្រទេសមិនសូវអភិវឌ្ឍន៍ ស្ថិតនៅក្នុងកម្រិតបន្ទាប់បន្សំនៅឡើយ។

ក្នុងពេលកន្លងមក ចំណុចផ្តោតសំខាន់គឺ ចល័តភាពដើម្បីយកសញ្ញាប័ត្រអន្តរជាតិ ហើយការពិភាក្សាពីចល័តភាពមិនដើម្បីយកសញ្ញាប័ត្រ ដូចជា កម្មវិធីចុះកម្មសិក្សា គម្រោងទស្សនកិច្ច និងគម្រោងផ្លាស់ប្តូរបទពិសោធន៍ នៅមានតិចតួចណាស់។ ដើម្បីចូលរួមចំណែកដល់ការជជែកវែកញែក ឲ្យកាន់តែផុសផុលលើប្រធានបទនេះ អត្ថបទនេះពិនិត្យពីបទពិសោធន៍ចុះកម្មសិក្សារបស់និស្សិតកូរ៉េខាងត្បូង នៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដោយចាប់ផ្តើមពីក្របខ័ណ្ឌសិក្សា និងវិធីសាស្ត្រស្រាវជ្រាវ ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ និងបញ្ចប់ដោយការផ្តល់មតិ សម្រាប់ការធ្វើគោលនយោបាយ និងការអនុវត្តជាក់ស្តែង និងទិសដៅស្រាវជ្រាវទៅអនាគតលើប្រធានបទការចុះកម្មសិក្សារបស់និស្សិតអន្តរជាតិ។

## ក្របខ័ណ្ឌសិក្សា

មធ្យោបាយមួយ ដើម្បីពិនិត្យពីបទពិសោធន៍ចុះកម្មសិក្សានៅក្រៅប្រទេស គឺ ការប្រើក្របខ័ណ្ឌការពេញចិត្តការងាររបស់និយោជិត។ ជាឧទាហរណ៍ ការសិក្សាបែបបរិមាណវិស័យរបស់ Rothman (2003) លើបទពិសោធន៍ចុះកម្មសិក្សារបស់និស្សិតសាលាពាណិជ្ជកម្ម បានរកឃើញកត្តាបីដែលជះឥទ្ធិពលលើការពេញចិត្តរបស់និស្សិត៖ ទិដ្ឋភាពការងារ របៀបរៀបចំអង្គភាព និងទំនាក់ទំនងអន្តរបុគ្គល។ ដោយផ្អែកលើម៉ូដែលនេះ D'Abate, Youndt and Wenzel (2009) បានបង្កើតម៉ូដែលមួយទៀតដែលមានលក្ខណៈពេញលេញជាងមុន ដើម្បីធ្វើការវាយតម្លៃដោយផ្អែកលើភស្តុតាង ទៅលើកម្មវិធីចុះកម្មសិក្សានានា ក្នុងនោះមានដូចជា លក្ខណៈសំគាល់ការងារ បរិយាកាសការងារ និងកត្តាបរិបទដទៃទៀត។ លក្ខណៈសំគាល់ការងារទាំងនោះ រួមមានភាពចម្រុះនៃជំនាញ ការស្គាល់និងការយល់ដឹងពីសារៈសំខាន់នៃកិច្ចការនីមួយៗ ស្វ័យភាព និងការផ្តល់មតិយោបល់ក្នុងន័យស្ថាបនា។ លក្ខណៈសំគាល់នៃបរិយាកាសការងារ រួមមានឱកាសរៀនសូត្រ ការគាំទ្រពីអ្នកត្រួតពិនិត្យ ឱកាសអភិវឌ្ឍអាជីព ការគាំទ្រពីមិត្តរួមការងារ និងការពេញចិត្តលើរបៀបរៀបចំអង្គភាព។ ទិដ្ឋភាពបរិបទដែលត្រូវបានយកមកពិចារណា រួមមាន របៀបធ្វើការដែលមានភាពបត់បែន ការធ្វើដំណើរនិងចម្ងាយទៅកន្លែងធ្វើការដែលមានកម្រិតសមរម្យ ប្រាក់ឧបត្ថម្ភនិងការពេញចិត្ត និងទីតាំងកន្លែងធ្វើការ។

ក៏ប៉ុន្តែការសិក្សារបស់ D'Abate et al. (2009) នៅមិនទាន់បានពិនិត្យលើកត្តាផ្សេងៗមួយចំនួនទៀត ជាពិសេសកត្តាបុគ្គល និងជំនួយគាំទ្រពីសាកលវិទ្យាល័យ។ Heng et al. (2011) បានរកឃើញកត្តាបុគ្គលចំនួនបី ដែលជាចំណុចសំខាន់ជំរុញឲ្យកម្មវិធីចុះកម្មសិក្សាមានប្រសិទ្ធភាព ពោលគឺ ការត្រៀមលក្ខណៈផ្នែកសិក្សា ឥរិយាបថវិជ្ជមាន និង គំនិតផ្តួចផ្តើមដោយខ្លួនឯង។ ពួកគេក៏បានផ្តោតលើជំនួយគាំទ្រពីសាកលវិទ្យាល័យ ក្នុងនោះមានកិច្ចសហការ រវាងសាកលវិទ្យាល័យនឹងស្ថាប័នខាងក្រៅ និង

រូបភាព១៖ ប្រទេសគោលដៅចម្បងៗរបស់និស្សិតអន្តរជាតិ នៅឆ្នាំ២០១៨




ប្រភព៖ គម្រោង Atlas (IIE, 2019)

---

អត្ថបទនេះរៀបរៀងដោយ Kang SoHyeon and Song Dabin ជាអ្នកហាត់ការនៃមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ នៃវិទ្យាស្ថាន CDRI និង បណ្ឌិត ឡេង ភីរម្យ ជានាយកនៃវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ។ សូមយោងអត្ថបទនេះថា៖ Citation: Kang SoHyeon, Song Dabin and Leng Phirom. 2020. "International Internship in Cambodia: A Case Study of Korean Students." *Cambodia Development Review* 24 (2): 7-11។

តារាង១៖ កត្តាជះឥទ្ធិពលដល់ការពេញចិត្តលើកម្មវិធី ចុះកម្មសិក្សានៅវិទ្យាស្ថាន CDRI

| កត្តា | ឧទាហរណ៍ |
|---|---|
| លក្ខណៈសំគាល់បុគ្គល | ការត្រៀមលក្ខណៈផ្នែកសិក្សា ឥរិយាបថវិជ្ជមាន និង គំនិតផ្តួចផ្តើមដោយខ្លួនឯង |
| លក្ខណៈសំគាល់ការងារ | ភាពចម្រុះនៃជំនាញ ការស្គាល់ពីកិច្ចការ ការយល់ដឹងពីសារៈសំខាន់នៃកិច្ចការនីមួយៗ ស្វ័យភាព ការផ្តល់មតិយោបល់ និង ភាពច្បាស់លាស់នៃកិច្ចការ |
| បរិយាកាសអង្គភាព | អ្នកត្រួតពិនិត្យ មិត្តរួមការងារ ឱកាសរៀនសូត្រ កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈ ជំនួយគាំទ្រផ្នែករដ្ឋបាល របៀបធ្វើការដែលមានភាពបត់បែន និង ការពេញចិត្តនឹងប្រាក់ឧបត្ថម្ភ |
| បរិបទ | ការធ្វើដំណើរ សុវត្ថិភាព វប្បធម៌ក្នុងស្រុក និង ឥរិយាបថប្រជាជនក្នុងស្រុកចំពោះជនបរទេស |

ប្រភព៖ D'Abate, Youndt and Wenzel (2009); Heng et al. (2011)

ការចាត់តាំងអ្នកត្រួតពិនិត្យដោយសាកលវិទ្យាល័យ សម្រាប់ជួយផ្តល់ការណែនាំលើការសិក្សារៀនសូត្រ និងផ្តល់ជំនួយគាំទ្រម្នាក់ទល់ម្នាក់ដល់អ្នកសិក្សាពីចម្ងាយ នៅពេលមានហេតុការណ៍បន្ទាន់ ឬមានបញ្ហាណាមួយកើតឡើង (Fagan and Wise, 2007)។ លើសពីនេះទៀត Heng et al. (2011) បានពង្រីកពាក្យ "លក្ខណៈសំគាល់នៃបរិយាកាសការងារ" ឲ្យទៅជា "បរិយាកាសនៃអង្គភាពការងារ" ដែលរួមបញ្ចូលទាំង អ្នកត្រួតពិនិត្យ មិត្តរួមការងារ ភាពច្បាស់លាស់នៃកិច្ចការ និង ឱកាសរៀននិងអភិវឌ្ឍខ្លួន។

សំណួរបន្ទាប់ទៀត គឺថា តើការជួយណែនាំជាប្រចាំ (mentorship) មានផលប៉ះពាល់អ្វីខ្លះដល់អ្នកហាត់ការអន្តរជាតិ? Feldman, Folks and Turnley (1999) បានបង្ហាញលទ្ធផលបីប្រភេទ ដោយផ្អែកលើការសិក្សាមុនៗ។ ទី១ ការជួយណែនាំជាប្រចាំ អាចនាំឲ្យទំនាក់ទំនងសង្គមនៅក្នុងអង្គភាពរបស់បុគ្គលិកថ្មី ឬអ្នកហាត់ការ មានភាពប្រសើរឡើង (Louis, Posner and Powell, 1983)។ ធាតុសំខាន់ពីរនៃដំណើរការនេះគឺ ការណែនាំឲ្យស្គាល់ពីកិច្ចការ ដែលអាចឈានដល់ការបំពេញកិច្ចការបានយ៉ាងស្ទាត់ជំនាញ និង ការណែនាំឲ្យស្គាល់ក្រុមការងារ ឬការរាប់បញ្ចូលទៅក្នុងក្រុម។ ទី២ ការជួយណែនាំជាប្រចាំទៅដល់អ្នកហាត់ការ លើកិច្ចការកំណត់ឲ្យធ្វើនៅបរទេស អាចនាំឲ្យពួកគេរៀនបានកាន់តែច្រើន អំពីជីវិតជាជនបរទេស និងយល់ដឹងកាន់តែស៊ីជម្រៅពីឱកាស និងបញ្ហាប្រឈមនៃការរស់នៅក្នុងវប្បធម៌ខុសប្លែកគ្នា (Feldman and Thomas, 1992)។ ទី៣ ការជួយណែនាំជាប្រចាំ អាចនាំឲ្យអ្នកហាត់ការមានលទ្ធផលការងារវិជ្ជមាន ដោយក្នុងនោះពួកគេអាចទទួលបាន ឬទទួលយកការផ្តល់ការងារពីនិយោជកណាមួយ ដោយសារតែបទពិសោធន៍ចុះកម្មសិក្សារបស់ខ្លួន (Taylor, 1985; 1988) ។ យោងតាមដំណើរការនេះ អ្នកស្រាវជ្រាវបានរកឃើញថា អ្នកហាត់ការដែលទទួលជោគជ័យ ក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកជួយណែនាំជាប្រចាំ ទំនងមានលទ្ធផលចុះកម្មសិក្សាវិជ្ជមានច្រើនជាងអ្នកពុំទទួលបានជោគជ័យក្នុងទំនាក់ទំនងនេះ។ តារាង១ បង្ហាញដោយសង្ខេបពីក្របខ័ណ្ឌដែលត្រូវបានប្រើប្រាស់ សម្រាប់ស្វែងយល់ពី បទពិសោធន៍របស់អ្នកហាត់ការជនជាតិកូរ៉េខាងត្បូងនៅវិទ្យាស្ថាន CDRI ។

តារាង២៖ បញ្ជីអ្នកចូលរួម

| អ្នកចូលរួម | ឋានៈ |
|---|---|
| PA | អ្នកហាត់ការស្រាវជ្រាវ |
| PB | អ្នកហាត់ការស្រាវជ្រាវ |
| PC | អ្នកហាត់ការស្រាវជ្រាវ |
| PD | អ្នកហាត់ការស្រាវជ្រាវ |
| PE | អ្នកហាត់ការស្រាវជ្រាវ |
| PF | អ្នកហាត់ការស្រាវជ្រាវ |
| PG | អ្នកស្រាវជ្រាវជាន់ខ្ពស់ |
| PH | រដ្ឋបាលជាន់ខ្ពស់ |

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះប្រើ វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ។ ការធ្វើសម្ភាសន៍ និងការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន គឺជា វិធីសាស្ត្រប្រមូលទិន្នន័យចម្បង ដែលត្រូវបានប្រើប្រាស់ដើម្បីស្វែងយល់ឲ្យបានស៊ីជម្រៅពីកត្តាជំរុញទឹកចិត្ត និងបទពិសោធន៍របស់អ្នកហាត់ការជនជាតិកូរ៉េខាងត្បូងនៅវិទ្យាស្ថាន CDRI។ សម្ភាសន៍ត្រូវបានធ្វើឡើងជាពីរដំណាក់កាល៖ ដំណាក់កាលទី១ ធ្វើជាមួយអ្នកហាត់ការបួននាក់ដែលបានចុះកម្មសិក្សានៅវិទ្យាស្ថាន CDRI ពីខែសីហា ២០១៧ ដល់ខែមករា ២០១៨ និងដំណាក់កាលទី២ ជាមួយអ្នកហាត់ការពីរនាក់ផ្សេងទៀត ដែលបានចុះកម្មសិក្សានៅវិទ្យាស្ថានដែរ ពីខែសីហា ២០១៨ ដល់ខែមករា ២០១៩ និងបុគ្គលិកវិទ្យាស្ថានចំនួនពីរនាក់ ដែលត្រូវបានជ្រើសរើសដោយផ្អែកលើបទពិសោធន៍ និងការចូលរួមក្នុងកម្មវិធីចុះកម្មសិក្សា។ សម្ភាសន៍ជាមួយបុគ្គលិកវិទ្យាស្ថាន CDRI បានផ្តល់នូវបរិបទរួមនៃរយៈពេលចុះកម្មសិក្សា។ ទិន្នន័យ ត្រូវបានយកមកវិភាគក្នុងក្របខ័ណ្ឌកត្តាទាំងបួន នៃការពេញចិត្តលើការចុះកម្មសិក្សា (តារាង១)។ ដើម្បីរក្សាការសម្ងាត់លើអត្តសញ្ញាណ និងព័ត៌មានរបស់អ្នកចូលរួម ក្រុមអ្នកស្រាវជ្រាវបានប្រើឈ្មោះជំនួស ដូចមានចុះក្នុងតារាង២ សម្រាប់ធ្វើការវិភាគ។

ការទទួលស្គាល់អត្ថប្រយោជន៍ និងភាពលំអៀងនៃការសិក្សាមានសារៈសំខាន់ណាស់ដោយហេតុថា អ្នកចូលរួមបីនាក់ (អ្នកហាត់ការពីរនាក់ និងអ្នកជួយណែនាំជាប្រចាំរបស់ពួកគេ) ជាអ្នកនិពន្ធអត្ថបទនេះ។ អ្នកនិពន្ធជាអ្នកស្រាវជ្រាវពីខាងក្នុង ដូច្នេះមានការយល់ដឹងលំអិត ពីវប្បធម៌អង្គភាពនៅវិទ្យាស្ថាន CDRI ហើយអាចធ្វើការប្រាស្រ័យទាក់ទង ជាមួយអ្នកចូលរួមឯទៀតក្នុងការសិក្សានេះបានយ៉ាងលឿន និងងាយស្រួល។ អ្នកនិពន្ធក៏អាចដាក់បញ្ចូលគំនិតផ្ទាល់ខ្លួន ទៅក្នុងក្របខ័ណ្ឌសិក្សានេះដែរ។ ម្យ៉ាងទៀត អ្នកនិពន្ធអាចនាំយកភាពលំអៀងខ្លះចូលមកក្នុងការសិក្សានេះ ជាពិសេសក្នុងការបកស្រាយលទ្ធផលស្រាវជ្រាវ។ ប៉ុន្តែដោយហេតុថា អ្នកនិពន្ធម្នាក់ ជាអ្នកស្រាវជ្រាវមានបទពិសោធន៍ច្រើន ក្រុមស្រាវជ្រាវអាចធានាបានថា វិធីសាស្ត្រស្រាវជ្រាវ និងការអនុវត្តក្នុងការសិក្សាទាំងមូល មានភាពត្រឹមត្រូវ និងច្បាស់លាស់។

## ករណីសិក្សារបស់អ្នកហាត់ការបរទេស នៅវិទ្យាស្ថាន CDRI

### *កម្មវិធីចុះកម្មសិក្សា*

ជាចំណែកមួយនៃកម្មវិធីបណ្ដុះបណ្ដាលសមត្ថភាព វិទ្យាស្ថាន CDRI បានផ្ដល់ឱកាសដល់អ្នកដែលទើបចាប់ផ្ដើមអាជីពជាអ្នកស្រាវជ្រាវទាំងនៅកម្ពុជា និងមកពីបរទេស រួមបញ្ចូលទាំងនិស្សិតសាកលវិទ្យាល័យ និងអ្នកទើបបញ្ចប់ការសិក្សា ឲ្យទទួលបានបទពិសោធន៍ស្រាវជ្រាវ និងរដ្ឋបាល តាមរយៈកម្មវិធីណែនាំជាប្រចាំ (mentor-protégé programs)។ លើសពីនេះទៀត កម្មវិធីចុះកម្មសិក្សាអន្តរជាតិ បានជំរុញឲ្យវិទ្យាស្ថាន CDRI បង្កើតនូវកិច្ចសហការស្រាវជ្រាវជាមួយស្ថាប័នអន្តរជាតិនានា និងលើកទឹកចិត្តឲ្យមានការផ្លាស់ប្ដូរគំនិត បទពិសោធន៍ និងចំណេះដឹងជំនាញ ជាមួយអ្នកស្រាវជ្រាវ និងនិស្សិតក្នុងស្រុក (សម្ភាសន៍ជាមួយ PG ថ្ងៃទី១២ ធ្នូ ២០១៨)។

ជាគោលការណ៍ អ្នកហាត់ការម្នាក់ៗត្រូវបានចាត់តាំងឲ្យធ្វើការយ៉ាងជិតស្និទ្ធ ជាមួយអ្នកស្រាវជ្រាវជាន់ខ្ពស់ម្នាក់ក្នុងកម្មវិធីណែនាំជាប្រចាំនេះ។ នៅអំឡុងពេលធ្វើការសិក្សានេះ ក្រុមស្រាវជ្រាវផ្នែកអប់រំ បានអនុវត្តកម្មវិធីណែនាំជាប្រចាំ ដែលជាគោលនយោបាយមួយរបស់វិទ្យាស្ថាន ក្នុងភាពតឹងរ៉ឹងជាងក្រុមស្រាវជ្រាវផ្នែកផ្សេងៗទៀត។ ក្នុងរយៈពេល ៦ឆ្នាំកន្លងមកនេះ វិទ្យាស្ថាន CDRI បានទទួលអ្នកហាត់ការជាមធ្យម ១៧នាក់ក្នុងមួយឆ្នាំ ឬសរុប ៩៥នាក់គិតត្រឹមឆ្នាំ២០១៨ ក្នុងនោះ ២៤នាក់ ជានិស្សិតអន្តរជាតិមកពី ១០ប្រទេស ដូចជា អូស្ត្រាលី កាណាដា បារាំង ម៉ាឡេស៊ី សិង្ហបុរី កូរ៉េខាងត្បូង ស៊ុយអែត ថៃ អង់គ្លេស និងសហរដ្ឋអាមេរិក។ រយៈពេលនៃការហាត់ការស្ថិតក្នុងចន្លោះពី ៣ខែ ដល់ ១២ខែ។

### *បទពិសោធន៍ចុះកម្មសិក្សា*

នៅពេលបញ្ចប់កម្មវិធីចុះកម្មសិក្សា អ្នកហាត់ការទាំង ៦នាក់ បានបញ្ជាក់ពីការពេញចិត្តលើបទពិសោធន៍របស់ខ្លួន ដោយផ្អែកលើកត្តាបីជាសំខាន់។កត្តាទី១ទាក់ទងទៅនឹងបទពិសោធន៍អនុវត្តជាក់ស្តែងក្នុងតួនាទីផ្នែកស្រាវជ្រាវ និងរដ្ឋបាល និងការយល់ដឹងពីការអភិវឌ្ឍនៅកម្ពុជានាពេលបច្ចុប្បន្ន។ ទាក់ទងនឹងលក្ខណៈសំគាល់ការងារ អ្នកហាត់ការបានចូលរួមក្នុងគ្រប់សកម្មភាពនៃវដ្តស្រាវជ្រាវ គឺចាប់តាំងពី ការកំណត់គោលគំនិត និងការគ្រោងគម្រោងស្រាវជ្រាវ រហូតដល់ការចុះមូលដ្ឋាន ការប្រមូលនិងវិភាគទិន្នន័យ ការសរសេររបាយការណ៍ និង ការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ។

> យើងទាំងអស់គ្នាជានិស្សិតថ្នាក់បរិញ្ញាបត្រ ដូច្នេះយើងត្រូវអនុវត្តតាមកម្មវិធីសិក្សា របស់សាកលវិទ្យាល័យដែលមានទាំងការរៀនក្នុងវគ្គសិក្សា និងការបង្រៀនផ្សេងៗដែលមិនមែនជាចំណាប់អារម្មណ៍របស់យើង។ ដូច្នេះ បទពិសោធន៍នៅ CDRI ជាកាតាលីករដ៏ធំមួយក្នុងការរៀបចំអនាគតរបស់យើង។ ចំណេះដឹង [ដែលទទួលបាន] ពីការពន្យល់មេរៀន សុទ្ធតែជាទ្រឹស្តីដែលថាតាមតែសៀវភៅ។ យើងមិនអាចយកចំណេះដឹងដ៏ធំធេងទាំងនោះមកអនុវត្តជាក់ស្តែងបានទេ ប៉ុន្តែយើងអាចប្រើប្រាស់អ្វីដែលយើងបានរៀនពីការចុះកម្មសិក្សានៅ CDRI។ ដើម្បីធ្វើការស្រាវជ្រាវ និងសរសេររបាយការណ៍ស្រាវជ្រាវបាន យើងត្រូវប្រើចំណេះដឹងទូទៅ និងចំណេះដឹងស៊ីជម្រៅអំពីបញ្ហា ច្រើនជាងអ្វីដែលមានបង្រៀននៅក្នុងសាលា។
> (សម្ភាសន៍ជាមួយ PA ថ្ងៃទី១៣ តុលា ២០១៧)

អ្នកហាត់ការ ក៏ចាប់អារម្មណ៍យ៉ាងខ្លាំងនឹងបរិយាកាសនៅវិទ្យាស្ថាន CDRI ដែលទាក់ទងនឹងកត្តាបុគ្គល លក្ខណៈសំគាល់ការងារ បរិយាកាសអង្គភាព និងជាពិសេស ការសហការ និងភាពរាក់ទាក់របស់បុគ្គលិក CDRI វប្បធម៌នៅកន្លែងធ្វើការប្រកបដោយស្វ័យភាពនិងគំនិតច្នៃប្រឌិត និងរបៀបនៃការរៀនសូត្រតាមការអនុវត្តជាក់ស្តែង ពោលគឺ ការរៀនតាមការអនុវត្តសាកល្បង និងស្វែងរកកំហុស (trail and errors)។ អ្នកហាត់ការម្នាក់បានលើកពីចំណុចវប្បធម៌នៅកន្លែងធ្វើការ ដែលបានជួយសម្រួលឲ្យគាត់អនុវត្តការងារបានល្អ និងមានផលិតភាព។ ចំណុចនេះមានភាពខុសប្លែកពី ក្រុមហ៊ុនជាច្រើននៅកូរ៉េខាងត្បូងដែលមានបទបញ្ញត្តិនៅកន្លែងធ្វើការតឹងរ៉ឹង និងមិនអាចបត់បែនបាន។ លើសពីនេះទៀត អ្នកហាត់ការទាំងអស់ បានបញ្ជាក់ពីការពេញចិត្តលើកម្មវិធីណែនាំជាប្រចាំ របស់វិទ្យាស្ថាន CDRI ដោយប្រាប់ថា ពួកគេរៀនបានច្រើនពីកម្មវិធីចុះកម្មសិក្សានេះ គឺមានតាំងពីជំនាញស្រាវជ្រាវ រហូតដល់ការយល់ដឹងពីសារៈសំខាន់នៃសង្គមវប្បធម៌។ អ្នកហាត់ការម្នាក់ បានលើកឡើងថា៖

> ខ្ញុំធ្វើការនៅទីនេះជានិយោជិតម្នាក់ ទន្ទឹមនឹងនេះ ខ្ញុំក៏ជានិស្សិតសាកលវិទ្យាល័យមួយរូបផងដែរ។ ចំណុចនេះមានន័យថា យើងនៅមានអ្នកត្រួតពិនិត្យពីខាងសាលា ហើយយើង នៅតែអាចទទួលបានការណែនាំពីពួកគាត់។ យើងអាចធ្វើការ និងរៀនក្នុងពេលជាមួយគ្នា គឺដូចគ្នានឹងការបណ្ដុះបណ្ដាលមុនពេលចូលបម្រើការងារដែរ។
> (សម្ភាសន៍ជាមួយ PD ថ្ងៃទី១ តុលា ២០១៨)

អ្នកហាត់ការបួននាក់ បានគូសបញ្ជាក់ថា កម្មវិធីចុះកម្មសិក្សាបានបង្រៀនពួកគេ ពីបែបបទធ្វើការស្រាវជ្រាវដែលមានតាំងពីការសិក្សាឯកសារមានស្រាប់ រហូតដល់ការសរសេររបាយការណ៍ រួមទាំងប្រធានបទ ដែលទាក់ទងនឹងជំនាញរបស់ពួកគេផងដែរ។ អ្នកហាត់ការម្នាក់បាននិយាយថា ការស្រាវជ្រាវបែបសិក្សាជាផ្នែកមួយដ៏សំខាន់នៃការសិក្សារបស់គាត់ ហើយគាត់ចង់បន្តចាប់យកការស្រាវជ្រាវដែលមានវិជ្ជាជីវៈ ឲ្យហួសពីកម្រិតដែលសាកលវិទ្យាល័យផ្ដល់ឲ្យ។ អ្នកហាត់ការម្នាក់ទៀត បានលើកពីចំណុចខ្សោយរបស់គាត់ក្នុងការស្រាវជ្រាវ និងសរសេរ ហើយសង្ឃឹមថាគាត់នឹងអាចពង្រឹងជំនាញសរសេររបស់ខ្លួន តាមរយៈកម្មវិធីចុះកម្មសិក្សានៅវិទ្យាស្ថាន CDRI។ ជារួម អ្នកហាត់ការទាំងនេះបានបង្កើននូវចំណាប់អារម្មណ៍ ទៅលើការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ដោយសារហេតុផលផ្សេងៗ។ លើសពីនេះទៀត ឱកាសបានចូលរួមក្នុងសកម្មភាពស្រាវជ្រាវជាក់ស្តែង ដូចជា ការចុះទៅដល់មូលដ្ឋាន និងការប្រមូលទិន្នន័យ ក៏ជាកត្តាជំរុញទឹកចិត្តឲ្យស្រឡាញ់ការស្រាវជ្រាវថែមទៀតផងដែរ។

អ្នកហាត់ការទាំង ៦នាក់ បានរាយការណ៍ថា កម្មវិធីចុះកម្មសិក្សានៅវិទ្យាស្ថាន CDRI បានពង្រីកការយល់ដឹងរបស់ពួកគេពីវប្បធម៌នៅកម្ពុជា។ នេះជាបទពិសោធន៍បន្ថែមមួយសម្រាប់អ្នកដែលរៀនជំនាញសិក្សាអន្តរជាតិ ពីព្រោះពួកគេអាចទទួលបានការយល់ដឹងទូលំទូលាយ តាមរយៈការសង្កេតពីព្រឹត្តិការណ៍អន្តរជាតិផ្សេងៗ ដោយឈរលើទស្សនៈវប្បធម៌ខុសពីមុន។ ការមានគំនិតបែបទស្សនវិស័យមិនលំអៀង គឺជាចំណុចវិជ្ជមានមួយនៅក្នុងមុខជំនាញ និងវិជ្ជាជីវៈភាគច្រើន។ តាមរយៈការចូលប្រឡូកផ្ទាល់ក្នុងវប្បធម៌ខុសគ្នាបែបនេះ អ្នកហាត់ការអាចទទួលបានបទពិសោធន៍ជាក់ស្តែង និងអាចពង្រីកការយល់ដឹងរបស់ខ្លួន។ បទពិសោធន៍ទាំងនេះ នឹងជួយឲ្យពួកគេត្រៀមខ្លួនរួចរាល់សម្រាប់ការងារទាក់ទងនឹងការអភិវឌ្ឍអន្តរជាតិនៅថ្ងៃអនាគត។

សំខាន់ផងដែរ ការពង្រីកចំណេះដឹងផ្នែកវប្បធម៌ បានផ្តល់អត្ថប្រយោជន៍ដល់អ្នកហាត់ការក្នុងស្រុក និងអន្តរជាតិ ក៏ដូចជាអ្នកស្រាវជ្រាវដែលនៅមានបទពិសោធន៍តិចតួច។ អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ម្នាក់បានលើកចំណុចនេះឡើងដោយបញ្ជាក់ថា អ្នកស្រាវជ្រាវក្នុងស្រុក ជាពិសេសអ្នកស្រាវជ្រាវទើបនឹងចាប់ផ្តើមអាជីពដែលមិនធ្លាប់ ឬធ្លាប់បានធ្វើដំណើរទៅប្រទេសក្រៅតិចតួច អាចយល់ដឹងបន្ថែមពីវប្បធម៌ខុសៗគ្នា តាមរយៈការធ្វើការ និងការប្រាស្រ័យទាក់ទងជាមួយអ្នកហាត់ការបរទេស (សម្ភាសន៍ជាមួយ PG ថ្ងៃទី៩ មករា ២០១៩)។

នៅចុងបញ្ចប់នៃសម្ភាសន៍អ្នកហាត់ការគ្រប់រូបបាននិយាយថា បើសិនគាត់អាចសម្រេចចិត្តលើការចុះកម្មសិក្សាម្តងទៀតពួកគាត់នៅតែជ្រើសយកវិទ្យាស្ថាន CDRI ដដែល ដោយលើកឡើងថា បទពិសោធន៍ស្រាវជ្រាវជាក់ស្តែង និងបរិយាកាសនៅកន្លែងធ្វើការជាកត្តាចម្បង។ សំដីនេះអាចជួយឲ្យសន្និដ្ឋានបានថា បទពិសោធន៍វិជ្ជមានរបស់អ្នកហាត់ការ ត្រូវបានជំរុញឡើងដោយលក្ខណៈសំគាល់នៃការងារ និងបរិយាកាសអង្គភាព។ បទពិសោធន៍វិជ្ជមានដែលអ្នកហាត់ការទាំងពីរក្រុម បានរាយការណ៍ឡើង បង្ហាញពីភាពជោគជ័យជាបន្តបន្ទាប់ នៃកម្មវិធីណែនាំជាប្រចាំ និងពីទំនាក់ទំនងដ៏រឹងមាំរវាងវិទ្យាស្ថាន CDRI និងសមភាគីកូរ៉េខាងត្បូង។

> អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ម្នាក់ បានលើកបង្ហាញ [ឯកសារមួយ] ក្នុងសន្និសីទមួយរៀបចំឡើងនាពេលកន្លងមក ដោយសារកលវិទ្យាល័យជាតិ Chonbuk និងសមាគមកូរ៉េសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍអន្តរជាតិ (KAIDEC)។ កាលនោះ អ្នកស្រាវជ្រាវរូបនោះ បានជួបជាមួយសាស្ត្រាចារ្យម្នាក់មកពីសាកលវិទ្យាល័យ Chonbuk ហើយបានជជែកគ្នាពីកម្មវិធីចុះកម្មសិក្សាអន្តរជាតិរបស់វិទ្យាស្ថាន CDRI។ ឆ្លងតាមការសន្ទនានេះ សាស្ត្រាចារ្យនោះបានមកធ្វើទស្សនកិច្ចនៅវិទ្យាស្ថាន CDRI ហើយបានស្នើឲ្យ CDRI ទទួលយកនិស្សិតខ្លះធ្វើជាអ្នកហាត់ការ។ ក្រោយអនុវត្តបានប៉ុន្មានឆ្នាំ សាស្ត្រាចារ្យរូបនោះ បានកើនទំនុកចិត្តជាខ្លាំងលើគុណភាពនិងកម្មវិធីរបស់វិទ្យាស្ថាន CDRI ហើយតែងបញ្ជូននិស្សិត ៣-៤នាក់ មកធ្វើជាអ្នកហាត់ការរយៈពេល ៦ខែ ជារៀងរាល់ឆ្នាំ។ (សម្ភាសន៍ជាមួយ PG ថ្ងៃទី៩ មករា ២០១៩)។

សេចក្តីអធិប្បាយខាងលើ បានបង្ហាញពីតួនាទីបណ្តុះបណ្តាលធនធានមនុស្ស ក្នុងសកម្មភាពសហប្រតិបត្តិការអន្តរជាតិ រវាងវិទ្យាស្ថាន CDRI និងសាកលវិទ្យាល័យជាតិ Chonbuk។

ទន្ទឹមគ្នានឹងបទពិសោធន៍វិជ្ជមាន អ្នកហាត់ការជាច្រើននាក់បានរៀបរាប់ពីបទពិសោធន៍អវិជ្ជមានរបស់ខ្លួន ក្នុងអំឡុងពេលស្នាក់នៅក្នុងប្រទេសកម្ពុជា ដូចជា ការបំពុលខ្យល់ ប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលរៀបចំមិនទាន់បានល្អ ពោលគឺ បទពិសោធន៍ទាក់ទងនឹងកត្តាបរិបទ។ ពួកគេក៏បានលើកពីរបាំងភាសាផងដែរ ព្រោះពួកគេមិនចេះនិយាយភាសាខ្មែរនោះទេ។ សូម្បីនៅវិទ្យាស្ថាន CDRI ដែលភាសាអង់គ្លេសត្រូវបានប្រើប្រាស់ជាភាសាផ្លូវការនៅក្នុងម៉ោងធ្វើការ ក៏មានសកម្មភាពជាច្រើន រួមទាំងការចុះមូលដ្ឋានផង ត្រូវការជំនាញភាសាខ្មែរកម្រិតមូលដ្ឋាន ដើម្បីធ្វើទំនាក់ទំនង។ អ្នកហាត់ការម្នាក់បានផ្តល់មតិឲ្យវិទ្យាស្ថាន CDRI រៀបចំការបង្រៀនភាសាខ្មែរ ដើម្បីជួយគាំទ្រដល់អ្នកហាត់ការបរទេស ហើយក៏មានអ្នកហាត់ការជាច្រើននាក់ទៀត បានបង្ហាញការសោកស្តាយ ដែលមិនបានរៀនភាសាខ្មែរមុនពេលមកកម្ពុជា។ អ្នកចូលរួម PH បានផ្តល់មតិថា ការរៀនពាក្យ និងឃ្លាប្រើប្រាស់ប្រចាំថ្ងៃជាភាសាខ្មែរខ្លះ និងការយល់ដឹងពីវប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជា ក្នុងពេលរៀបចំខ្លួនមកចុះកម្មសិក្សា ពិតជាអាចជួយពួកគេបានច្រើន។

កម្មវិធីជួយណែនាំជាប្រចាំ ក៏មានសារៈសំខាន់គួរឲ្យកត់សំគាល់ដែរ។ ទោះបីជាអ្នកហាត់ការច្រើននាក់ ពេញចិត្តនឹងកម្មវិធីនេះក្តី ក៏មានអ្នកហាត់ការម្នាក់បានរាយការណ៍ថា អ្នកជួយណែនាំជាប្រចាំ មិនបានជួយណែនាំគ្រប់គ្រាន់ទេក្នុងគ្រាដំបូងៗ។ អ្នកហាត់ការនោះបានប្រាប់ថា ខ្លឹមសារនៃកម្មវិធី គឺប្រែប្រួលទៅតាមអ្នកជួយណែនាំជាប្រចាំ និងទៅតាមគម្រោងដែលគាត់កំពុងធ្វើ។ អ្នកហាត់ការម្នាក់ទៀតបាននិយាយថា ទំនាក់ទំនងរវាងអ្នកជួយណែនាំជាប្រចាំ និងអ្នកទទួលការណែនាំ មានភាពរអាក់រអួលបន្តិច ដោយសារអ្នកជួយណែនាំ ត្រូវចូលរួមកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ស្រាវជ្រាវនៅបរទេស។

## សេចក្តីសន្និដ្ឋាន

អត្ថបទនេះ ផ្តល់ការយល់ដឹងលំអិតពីបទពិសោធន៍ចុះកម្មសិក្សារបស់និស្សិតកូរ៉េខាងត្បូង នៅវិទ្យាស្ថាន CDRI។ បទពិសោធន៍នៃវប្បធម៌ខុសគ្នា ការមើលឃើញទូលាយពីការអភិវឌ្ឍក្នុងតំបន់ និងការយល់ដឹងស៊ីជម្រៅពីជីវិតជាបញ្ញវន្ត គឺជា លទ្ធផលវិជ្ជមានចម្បងៗ បានមកពីបទពិសោធន៍ចុះកម្មសិក្សានៅបរទេសរបស់ពួកគេ។ ការជួយណែនាំសមស្របតាមរយៈកម្មវិធីជួយណែនាំជាប្រចាំ និងបរិយាកាសការងារប្រកបដោយនវានុវត្តន៍ជាផលបន្ថែមមួយទៀត លើបទពិសោធន៍វិជ្ជមានរបស់អ្នកហាត់ការ។ ដូច្នេះគេអាចសន្និដ្ឋានបានថា កម្មវិធីជួយណែនាំជាប្រចាំដែលមានបែបបទកំណត់ច្បាស់លាស់ គួរត្រូវបានពង្រីកទៅក្នុងវិទ្យាស្ថានទាំងមូល ដើម្បីពង្រឹង និងលើកកម្ពស់គុណភាពកម្មវិធីចុះកម្មសិក្សា ជាពិសេស កេរ្តិ៍ឈ្មោះជាសកលរបស់វិទ្យាស្ថាន។ ស្ថាប័នផ្សេងទៀតនៅកម្ពុជា ក៏អាចរៀនសូត្រពីបទពិសោធន៍ជោគជ័យរបស់វិទ្យាស្ថាន CDRI ក្នុងកិច្ចដំណើរការកម្មវិធីជួយណែនាំជាប្រចាំ សម្រាប់អ្នកហាត់ការបរទេសផងដែរ។

ការរៀបចំឲ្យមានការបង្រៀនភាសាខ្មែរ ពិតជាមានអត្ថប្រយោជន៍ណាស់សម្រាប់វិទ្យាស្ថាន និងអ្នកហាត់ការបរទេស។ វិធីនេះ អាចជួយបង្កើនប្រសិទ្ធភាពការចូលរួមក្នុងសង្គម និងការរៀនសូត្ររបស់អ្នកហាត់ការ ក៏ដូចជាការចូលរួមចំណែករបស់ពួកគេក្នុងការងារស្រាវជ្រាវរបស់វិទ្យាស្ថាន។ សរុបមកការចុះកម្មសិក្សា មិនមែនគ្រាន់តែជាការបញ្ជូននិស្សិតទៅបរទេសដោយពុំមានការយល់ដឹងអំពីវប្បធម៌ និងសាវតាររបស់ប្រទេស ឬស្ថាប័ននោះទេ។ ទំនាក់ទំនងរវាងមនុស្ស និងទំនុកចិត្តរឹងមាំ ជាកត្តាដ៏សំខាន់ក្នុងការបង្កើត និងទ្រទ្រង់កម្មវិធីចុះកម្មសិក្សាអន្តរជាតិដូចក្នុងករណីអ្នកហាត់ការកូរ៉េខាងត្បូង នៅវិទ្យាស្ថាន CDRI ជាដើម។

ករណីសិក្សានេះ បានផ្ដោតទៅលើអ្នកហាត់ការកូរ៉េខាងត្បូង នៅវិទ្យាស្ថាន CDRI ត្រឹមតែ ៦នាក់ ប៉ុណ្ណោះ។ ដូច្នេះហើយ វាពិតជាពិបាកក្នុងការយកលទ្ធផល ដែលរកឃើញទៅធ្វើសេចក្ដីសន្និដ្ឋានទូទៅ សម្រាប់អ្នកហាត់ការបរទេសផ្សេងទៀតនៅវិទ្យាស្ថាន CDRI ឬសម្រាប់ចលិតភាពរបស់អ្នកហាត់ការអន្តរជាតិទាំងមូលណាស់។ ម្យ៉ាងទៀត ដោយសារអ្នកនិពន្ធពីររូបជាអ្នកស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI លទ្ធផលស្រាវជ្រាវគួរត្រូវបានប្រើប្រាស់ដោយប្រុងប្រយ័ត្ន។ ចំណុចខ្វះចន្លោះមួយទៀតនៃការស្រាវជ្រាវនេះ គឺ សម្ភាសន៍ត្រូវបានធ្វើឡើងជាពីរដំណាក់កាលក្នុងរយៈពេលខុសគ្នា។ ការសិក្សានាពេលអនាគតគួរពិចារណាពីចំណុចទាំងនេះ និងប្រើវិធីសាស្ត្រប្រៀបធៀបមួយតាមរយៈការស្រាវជ្រាវពីបទពិសោធន៍ របស់អ្នកហាត់ការអន្តរជាតិមកពីប្រទេសផ្សេងៗទៀត។

លើសពីនេះទៀត CDRI ជាករណីពិសេសមួយ ព្រោះវិទ្យាស្ថាននេះ ត្រូវបានបង្កើតឡើងជាផ្លូវការនៅឆ្នាំ២០០០ ដោយអនុក្រឹត្យលេខ៩៤ ក្នុងលក្ខណៈជាវិទ្យាស្ថានស្រាវជ្រាវផ្នែកគោលនយោបាយ ឯករាជ្យ មិនស្វែងរកប្រាក់ចំណេញ ដែលរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ផ្ដល់សេវាកម្ម ដើម្បីលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សនៅក្នុងប្រទេស និងធ្វើការស្រាវជ្រាវ និងវិភាគដើម្បីផ្ដល់ព័ត៌មានដល់ការកសាងគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍។ ដោយមូលហេតុនេះ វិទ្យាស្ថាន CDRI មានបទពិសោធន៍ជាយូរឆ្នាំមកហើយក្នុងការទទួលអ្នកស្រាវជ្រាវ និងអ្នកហាត់ការបរទេស និងមានឈ្មោះល្បីល្បាញក្នុងស្រុក ក្នុងតំបន់ និងអន្តរជាតិលើការស្រាវជ្រាវមានគុណភាពខ្ពស់។ ដូច្នេះការសិក្សានាពេលអនាគត គួរពិនិត្យមើលពីកម្មវិធីចុះកម្មសិក្សាអន្តរជាតិ នៅតាមស្ថាប័នស្រាវជ្រាវ និងមិនមែនស្រាវជ្រាវដទៃទៀតនៅកម្ពុជា។

## ឯកសារយោង


Creswell, John W. 2007. Qualitative Inquiry and Research Design: Choosing among Five Approaches. 3rd edition. Thousand Oaks, CA: Sage.

D'Abate, Caroline P., Mark A. Youndt and Kathryn E. Wenzel. 2009. "Making the Most of an Internship: An Empirical Study of Internship Satisfaction." *Academy of Management Learning & Education* 8 (4): 527–539.

Fagan, Thomas K., and Paula Sachs Wise. 2007. *School Psychology: Past, Present, and Future.* 3rd edition. Bethesda, MA: National Association of School Psychologists.

Feldman, Daniel C., William R. Folks and William H. Turnley. 1999. "Mentor-Protege Diversity and Its Impact on International Internship Experiences." *Journal of Organizational Behavior* 20 (5): 597–611.


*តទៅទំព័រ ១៧*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីសូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍។ ជារួមនៅត្រីមាសទី១ ឆ្នាំ២០២០ កំណើន ផសស ក្នុងប្រទេសជ្រើសរើសទាំងអស់បានធ្លាក់ចុះខ្លាំងរហូតដល់កម្រិតទាបបំផុត។

ក្នុងចំណោមប្រទេសអាស៊ានជ្រើសរើស សិង្ហបុរីមានអត្រាកំណើនទាបបំផុតរហូតដល់ ដក ២,២% បន្ទាប់មកគឺ ថៃ (ដក ១,៨%) ម៉ាឡេស៊ី (០,៧%) ឥណ្ឌូនេស៊ី (២,០%)។ ទិន្នន័យថ្មីបំផុតលើកំណើន ផសស នៅ កម្ពុជា និង វៀតណាម មិនទាន់មាននៅឡើយទេ នៅពេលចងក្រងអត្ថបទនេះ។ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ផសស សិង្ហបុរីធ្លាក់ចុះអស់ ៣,៥ឯកតាភាគរយ ផសស ថៃធ្លាក់ចុះ ៤,៦ឯកតាភាគរយ ម៉ាឡេស៊ីធ្លាក់ចុះ ៣,៨ឯកតាភាគរយ ឥណ្ឌូនេស៊ីធ្លាក់ចុះ ២,១ឯកតាភាគរយ។ ធៀបនឹងត្រីមាសមុន ផសស សិង្ហបុរីធ្លាក់ចុះ ៣,០ឯកតាភាគរយ ថៃធ្លាក់ចុះ ៣,៤ឯកតាភាគរយ ម៉ាឡេស៊ីធ្លាក់ចុះ ២,៩ឯកតាភាគរយ ឥណ្ឌូនេស៊ីធ្លាក់ចុះ ២,០ឯកតាភាគរយ។

ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើស ហុងកុងមានអត្រាកំណើន ផសស ទាបជាងគេ (ដក ៨,៩%) បន្ទាប់មកគឺ ចិន (ដក ៦,៨%) កូរ៉េខាងត្បូង (១,៣%) តៃវ៉ាន់ (១,៥%)។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អត្រាកំណើន ផសស នៅហុងកុងធ្លាក់ចុះ ៩,៥ឯកតាភាគរយ ចិនធ្លាក់ចុះ ១៣,២ឯកតាភាគរយ កូរ៉េខាងត្បូងធ្លាក់ចុះ ០,៥ឯកតាភាគរយ តៃវ៉ាន់ ធ្លាក់ចុះ ០,២ ឯកតាភាគរយ។ ធៀបនឹងត្រីមាសមុន អត្រាកំណើន ផសស នៅហុងកុងធ្លាក់ចុះ ៦,០ឯកតាភាគរយ ចិនធ្លាក់ចុះ ១២,៨ឯកតាភាគរយ កូរ៉េខាងត្បូងធ្លាក់ចុះ ២,១ឯកតាភាគរយ តៃវ៉ាន់ធ្លាក់ចុះ ១,៨ឯកតាភាគរយ។

សម្រាប់ប្រទេសឧស្សាហកម្មជ្រើសរើស តំបន់អឺរ៉ូ១២ មានអត្រាកំណើន ផសស ទាបជាងគេ (ដក ៣,៣%) បន្ទាប់មកគឺ ជប៉ុន (ដក ២,០%) សហរដ្ឋអាមេរិក (០,៣)។ ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ អត្រាកំណើន ផសស នៅតំបន់អឺរ៉ូ១២ ធ្លាក់ចុះអស់ ៤,៥ឯកតាភាគរយ ជប៉ុនធ្លាក់ចុះ ២,៩ឯកតាភាគរយ សហរដ្ឋអាមេរិកធ្លាក់ចុះ ២,៩ឯកតាភាគរយ។ បើធៀបនឹងត្រីមាសមុន អត្រាកំណើន ផសស នៅតំបន់អឺរ៉ូ១២ ធ្លាក់ចុះអស់ ៤,៣ឯកតាភាគរយ ជប៉ុនធ្លាក់ចុះ ១,៣ឯកតាភាគរយ សហរដ្ឋអាមេរិកធ្លាក់ចុះ ២,០ឯកតាភាគរយ។

---

អត្ថបទនេះ រៀបរៀងដោយ រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និង ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

## អតិផរណាក្នុងពិភពលោក

សម្រាប់ប្រទេសអាស៊ានជ្រើសរើស បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ ថៃ និង សិង្ហបុរី មានអត្រាអតិផរណាធ្លាក់ចុះ រីឯ កម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និង វៀតណាម មានអតិផរណាកើនឡើង។ វៀតណាមមានអត្រាអតិផរណាខ្ពស់ជាងគេ (៥,៦%) បន្ទាប់មកគឺ កម្ពុជា (៣,០%) ឥណ្ឌូនេស៊ី (២,៩%) ម៉ាឡេស៊ី (០,៩%) សិង្ហបុរី (០,៤%) ថៃ (០,៤)។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អត្រាអតិផរណានៅវៀតណាមកើនឡើង ៣,០ឯកតាភាគរយ កម្ពុជាកើន ១,១ឯកតាភាគរយ ម៉ាឡេស៊ីកើន ១,២ឯកតាភាគរយ ឥណ្ឌូនេស៊ីកើន ០,៣ឯកតាភាគរយ ប៉ុន្តែអត្រាអតិផរណានៅសិង្ហបុរី ធ្លាក់ចុះ ០,១ឯកតាភាគរយ ថៃធ្លាក់ចុះ ០,៣ឯកតាភាគរយ។ បើធៀបនឹងត្រីមាសមុន វៀតណាមមានអត្រាអតិផរណាកើនឡើង ១,៩ឯកតាភាគរយ កម្ពុជាមានអត្រាអតិផរណាកើន ០,៩ឯកតាភាគរយ រីឯ ឥណ្ឌូនេស៊ី និង ថៃ មានអត្រាអតិផរណានៅថេរ ហើយ ម៉ាឡេស៊ីមានអត្រាអតិផរណាធ្លាក់ចុះ ០,១ឯកតាភាគរយ សិង្ហបុរីធ្លាក់ចុះ ០,២ឯកតាភាគរយ។

ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើស ចិនមានអត្រាអតិផរណាខ្ពស់ជាងគេ (៤,៤%) បន្ទាប់មកគឺ ហុងកុង (២,០%) កូរ៉េខាងត្បូង (១,២%) តៃវ៉ាន់(០,៦)។ ធៀបនឹងកាលពីមួយឆ្នាំមុន អត្រាអតិផរណានៅចិនកើន ២,៦ឯកតាភាគរយ កូរ៉េខាងត្បូងកើន ០,៦ឯកតាភាគរយ តៃវ៉ាន់កើន ០,៣ឯកតាភាគរយ រីឯអត្រាអតិផរណានៅហុងកុងធ្លាក់ចុះ ០,២ឯកតាភាគរយ។ បើធៀបនឹងត្រីមាសមុនអត្រាអតិផរណានៅចិនកើនឡើង ០,១ឯកតាភាគរយ កូរ៉េខាងត្បូង កើន ០,៩ឯកតាភាគរយ រីឯអត្រាអតិផរណានៅហុងកុងធ្លាក់ចុះ ១,០ឯកតាភាគរយ តៃវ៉ាន់ធ្លាក់ចុះ ០,១ឯកតាភាគរយ។

ក្នុងចំណោមប្រទេសឧស្សាហកម្មជ្រើសរើស សហរដ្ឋអាមេរិកមានអត្រាអតិផរណាខ្ពស់ជាងគេ (២,១%) បន្ទាប់មកគឺ តំបន់អឺរ៉ូ១២ (១,១%) ជប៉ុន (០,៥%)។ ធៀបនឹងកាលពីមួយឆ្នាំមុន អត្រាអតិផរណានៅសហរដ្ឋអាមេរិកកើនឡើង ០,៤ឯកតាភាគរយ ហើយ ជប៉ុនកើន ០,២ឯកតាភាគរយ ប៉ុន្តែនៅតំបន់អឺរ៉ូ១២ អត្រាអតិផរណាបានធ្លាក់ចុះ ០,៣ឯកតាភាគរយ។ បើធៀបនឹងត្រីមាសមុន អត្រាអតិផរណានៅសហរដ្ឋអាមេរិក និងជប៉ុននៅថេរ ប៉ុន្តែនៅតំបន់អឺរ៉ូ១២ វាកើនឡើង។

## អត្រាប្តូរប្រាក់

ធៀបនឹងកាលពីមួយឆ្នាំមុន ប្រាក់បាតថៃ ដុល្លារតៃវ៉ាន់ និងប្រាក់យ៉េនជប៉ុន បានឡើងថ្លៃទល់នឹងដុល្លារអាមេរិក រីឯប្រាក់រៀលកម្ពុជា ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ី ប្រាក់រីងហ្គិតម៉ាឡេស៊ី ប្រាក់ដុងវៀតណាម ប្រាក់យ័នចិន ដុល្លារហុងកុង ប្រាក់វ៉ុនកូរ៉េខាងត្បូង និងប្រាក់អឺរ៉ូ បានចុះថ្លៃ។ ប្រាក់រៀលកម្ពុជាបានចុះថ្លៃ ១,៤% ដល់ ៤.០៦៤,១រៀល/ដុល្លារ ហើយប្រាក់ដុងវៀតណាមចុះថ្លៃ ២,០% ដល់ ២៣.៣៥១,០ដុង/ដុល្លារ ប៉ុន្តែប្រាក់បាតថៃឡើងថ្លៃ ១,៣% ដល់ ៣១,២បាត/ដុល្លារ។ បើធៀបនឹងត្រីមាសមុន ប្រាក់រៀលកម្ពុជាចុះថ្លៃ ០,០១% ទល់នឹងដុល្លារអាមេរិក ប្រាក់បាតថៃចុះថ្លៃ ៣,០% ហើយប្រាក់ដុងវៀតណាមចុះថ្លៃ ០,៦%។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ កៅស៊ូ ប្រេងឆៅ សាំង និង ម៉ាស៊ូត បានចុះថ្លៃ រីឯ ពោត ប្រេងដូងប្រេង អង្ករ និងសណ្តែកសៀង បានឡើងថ្លៃ។ កៅស៊ូបានចុះថ្លៃ ៤,៣% ប្រេងឆៅចុះថ្លៃ ១៨,៨% សាំងចុះថ្លៃ ១៦,៤% ម៉ាស៊ូតចុះថ្លៃ ២០,៨% ប៉ុន្តែពោតឡើងថ្លៃ ០,១% ប្រេងដូងប្រេងឡើងថ្លៃ ២៣,៥% អង្ករឡើងថ្លៃ ១២,៨% សណ្តែកសៀងឡើងថ្លៃ ២,១%។ បើធៀបនឹងត្រីមាសមុន កៅស៊ូចុះថ្លៃ ២,៥% ប្រេងឆៅចុះថ្លៃ ១៨,៦% សាំងចុះថ្លៃ ២១,០% ម៉ាស៊ូតចុះថ្លៃ ២០,៦% ប៉ុន្តែពោតឡើងថ្លៃ ០,៥% ប្រេងដូងប្រេងឡើងថ្លៃ ៦,៥% អង្ករឡើងថ្លៃ ៨,៧% ហើយសណ្តែកសៀងឡើងថ្លៃ ៣,៩%។

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.3 | 7.4 | 7.1 | 7.0 | 7.0 | 7.0 | 7.5 | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 6.3 | 5.8 | 5.2 | 4.8 | 5.0 | 5.1 | 5.2 | 5.1 | 5.0 | 5.0 | 5.0 | 3.0 |
| ម៉ាឡេស៊ី | 5.4 | 4.6 | 6.0 | 4.9 | 4.3 | 5.9 | 4.8 | 4.5 | 4.9 | 4.4 | 3.6 | 0.7 |
| សិង្ហបុរី | 1.3 | 3.8 | 3.0 | 2.0 | 2.0 | 3.8 | 3.2 | 1.3 | 0.1 | 0.5 | 0.8 | -2.2 |
| ថៃ | 6.8 | 2.8 | 1.6 | 2.8 | 3.2 | 3.8 | 4.1 | 2.8 | 2.3 | 2.4 | 1.6 | -1.8 |
| វៀតណាម | 5.2 | 5.4 | 5.9 | 6.6 | 6.1 | 6.6 | 7.2 | 6.8 | 6.7 | 7.3 | 7.0 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 7.8 | 7.7 | 7.3 | 7.0 | 6.7 | 6.9 | 6.6 | 6.4 | 6.2 | 6.0 | 6.0 | -6.8 |
| ហុងកុង | 2.9 | 3.0 | 2.3 | 2.3 | 1.7 | 2.8 | 3.1 | 0.6 | 0.5 | 2.9 | -2.9 | -8.9 |
| កូរ៉េខាងត្បូង | 2.1 | 2.8 | 3.4 | 2.6 | 2.6 | 3.0 | 3.0 | 1.8 | 2.1 | 2.0 | 3.4 | 1.3 |
| តៃវ៉ាន់ | 1.2 | 2.2 | 3.5 | 0.6 | 1.2 | 2.8 | 2.6 | 1.7 | 2.4 | 3.0 | 3.3 | 1.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | -0.5 | 0.1 | 0.7 | 1.3 | 1.6 | 2.3 | 1.9 | 1.2 | 1.1 | 1.2 | 1.0 | -3.3 |
| ជប៉ុន | 1.7 | 1.7 | 0.6 | 0.3 | 0.9 | 1.8 | 0.6 | 0.9 | 1.2 | 1.7 | -0.7 | -2.0 |
| សហរដ្ឋអាមេរិក | 2.1 | 1.8 | 2.4 | 2.3 | 1.6 | 2.3 | 3.0 | 3.2 | 2.3 | 2.1 | 2.3 | 0.3 |

Sources: International Monetary Fund; *Economist*; countries' statistics offices

## តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 3.0 | 3.0 | 3.9 | 1.2 | 3.0 | 2.9 | 2.5 | 1.9 | 1.8 | 2.0 | 2.1 | 3.0 |
| ឥណ្ឌូនេស៊ី | 4.3 | 7.0 | 6.4 | 6.4 | 3.5 | 3.8 | 3.2 | 2.6 | 3.1 | 3.4 | 2.9 | 2.9 |
| ម៉ាឡេស៊ី | 1.7 | 2.1 | 3.2 | 2.1 | 2.1 | 3.9 | 1.0 | -0.3 | 0.6 | 1.3 | 1.0 | 0.9 |
| សិង្ហបុរី | 4.6 | 2.3 | 1.0 | -0.5 | -0.8 | 0.6 | 0.4 | 0.5 | 0.8 | 0.5 | 0.6 | 0.4 |
| ថៃ | 3.0 | 2.2 | 1.9 | -0.9 | 0.2 | 0.7 | 1.1 | 0.7 | 1.1 | 0.6 | 0.4 | 0.4 |
| វៀតណាម | 9.3 | 6.6 | 4.8 | 0.6 | 2.7 | 3.4 | 3.6 | 2.6 | 2.7 | 2.2 | 3.7 | 5.6 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 2.7 | 2.6 | 2.0 | 1.4 | 2.0 | 1.6 | 2.1 | 1.8 | 2.6 | 2.9 | 4.3 | 4.4 |
| ហុងកុង | 4.1 | 4.0 | 4.4 | 3.1 | 2.5 | 1.7 | 2.4 | 2.2 | 2.7 | 3.4 | 3.0 | 2.0 |
| កូរ៉េខាងត្បូង | 2.1 | 1.1 | 1.3 | 0.7 | 0.8 | 2.0 | 1.4 | 0.6 | 0.7 | 0.1 | 0.3 | 1.2 |
| តៃវ៉ាន់ | 1.9 | 0.8 | 1.5 | 0.6 | 1.4 | 0.6 | 1.4 | 0.3 | 0.8 | 0.4 | 0.7 | 0.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.5 | 1.4 | 0.4 | 0.0 | 0.3 | 1.5 | 1.8 | 1.4 | 1.4 | 1.0 | 1.0 | 1.1 |
| ជប៉ុន | 0.0 | 0.4 | 2.8 | 0.9 | -0.1 | 0.6 | 1.0 | 0.3 | 0.7 | 0.3 | 0.5 | 0.5 |
| សហរដ្ឋអាមេរិក | 2.1 | 1.5 | 1.6 | 0.0 | 1.2 | 2.1 | 2.5 | 1.7 | 1.8 | 1.7 | 2.1 | 2.1 |

Sources: International Monetary Fund; *Economist*; National Institute of Statistics

## តារាង៣៖ អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4037.8 | 4027.2 | 4037.6 | 4060.4 | 4053.6 | 4047.0 | 4045.0 | 4006.6 | 4052.1 | 4086.8 | 4063.7 | 4064.1 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9363.0 | 10419.2 | 11,850.2 | 13394.8 | 13338.3 | 13379.8 | 14227.6 | 14127.8 | 14246.8 | 14117.6 | 14060.5 | 14220.3 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.1 | 3.1 | 3.3 | 3.9 | 4.1 | 4.3 | 4.0 | 4.1 | 4.1 | 4.2 | 4.2 | 4.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.2 | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 31.1 | 30.7 | 32.5 | 34.2 | 35.3 | 33.9 | 32.3 | 31.6 | 31.6 | 30.7 | 30.3 | 31.2 |
| វៀតណាម (ដុង) | 20856.9 | 20990.3 | 21,138.2 | 21917.7 | 22507.5 | 22645.9 | 22663.3 | 22902.9 | 23255.5 | 23258.3 | 23217.3 | 23351.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន) | 6.3 | 6.1 | 6.2 | 6.3 | 6.6 | 6.8 | 6.6 | 6.7 | 6.8 | 7.0 | 7.0 | 7.0 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1126.6 | 1095.0 | 1053.6 | 1131.9 | 1161.0 | 1130.5 | 1099.9 | 1125.0 | 1165.4 | 1193.4 | 1174.7 | 1191.5 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់) | 29.6 | 29.7 | 30.3 | 31.8 | 32.3 | 30.4 | 30.1 | 30.8 | 31.1 | 31.2 | 30.5 | 30.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 79.8 | 97.6 | 105.9 | 121.0 | 108.8 | 112.1 | 110.4 | 110.1 | 109.9 | 107.3 | 108.7 | 109.0 |

Sources: International Monetary Fund; *Economist*; National Bank of Cambodia

## តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១២-២០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No.2) - USA (ដុល្លារ/តោន) | 298.4 | 259.4 | 192.9 | 169.8 | 159.2 | 154.5 | 164.4 | 167.5 | 175.9 | 170.1 | 166.8 | 167.6 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 999.3 | 856.9 | 821.4 | 622.7 | 643.6 | 714.7 | 638.7 | 586.9 | 568.1 | 570.1 | 680.2 | 724.7 |
| កៅស៊ូ SMR 5 (ដុល្លារ/តោន) | 3200.7 | 2575.3 | 1755.6 | 1392.7 | 1416.1 | 1688.3 | 1401.4 | 1436.6 | 1549.5 | 1389.7 | 1410.1 | 1374.4 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 594.8 | 533.8 | 434.9 | 395.5 | 406.7 | 452.3 | 444.2 | 426.7 | 430.0 | 439.7 | 442.7 | 481.3 |
| សណ្ដែកសៀង (US No.1) - USA (ដុល្លារ/តោន) | 591.4 | 538.4 | 491.8 | 390.4 | 405.7 | 400.6 | 405.4 | 353.3 | 347.8 | 339.7 | 347.3 | 360.7 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 109.5 | 105.9 | 96.2 | 49.6 | 40.7 | 52.6 | 69.5 | 60.5 | 65.1 | 59.7 | 60.3 | 49.1 |
| សាំង - US Gulf Coast (សេនដុល្លារ/លីត្រ) | 74.6 | 71.2 | 65.6 | 41.0 | 35.2 | 42.4 | 49.6 | 40.9 | 49.4 | 46.0 | 43.3 | 34.2 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេនដុល្លារ/លីត្រ) | 80.7 | 78.4 | 71.5 | 41.7 | 34.8 | 42.9 | 53.8 | 49.5 | 51.1 | 48.9 | 49.4 | 39.2 |

Sources: Food and Agriculture Organisation; US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ ឆ្នាំ២០២០ ការអនុម័តវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់សរុប ធ្លាក់ចុះ ៥២,៧% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ត្រឹម ៩១៦,១លានដុល្លារ ដោយសារការអនុម័តវិនិយោគក្នុងវិស័យកសិកម្មមិនមានសោះ ក្នុងវិស័យឧស្សាហកម្មធ្លាក់ចុះ ២០,១% ក្នុងវិស័យសេវាកម្មធ្លាក់ចុះ ៥៨,០%។ ផ្នែកសណ្ឋាគារនិងទេសចរណ៍ បានធ្លាក់ចុះខ្លាំងជាងគេ រហូតដល់ ៩១,៨% ប៉ុន្តែផ្នែកកាត់ដេរសម្លៀកបំពាក់បានកើន ៤៣,៤% ដែលជាលទ្ធផលល្អបំផុតមួយ។ បើធៀបនឹងត្រីមាសមុន ការអនុម័តវិនិយោគក្នុងវិស័យឧស្សាហកម្ម បានធ្លាក់ចុះ ៧៤,៦% និងក្នុងវិស័យសេវាកម្ម បានធ្លាក់ចុះ ៥២,៦%។ ក្នុងគ្រប់វិស័យ គឺមានតែផ្នែកកាត់ដេរសម្លៀកបំពាក់ប៉ុណ្ណោះ ដែលមានកំណើនការអនុម័តវិនិយោគ ធៀបនឹងត្រីមាសមុនៗគិតតាំងពីត្រីមាសទី១ ឆ្នាំ២០១៩ មក។

ធៀបនឹងកាលពីមួយឆ្នាំមុន ភ្ញៀវទេសចរណ៍អន្តរជាតិមកដល់កម្ពុជាបានថយចុះ លើកលែងតែភ្ញៀវមកពីថៃ។ ជាក់ស្តែងភ្ញៀវមកពីចិនថយចុះ ៦២,០% មកពីកូរ៉េខាងត្បូងថយចុះ ៥៦,៤% ពីម៉ាឡេស៊ីថយចុះ ៤៨,៩% ពីសហរដ្ឋអាមេរិក ថយចុះ ៤៥,៩% ពីជប៉ុនថយចុះ ៣៣,៩% ពីបារាំង ថយចុះ ២៩,៦% ពីអង់គ្លេសថយចុះ ២៥,៦% ពីវៀតណាម ថយចុះ ៤,០%។ បើធៀបនឹងត្រីមាសមុន ភ្ញៀវមកពីចិនថយចុះ ៤៧,៧% ពីម៉ាឡេស៊ីថយចុះ ៦១,៥% ពីកូរ៉េខាងត្បូងថយចុះ ៣៨,៨% ពីសហរដ្ឋអាមេរិកថយចុះ ៤០,០% ពីវៀតណាមថយចុះ ៣៣,៩% ពីជប៉ុនថយចុះ ៣១,៦% ពីថៃថយចុះ ១៤,៤% ពីបារាំងថយចុះ ៦,១% ពីអង់គ្លេសថយចុះ ៣,១% ។

ការនាំចេញសរុបកើន ១០,២% ធៀបនឹងកាលពីមួយឆ្នាំមុន ឬកើន ៥,១% ធៀបនឹងត្រីមាសទី២ ឆ្នាំ២០១៩ ឬកើន ០,៧% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩ ប៉ុន្តែធ្លាក់ចុះ ១៦,៧% ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០១៩។ ការនាំចេញសរុបបានកើនឡើងធៀបនឹងកាលពីមួយឆ្នាំមុន ដោយសារការនាំចេញសម្លៀកបំពាក់កើន ៧,៥% គ្រឿងអេឡិចត្រូនិកកើន ៥៧,២% គ្រឿងបង្គុំរថយន្តកើន ២៧,៥% ផលិតផលកសិកម្មកើន ២៥,០%។ បើពិនិត្យពីគោលដៅនាំចេញសម្លៀកបំពាក់ ដោយធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ការនាំចេញទៅសហរដ្ឋអាមេរិកកើន ២៧,៩% ទៅអាស៊ានកើន ៤៣,៣% ប៉ុន្តែការនាំចេញទៅសហភាពអឺរ៉ុបធ្លាក់ចុះ ១,៨% ទៅអង់គ្លេសធ្លាក់ចុះ ១០,១% និងទៅប្រទេសផ្សេងៗទៀតធ្លាក់ចុះ ០,៩%។ បើធៀបនឹងត្រីមាសមុន ការនាំចេញសម្លៀកបំពាក់កើន ៤,៦% គ្រឿងបង្គុំរថយន្តកើន ៧,៩% ប៉ុន្តែការនាំចេញផលិតផលកសិកម្មធ្លាក់ចុះ ៨,៧% គ្រឿងអេឡិចត្រូនិកធ្លាក់ចុះ ២,៨%។ ការនាំចេញផលិតផលកសិកម្មបានធ្លាក់ចុះ ដោយសារជាសំខាន់ការនាំចេញ កៅស៊ូបានធ្លាក់ចុះ ៥៨,០% ឈើធ្លាក់ចុះ ៧,៤% ផលិតផលកសិកម្មផ្សេងទៀត ធ្លាក់ចុះ ១១,៤%។

ការនាំចូលសរុបកើន ១៨,៣% ធៀបនឹងកាលពីមួយឆ្នាំមុន ប៉ុន្តែធ្លាក់ចុះ ១,៤% ធៀបនឹងត្រីមាសមុន។ ធៀបនឹងកាលពីមួយឆ្នាំមុន ការនាំចូល សាំងកើន ៨,៥% ម៉ាស៊ូតកើន ៨,៧% សម្ភារសំណង់កើន ៣,៦% និង ទំនិញផ្សេងៗទៀតកើន ១៩,៨%។ ធៀបនឹងត្រីមាសមុន មានតែការនាំចូលសាំងប៉ុណ្ណោះ ដែលបានកើនឡើង ៧,៨% រីឯការនាំចូល ម៉ាស៊ូតធ្លាក់ចុះ ០,៣% សម្ភារសំណង់ធ្លាក់ចុះ ២១,១% ទំនិញផ្សេងៗទៀតធ្លាក់ចុះ ០,៧%។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ឆ្នាំ២០២០ ចំណូលសរុបរបស់រដ្ឋាភិបាលកើន ៨,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែធ្លាក់ចុះ ២០,០% បើធៀបនឹងត្រីមាសមុន។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ចំណូលចរន្តកើន ៩,០% ចំណូលពន្ធកើន ៣,៨% ចំណូលពន្ធក្នុងស្រុកកើន ៤,៤% ចំណូលពន្ធលើពាណិជ្ជកម្មអន្តរជាតិ កើន ០,២% ចំណូលមិនមែនពន្ធកើន ៥២,៤% ចំណូលលើទ្រព្យសម្បត្តិកើន ៦៣,២% ចំណូលលើការលក់ទំនិញនិងសេវាកើន ៥១,៥% ចំណូលមិនមែនពន្ធផ្សេងទៀតកើន ៥,៥%។ ដោយឡែកចំណូលជាមូលធនបានធ្លាក់ចុះ ៣៤,២%។ បើធៀបនឹងត្រីមាសមុន មានតែចំណូលលើទ្រព្យសម្បត្តិប៉ុណ្ណោះ ដែលបានកើនឡើង ១.១៦៤,៦% រីឯចំណូលប្រភេទផ្សេងទៀតបានធ្លាក់ចុះ ពោលគឺ ចំណូលចរន្តធ្លាក់ចុះ ១៩.៦% ចំណូលពន្ធធ្លាក់ចុះ ២១,៨% ចំណូលពន្ធក្នុងស្រុកធ្លាក់ចុះ ២១,៨% ចំណូលពន្ធលើពាណិជ្ជកម្មអន្តរជាតិធ្លាក់ចុះ ២១,៨% ចំណូលមិនមែនពន្ធធ្លាក់ចុះ ៣,៨% ចំណូលលើការលក់ទំនិញនិងសេវាធ្លាក់ចុះ ៣៣,២% ចំណូលមិនមែនពន្ធផ្សេងទៀតធ្លាក់ចុះ ៥៨,២% ចំណូលជាមូលធនធ្លាក់ចុះ ៦៦,៧%។

ធៀបនឹងកាលពីមួយឆ្នាំមុន ចំណាយសរុបកើន ២៧,៧% ដែលជំរុញឡើងដោយសារ កំណើន ២២,៩% ក្នុងចំណាយជាមូលធន ២៩,៣% ក្នុងចំណាយចរន្ត ១៣,១% ក្នុងចំណាយលើបៀវត្សរ៍ ៧៦,៧% ក្នុងចំណាយលើឧបត្ថម្ភធននិងជំនួយសង្គម ៥២,០% ក្នុងចំណាយចរន្តផ្សេងទៀត។ បើធៀបនឹងត្រីមាសមុន ចំណាយសរុបធ្លាក់ចុះ ៣០,៩% ដោយសារ ការធ្លាក់ចុះ ៦០,០% ក្នុងចំណាយជាមូលធន ៩,៨% ក្នុងចំណាយចរន្ត ២០,៥% ក្នុងចំណាយលើឧបត្ថម្ភធននិងជំនួយសង្គម ២៣,៦% ក្នុងចំណាយចរន្តផ្សេងទៀត។ គួរកត់សំគាល់ថា ចំណាយគ្រប់ប្រភេទបានធ្លាក់ចុះ លើកលែងតែចំណាយលើបៀវត្សរ៍ដែលបានកើនឡើង ៩,៣%។

នៅត្រីមាសទី១ ឆ្នាំ២០២០ សមតុល្យសរុបមានអតិរេក ២៤២,៤ប៊ីលានរៀល ពោលគឺ បានធ្លាក់ចុះ ៧៤,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០២០ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខ (CPI) នៅភ្នំពេញកើនដល់ ៣,០% ធៀបនឹង ២,០% នៅពីរត្រីមាសមុន។ ដោយឡែក សន្ទស្សន៍ថ្លៃស្បៀងអាហារនិងភេសជ្ជៈមិនមែនស្រា កើនដល់ ៣,៧% ហើយសន្ទស្សន៍ថ្លៃដឹកជញ្ជូន កើនដល់ ២,៦%។

ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប្រាក់រៀលចុះថ្លៃ ១,៤% ទល់នឹងប្រាក់ដុល្លារ ដល់ ៤.០៦៤,១រៀល/ដុល្លារ ចុះថ្លៃ ២,៦% ទល់នឹង

---

អត្ថបទនេះ រៀបរៀងដោយ រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និង ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

ប្រាក់បាតថៃ ដល់ ១៣០,៧រៀល/បាត និងចុះថ្លៃ ១,១% ទល់នឹងប្រាក់ដុងវៀតណាម ដល់ ១៧,៦រៀល/១០០ដុង។ បើធៀបនឹងត្រីមាសមុន ប្រាក់រៀលចុះថ្លៃ ០,០១% ទល់នឹងប្រាក់ដុល្លារ ប៉ុន្តែឡើងថ្លៃ ៣,១% ទល់នឹងប្រាក់បាតថៃ និងមានស្ថិរភាពទល់នឹងប្រាក់ដុងវៀតណាម។

មាសឡើងថ្លៃ ២០,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ដល់ ១៨៨,៣ដុល្លារ/ជី និងឡើងថ្លៃ ៥,៧% ធៀបនឹងត្រីមាសមុន។ ម៉ាស៊ូតចុះថ្លៃ ២,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និងចុះថ្លៃ ៤,៥% ធៀបនឹងត្រីមាសមុន។ សាំងឡើងថ្លៃ ៣,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែចុះថ្លៃ ៤,០% ធៀបនឹងត្រីមាសមុន។

## ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

ផ្នែកនេះ ពិពណ៌នាពីស្ថានភាពរបស់ពលករងាយរងគ្រោះ ដោយផ្អែកតាមអង្កេតនៅខែឧសភា ២០២០ លើកម្មកររោងចក្រកាត់ដេរ ១២០នាក់ និងពលករងាយរងគ្រោះ ៩ប្រភេទទៀត ចំនួន ៣៦០នាក់។ ជារួម ធៀបនឹងកាលពីមួយឆ្នាំមុន ប្រាក់ចំណូលប្រចាំថ្ងៃ បានកើនឡើងសម្រាប់ពលករប្រាំប្រភេទ (អ្នកលីសែង អ្នករត់តុភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករសំណង់គ្មានជំនាញ និង កម្មករសំណង់មានជំនាញ) និងបានថយចុះ សម្រាប់ពលករប្រាំប្រភេទទៀត (អ្នករត់ស៊ីក្លូ អ្នកលក់បន្លែតូចតាច អ្នករើសអេតចាយ កម្មកររោងចក្រកាត់ដេរ អ្នករត់ម៉ូតូឌុប)។ ធៀបនឹងអង្កេតនៅខែកុម្ភៈ ២០២០ (គឺកាលពីបីខែមុន) ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែងកើន ៣,១% អ្នករត់តុភោជនីយដ្ឋានកើន ០,៩% អ្នកស៊ីឈ្នួលធ្វើស្រែកើន ១១,៤% កម្មករសំណង់គ្មានជំនាញកើន ៩,៧% កម្មករសំណង់មានជំនាញកើន ៨,២% ប៉ុន្តែប្រាក់ចំណូលប្រចាំថ្ងៃរបស់ អ្នករត់ស៊ីក្លូថយចុះ ១៤,១% អ្នកលក់បន្លែតូចតាចចុះ ៦,០% អ្នករើសអេតចាយចុះ ៣៤,៤% កម្មកររោងចក្រកាត់ដេរចុះ ១២,៥% អ្នករត់ម៉ូតូឌុបចុះ ១១,៩%។

សម្រាប់ពលករងាយរងគ្រោះ ៩ប្រភេទ មានសរុប ៣៦០នាក់ (ពោលគឺ ក្រៅពីកម្មកររោងចក្រកាត់ដេរ) ភាគច្រើន (៨៦,៤%) មកពីគ្រួសារមានសមាជិកពី ៤ ដល់ ៦នាក់ ហើយភាគច្រើនដែរ (៨៦,៤%) រាយការណ៍ថា គាត់ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ និងមាន ៦៨,៣% ធ្វើចំណាកស្រុកតែម្នាក់ឯងមកក្រុងភ្នំពេញ ឬសៀមរាប។ ម្យ៉ាងទៀត មានពលករជិតពាក់កណ្ដាល (៤៤,៧%) គាត់គ្មានការងារអ្វីផ្សេងទៀតទេ និងមាន ៤៩,៧% មានធ្វើការងារដាំដុះនិងចិញ្ចឹមសត្វ សម្រាប់ការហូបចុកក្នុងគ្រួសារ។ តបនឹងសំណួរថា តើប្រាក់ចំណូលរបស់អ្នកអាចផ្គត់ផ្គង់គ្រួសារបានឬទេ? មានពលករ ៨២,៨% ឆ្លើយថា បានមួយភាគ ពលករ ១៦,៤% ឆ្លើយថា មិនបានទេ និង ០,៩% ឆ្លើយថា ផ្គត់ផ្គង់បាន។ ពលករងាយរងគ្រោះភាគច្រើនណាស់ (៩១,៩%) បានប្រាប់ថា គាត់មិនអាចសន្សំប្រាក់ចំណូល សម្រាប់ទប់ទល់បញ្ហាចោទលើការងារគាត់ទៅអនាគតបានទេ។ ចំណូលរបស់គាត់ ត្រូវយកទៅចំណាយជាសំខាន់លើស្បៀងអាហារ (៧៧,៥%) កន្លែងស្នាក់នៅ (៩,៥%) ការដឹកជញ្ជូន (១,៧%) ការថែទាំសុខភាព (០,៥%) និង ចំណាយផ្សេងទៀត (១០,៨%)។

សម្រាប់កម្មករកាត់ដេរវិញ គ្រប់គ្នារាយការណ៍ថា ត្រូវធ្វើការ ៦ថ្ងៃ/សប្ដាហ៍។ តបនឹងសំណួរថា តើប្រាក់ចំណូលរបស់អ្នកអាចផ្គត់ផ្គង់គ្រួសារបានឬទេ? កម្មករភាគច្រើន (៨៣,៣% ឆ្លើយថា បានមួយភាគ កម្មករ ១០,៨% ឆ្លើយថា មិនបានទេ និង ៥,៨% ឆ្លើយថា ផ្គត់ផ្គង់បាន។ ចំណូលរបស់គាត់ត្រូវយកទៅចំណាយជាសំខាន់លើស្បៀងអាហារ (៦៩,៧%) កន្លែងស្នាក់នៅ (១៨,៣%) ការថែទាំសុខភាព (០,៣%) និងចំណាយផ្សេងទៀត (១១,៧%)។

តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១២-២០

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 531.6 | 930.5 | 56.5 | 169.8 | 117.1 | 62.9 | 214.9 | 17.2 | 48.2 | 1.9 | 27.5 | 0.0 |
| ឧស្សាហកម្ម | 829.3 | 3257.0 | 1002.5 | 1014.7 | 1436.4 | 982.2 | 1186.2 | 292.9 | 113.7 | 302.0 | 919.9 | 234.0 |
| *. សម្លៀកបំពាក់* | 497.0 | 324.1 | 393.5 | 225.2 | 380.7 | 211.1 | 187.3 | 73.9 | 34.4 | 47.3 | 74.1 | 106.0 |
| សេវាកម្ម | 916.6 | 140.7 | 622.6 | 2734.4 | 1664.3 | 3858.6 | 4351.8 | 1625.6 | 2518.2 | 849.7 | 1440.4 | 682.1 |
| *. សណ្ឋាគារ និងទេសចរណ៍* | 691.5 | 106.0 | 446.9 | 98.6 | 1366.9 | 2759.6 | 1584.0 | 1618.8 | 2518.2 | 808.7 | 1703.8 | 133.0 |
| សរុប | 2278.0 | 4328.0 | 1583.9 | 3918.9 | 3217.7 | 4903.7 | 5752.9 | 1935.6 | 2680.1 | 1153.5 | 2387.8 | 916.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | | 4.9 | 38.5 | -57.0 | 107.0 | -61.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 90.1 | 63.4 | -63.4 | 147.4 | -17.9 | 52.4 | 17.3 | 312.5 | 12.6 | 8.9 | 29.4 | -52.7 |

Note: Including expansion project approvals. Source: Cambodian Investment Board

តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ ផ្ទះ និងផ្ទះល្វែង | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 227.3 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | - |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១២-២០

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| ចិន | 333.9 | 463.1 | 560.3 | 694.7 | 830.0 | 1210.8 | 2024.4 | 683.4 | 609.1 | 572.5 | 496.9 | 259.7 |
| វៀតណាម | 763.1 | 854.1 | 905.8 | 987.8 | 959.7 | 835.4 | 800.1 | 186.9 | 214.8 | 235.7 | 271.5 | 179.5 |
| កូរ៉េខាងត្បូង | 411.5 | 435.0 | 424.4 | 395.3 | 357.2 | 345.0 | 301.8 | 95.7 | 43.6 | 47.4 | 68.1 | 41.7 |
| ថៃ | 201.4 | 221.3 | 279.5 | 349.9 | 398.1 | 394.9 | 382.3 | 97.9 | 76.3 | 113.9 | 178.4 | 152.7 |
| សហរដ្ឋអាមេរិក | 173.1 | 185.0 | 191.4 | 217.5 | 238.7 | 256.5 | 250.8 | 79.0 | 53.2 | 45.5 | 71.2 | 42.7 |
| ជប៉ុន | 179.3 | 206.9 | 215.8 | 193.3 | 191.6 | 203.4 | 210.5 | 60.2 | 40.4 | 48.9 | 58.2 | 39.8 |
| បារាំង | 121.2 | 131.5 | 141.1 | 145.7 | 150.3 | 166.4 | 170.8 | 59.4 | 27.3 | 32.9 | 44.5 | 41.8 |
| ចក្រភពអង់គ្លេស | 110.2 | 123.9 | 133.3 | 154.3 | 159.5 | 171.2 | 162.4 | 59.4 | 29.7 | 28.5 | 45.6 | 44.2 |
| ម៉ាឡេស៊ី | 116.8 | 130.7 | 144.4 | 149.4 | 152.8 | 179.3 | 201.1 | 48.7 | 43.2 | 46.5 | 64.6 | 24.9 |
| តាមផ្លូវអាកាស | 1722.1 | 2017.7 | 2273.5 | 2476.0 | 2778.0 | 3312.7 | 6405.6 | 1299.1 | 1054.8 | 1039.9 | 1010.2 | 663.6 |
| តាមផ្លូវគោក និងទឹក | 1862.2 | 2192.5 | 2229.3 | 2299.2 | 2331.4 | 2289.4 | 3242.2 | 578.7 | 405.8 | 436.0 | 786.1 | 491.6 |
| សរុប | 3584.3 | 4210.2 | 4502.8 | 4775.2 | 4980.4 | 5602.2 | 9647.7 | 1877.9 | 1460.6 | 1475.8 | 1796.3 | 1155.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 2.9 | -22.2 | 1.0 | 21.7 | -35.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 24.4 | 17.5 | 7.0 | 6.1 | 4.3 | 12.5 | 72.2 | 9.7 | 13.2 | 7.4 | -1.6 | -38.5 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០១២-២០ *

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 4929.5 | 6106.4 | 8106.0 | 9256.4 | 10043.3 | 10772.9 | 12783.8 | 3222.7 | 3379.0 | 4263.9 | 3524.9 | 3550.1 |
| សម្លៀកបំពាក់ | 4259.6 | 5015.4 | 5960.5 | 6827.0 | 7308.0 | 8020.3 | 9506.0 | 2463.4 | 2526.3 | 3143.8 | 2530.9 | 2647.2 |
| *- សហរដ្ឋអាមេរិក* | 2055.3 | 2143.3 | 1963.6 | 2009.4 | 1831.5 | 1923.8 | 2483.2 | 739.8 | 802.9 | 1006.5 | 848.0 | 945.9 |
| *- សហភាពអឺរ៉ុប* | 1322.2 | 1716.9 | 2403.7 | 2903.9 | 2928.7 | 2782.2 | 3155.3 | 719.2 | 801.1 | 965.4 | 716.2 | 706.3 |
| *- អាស៊ាន* | 17.6 | 39.4 | 83.3 | 103.4 | 98.4 | 106.9 | 135.3 | 38.1 | 41.3 | 48.2 | 53.1 | 54.6 |
| *- ជប៉ុន* | 147.0 | 188.6 | 383.1 | 524.2 | 655.5 | 701.2 | 890.8 | 262.9 | 175.8 | 291.2 | 236.8 | 262.9 |
| *- ចក្រភពអង់គ្លេស* | | | - | - | 439.8 | 904.0 | 1007.0 | 211.5 | 197.7 | 272.9 | 200.3 | 190.2 |
| *- ប្រទេសផ្សេងៗ* | 717.5 | 927.2 | 1126.8 | 1286.3 | 1354.2 | 1602.2 | 1834.3 | 491.7 | 507.5 | 559.7 | 476.4 | 487.3 |
| គ្រឿងអេឡិចត្រូនិក | - | - | - | - | - | 380.0 | 328.7 | 71.9 | 123.8 | 142.3 | 116.3 | 113.0 |
| គ្រឿងបង្គុំរថយន្ត | - | - | - | - | - | 11.6 | 94.4 | 20.4 | 18.2 | 22.7 | 24.1 | 26.0 |
| កសិកម្ម | 362.1 | 376.7 | 624.4 | 548.8 | 534.1 | 706.4 | 850.9 | 210.4 | 177.7 | 211.0 | 288.1 | 262.9 |
| *- កៅស៊ូ* | 197.6 | 176.6 | 153.9 | 165.4 | 165.3 | 273.5 | 217.6 | 43.8 | 42.2 | 60.0 | 73.3 | 30.8 |
| *- ឈើ* | 48.8 | 36.8 | 132.0 | 46.3 | 47.2 | 100.5 | 142.3 | 22.2 | 35.2 | 42.4 | 47.5 | 44.0 |
| *- ត្រី* | 3.1 | 2.0 | 0.8 | 0.5 | 0.6 | 0.6 | 1.3 | 0.1 | 0.1 | 0.1 | 0.1 | 0.1 |
| *- អង្ករ* | 106.6 | 146.4 | 248.5 | 315.3 | 300.8 | 255.1 | 413.6 | 122.4 | 72.2 | 84.5 | 140.2 | 145.9 |
| *- ផលិតផលកសិកម្មផ្សេងៗ* | 6.0 | 14.9 | 89.1 | 21.3 | 20.2 | 76.7 | 76.2 | 21.9 | 28.1 | 24.1 | 26.9 | 42.2 |
| ផ្សេងៗ | 307.9 | 714.4 | 1520.1 | 1880.2 | 2201.2 | 1654.7 | 2003.8 | 456.6 | 532.9 | 744.0 | 565.6 | 501.0 |
| ការនាំចូលសរុប | 8593.3 | 8639.4 | 10295.4 | 11494.5 | 15013.4 | 16815.4 | 16904.7 | 4437.7 | 5328.6 | 5091.4 | 5324.3 | 5250.9 |
| សាំង | 308.0 | 306.4 | 334.7 | 377.3 | 384.8 | 256.7 | 320.5 | 121.1 | 117.1 | 118.6 | 121.9 | 131.4 |
| ម៉ាស៊ូត | 559.5 | 569.1 | 602.3 | 607.8 | 709.1 | 472.9 | 594.1 | 228.2 | 250.2 | 166.4 | 248.9 | 248.1 |
| សម្ភារសំណង់ | 66.1 | 80.8 | 117.6 | 164.4 | 253.2 | 304.3 | 564.5 | 170.8 | 231.4 | 271.2 | 224.4 | 177.0 |
| ផ្សេងៗ | 7659.1 | 7682.6 | 9240.7 | 10345.1 | 13666.3 | 15781.6 | 15425.7 | 3917.7 | 4729.9 | 4535.2 | 4729.1 | 4694.4 |
| ជញ្ជីងពាណិជ្ជកម្ម | -1341.6 | -1610.9 | -2184.3 | -2238.1 | -4970.0 | -5974.1 | -4120.9 | -1215.0 | -1990.6 | -827.5 | -1799.4 | -1700.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | - | 7.0 | 2.6 | 24.4 | -19.5 | 4.6 |
| ការនាំចេញសរុប | - | - | - | - | - | - | - | 2.8 | 7.8 | 26.2 | -17.3 | 0.7 |
| ការនាំចូលសរុប | - | - | - | - | - | - | - | 6.0 | 27.2 | -4.5 | 4.6 | -1.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 17.7 | 7.4 | 10.7 | 14.5 | 7.0 | 9.7 | 18.5 | 17.7 | 12.8 | 9.5 | 9.9 | 7.5 |
| ការនាំចេញសរុប | 23.9 | 14.3 | 16.1 | 14.2 | 8.5 | 7.9 | 17.9 | 13.7 | 12.6 | 11.8 | 12.4 | 10.2 |
| ការនាំចូលសរុប | 16.8 | 15.4 | 19.7 | 11.7 | 30.6 | 12.0 | 0.5 | 4.6 | 18.5 | 28.0 | 27.1 | 18.3 |

Note: Import data include tax-exempt imports.

Sources: Department of Trade Preference Systems, Ministry of Commerce; Customs and Excise Department, Ministry of Economy and Finance website

តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១២-២០ (ប៊ីលានរៀល)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ចំណូលសរុប | 7691.9 | 8255.2 | 10543.4 | 11879.9 | 14201.5 | 16582.0 | 19743.1 | 5097.5 | 6357.1 | 6364.5 | 6930.3 | 5544.2 |
| ចំណូលចរន្ត | 7443.8 | 8233.2 | 10359.4 | 11759.0 | 14088.7 | 16481.4 | 19549.0 | 5066.8 | 6322.2 | 6309.2 | 6869.7 | 5524.0 |
| ចំណូលពន្ធ | 6334.8 | 7198.1 | 8995.2 | 10502.4 | 12196.5 | 14314.3 | 17019.2 | 4524.3 | 5663.5 | 5415.1 | 6009.8 | 4697.1 |
| ពន្ធក្នុងស្រុក | 5002.8 | 5728.1 | 7226.5 | 8591.7 | 10185.8 | 12338.7 | 14648.3 | 3904.9 | 4944.9 | 4634.1 | 5215.9 | 4076.5 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1331.7 | 1470.0 | 1822.7 | 1910.7 | 2010.7 | 1875.6 | 2370.9 | 619.4 | 718.6 | 781.0 | 793.9 | 620.6 |
| ចំណូលមិនមែនពន្ធ | 1118.2 | 1035.2 | 1310.3 | 1256.6 | 1892.2 | 2167.2 | 2520.9 | 542.5 | 658.7 | 894.1 | 859.9 | 826.9 |
| ចំណូលលើទ្រព្យសម្បត្តិ | 143.0 | 84.0 | 88.5 | 77.3 | 116.0 | 127.2 | 197.3 | 177.4 | 34.0 | 30.2 | 22.9 | 289.6 |
| លក់ទំនិញ និងសេវា | 667.4 | 750.3 | 871.2 | 1047.1 | 1248.3 | 1517.0 | 2075.6 | 330.7 | 531.2 | 798.5 | 750.0 | 500.9 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 298.8 | 200.8 | 350.5 | 132.2 | 528.0 | 523.1 | 253.9 | 34.5 | 93.5 | 65.5 | 87.1 | 36.4 |
| ចំណូលជាមូលធន | 247.9 | 73.4 | 184.0 | 121.0 | 113.4 | 100.5 | 194.1 | 30.7 | 35.0 | 55.4 | 60.7 | 20.2 |
| ចំណាយសរុប | 9660.9 | 12535.7 | 13306.5 | 13849.5 | 13775.4 | 17251.0 | 19027.1 | 4150.4 | 4997.6 | 5386.5 | 7676.8 | 5301.7 |
| ចំណាយជាមូលធន | 3628.3 | 5567.5 | 5590.7 | 5290.3 | 3785.3 | 5207.2 | 5730.2 | 1025.0 | 1392.7 | 1358.6 | 3195.4 | 1259.3 |
| ចំណាយចរន្ត | 6188.4 | 6968.3 | 7715.8 | 8544.6 | 9990.1 | 12043.7 | 13297.0 | 3125.4 | 3604.9 | 4027.9 | 4481.3 | 4042.5 |
| បៀវត្សរ៍ | 2486.6 | 2997.3 | 3755.5 | 4271.9 | 5381.7 | 6647.4 | 7558.4 | 1820.2 | 1911.1 | 2102.0 | 1883.3 | 2058.0 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1586.8 | 1563.0 | 1627.0 | 1742.9 | 1774.9 | 2314.8 | 2505.4 | 729.2 | 1061.9 | 855.5 | 1620.3 | 1288.2 |
| ចំណាយចរន្តផ្សេងទៀត | 2115.1 | 2408.0 | 2333.4 | 2529.8 | 2833.5 | 5394.3 | 5738.6 | 1305.2 | 1693.8 | 1925.8 | 2598.1 | 1984.4 |
| សមតុល្យជាទូទៅ | -9.0 | -160.8 | -2763.1 | -1969.6 | 426.1 | -669.1 | -205.4 | 947.1 | 1359.6 | 978.0 | -746.4 | 242.4 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | -1969.0 | -4280.6 | 3972.1 | 3729.4 | 1878.9 | 3358.1 | 716.1 | 652.8 | 895.5 | 608.8 | 1383.3 | 369.5 |
| ហិរញ្ញប្បទានក្នុងស្រុក | 2457.8 | 4326.2 | -1428.7 | -2034.9 | -1858.7 | -2454.1 | 2513.5 | -44.4 | -7.6 | 11.9 | -18.0 | 3.2 |

Source: Ministry of Economy and Finance website

តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១២-២០

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 2.3 | 3.0 | 3.9 | 1.2 | 3.1 | 2.9 | 2.5 | 1.9 | 1.8 | 2.0 | 2.0 | 3.0 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 2.5 | 3.9 | 4.9 | 4.0 | 5.6 | 3.4 | 2.5 | 2.1 | 1.6 | 2.2 | 2.4 | 3.7 |
| - ដឹកជញ្ជូន | 3.3 | -0.6 | -1.0 | -9.2 | -6.9 | 4.1 | 2.9 | -3.8 | -1.5 | -2.5 | -1.4 | 2.6 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4039.2 | 4037.3 | 4036.2 | 4060.4 | 4053.7 | 4047.5 | 4045.0 | 4006.6 | 4052.1 | 4086.8 | 4063.7 | 4064.1 |
| រៀលក្នុង ១ បាតថៃ | 130.0 | 133.1 | 124.9 | 119.4 | 115.5 | 120.0 | 125.9 | 127.4 | 128.9 | 133.7 | 134.9 | 130.7 |
| រៀលក្នុង ១០០ ដុងវៀតណាម | 19.4 | 19.3 | 19.1 | 18.7 | 18.2 | 17.9 | 17.7 | 17.4 | 17.5 | 17.7 | 17.6 | 17.6 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 200.9 | 175.9 | 152.3 | 140.6 | 151.2 | 151.5 | 152.8 | 156.6 | 157.1 | 175.7 | 178.1 | 188.3 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 4941.2 | 5019.0 | 4852.1 | 3771.3 | 3004.0 | 3385.8 | 3808.7 | 3413.9 | 3595.4 | 3499.7 | 3499.5 | 3343.5 |
| ថ្លៃសាំង (រៀល/លីត្រ) | 5312.7 | 5264.2 | 5083.3 | 3951.7 | 3336.8 | 3716.0 | 3982.5 | 3405.7 | 3770.2 | 3629.3 | 3685.9 | 3538.8 |

Sources: NIS, NBC; CDRI

តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១២-២០ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 18154.5 | 21260.1 | 26699.7 | 26665.5 | 31814.5 | 42575.3 | 55214.3 | 55214.3 | 58148.8 | 62699.5 | 67081.5 | 57001.8 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 10437.4 | 11508.3 | 15859.8 | 22157.6 | 25802.3 | 28743.5 | 33228.9 | 33228.9 | 33997.2 | 33548.0 | 34814.3 | 62221.0 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2486.4 | -2794.9 | -4359.1 | -6428.8 | -8148.5 | -11066.5 | -14803.7 | -14803.7 | -17381.0 | -18747.4 | -20263.2 | -24650.6 |
| ឥណទានដល់វិស័យឯកជន | 23536.6 | 27608.8 | 36244.6 | 46071 | 56458.8 | 66922.6 | 82419.3 | 82419.3 | 86574.4 | 91568.6 | 98320.3 | 131815.3 |
| រូបិយវត្ថុទូទៅ | 28591.9 | 32768.4 | 42559.5 | 48823.1 | 57616.6 | 71318.9 | 88443.2 | 88443.2 | 92146.0 | 96247.6 | 101895.8 | 11922.8 |
| រូបិយវត្ថុ | 4045.7 | 4878.2 | 6308.4 | 6741.4 | 7273.0 | 9428.4 | 10226.8 | 10226.8 | 10782.0 | 11274.5 | 13465.9 | 96047.6 |
| រូបិយវត្ថុផ្សេងៗ | 18154.5 | 21260.1 | 26699.7 | 42081.7 | 50343.8 | 61890.4 | 78216.4 | 78216.4 | 81364.0 | 84973.0 | 88429.9 | 7976.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ | 20.9 | 14.6 | 29.9 | 14.7 | 18.0 | 23.8 | 24.0 | 24.0 | 22.6 | 21.3 | 20.4 | - |
| រូបិយវត្ថុ | 2.3 | 20.6 | 29.3 | 6.9 | 7.9 | 29.6 | 8.5 | 8.5 | 12.6 | 18.0 | 32.7 | - |
| រូបិយវត្ថុផ្សេងៗ | 44.6 | 13.6 | 30.0 | 16.1 | 19.6 | 22.9 | 26.4 | 26.4 | 24.1 | 21.7 | 18.8 | - |

Source: National Bank of Cambodia

តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2016 | 2017 | 2018 | 2019 | | | | 2020 | | 2019 | 2020 | |
| | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នករត់ស៊ីក្លូ | 11516 | 10793 | 10793 | 11764 | 10567 | 11114 | 12046 | 10997 | 9081 | 14.7 | -6.5 | -14.1 |
| អ្នកលីសែង | 14318 | 14942 | 14942 | 15882 | 17323 | 16560 | 18802 | 18246 | 17856 | 21.7 | 14.9 | 3.1 |
| អ្នកលក់បន្លែតូចតាច | 17177 | 17015 | 17015 | 18912 | 21472 | 19197 | 18651 | 15207 | 20181 | -11.3 | -19.6 | -6.0 |
| អ្នករើសអេតចាយ | 10299 | 11591 | 11591 | 12941 | 12685 | 13123 | 13099 | 14759 | 8322 | 4.2 | 14 | -34.4 |
| អ្នករត់តុភោជនីយដ្ឋាន* | 20008 | 22901 | 22901 | 8299 | 8348 | 8564 | 8724 | 8706 | 8420 | 4.5 | 4.9 | 0.9 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 17365 | 17341 | 17341 | 8209 | 7909 | 9180 | 9376 | 9154 | 8812 | 4.4 | 11.5 | 11.4 |
| កម្មកររោងចក្រកាត់ដេរ | 14509 | 14231 | 14231 | 16073 | 15166 | 16076 | 16578 | 16483 | 13271 | 5.1 | 2.6 | -12.5 |
| អ្នករត់ម៉ូតូឌុប | 7989 | 8093 | 8093 | 14705 | 15104 | 14219 | 14904 | 17748 | 9081 | 1.8 | 20.7 | -11.9 |
| កម្មករសំណង់គ្មានជំនាញ | 8088 | 8055 | 8055 | 19820 | 17987 | 18322 | 18814 | 22916 | 19741 | -0.5 | 15.6 | 9.7 |
| កម្មករសំណង់មានជំនាញ | 13688 | 14093 | 14093 | 26265 | 24743 | 25235 | 27225 | 27164 | 26778 | 2.4 | 3.4 | 8.2 |

Notes: * Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. November 2015 data are not available. **Not available. Source: CDRI

*តពីទំព័រ ១០* **ការចុះកម្មសិក្សា...**


Feldman, Daniel C., and David C. Thomas. 1992. "Career Management Issues Facing Expatriates." *Journal of International Business Studies* 23 (2): 271–293.

Heng, Kawai, Phui Jean Ch'ng, Wen Rong Hung, Xui Chi Ooi and Chien Yin Soh. 2011. "Internship Satisfaction: A Preliminary Study on Undergraduates from the Faculty of Business and Finance of Universiti Tunku Abdul Rahman." Final year project, Universiti Tunku Abdul Rahman, Malaysia.

Henze, Brent R. 2006. "The Research-Experiential Internship in Professional Communication." *Technical Communication* 53 (3): 339–347.

IIE (Institute of International Education). 2019. "Project Atlas: Higher Education Students Study Abroad." www.iie.org/Research-and-Insights/Project-Atlas/Explore-Data/Current-Infographics.

Jiani, M. A. 2016. "Why and How International Students Choose Mainland China as a Higher Education Study Abroad Destination." *Higher Education.* doi.org/10.1007/s10734-016-0066-0.

Knight, Jane. 2008. *Higher Education in Turmoil: The Changing World of Internationalisation.* Global Perspectives on Higher Education Vol. 13. Rotterdam: Sense Publishers.

Knight, Jane, ed. 2014. *International Education Hubs: Student, Talent, Knowledge-Innovation Models*. New York: Springer.

Louis, Meryl R., Barry Z. Posner and Gary N. Powell. 1983. "The Availability and Helpfulness of Socialization Practices." *Personnel Psychology* 36 (4): 857–866.

OECD (Organisation for Economic Co-operation and Development). 2017. *Education at a Glance 2017 - OECD Indicators.* Paris: OECD Publishing. www.oecd.org/education/ education-at-a-glance-19991487.htm.

Rothman, Miriam. 2003. "Internships: Most and Least Favored Aspects among a Business School Sample." *Psychological Reports* 93 (3): 921–924.

Taylor, Susan M. 1985. "The Roles of Occupational Knowledge and Vocational Self-Concept Crystallization in Students' School-to-Work Transition." *Journal of Counseling Psychology* 32 (4): 539.

Taylor, Susan M. 1988. "Effects of College Internships on Individual Participants." *Journal of Applied Psychology* 73 (3): 393.

*តពីទំព័រ ៥* **កត្តារាំង...**

*Gender. Research Finding 2019.* CDRI *(unpublished, due in May 2021)*

Khim, Phearum & Chin, Samphors. (2016). *Climate-Proofing Integration Rural Community Development.* Ministry of Rural Development. Phnom Penh, Cambodia

Khoday, Kishan ; Ali, W. (n.d.). Climate Change and the Rise of Poverty | UNDP. Retrieved September 23, 2020, from https://www.undp.org/content/undp/en/home/blog/2018/Climate_Change_and_the_Rise_of_Poverty.html

Nang, P., & Chhuong, O. (2014). *Gender and Water Governance: Women's Role in Irrigation Management and Development in the Context of Climate Change.* CDRI Working Paper Series No. 89

National Institute of Statistics (NIS). (2010). 2008 *census map layers and databases.* Phnom Penh: National Institute of Statistics.

NCDM. (2020). Cambodia Disaster Damage & Loss Information System: Kampong Thom Province. Retrieved August 3, 2020, from http://camdi.ncdm.gov.kh/DesInventar/profiletab.jsp

NIS. (2018). *Commune database 2018.* Phnom Penh, Cambodia.

NIS (Nation Institute of Statistics of the Ministry of Planning). (2019). *General Population Census of the Kingdom of Cambodia 2019: Provisional Population Totals.*

Nyahunda, L., & Tirivangasi, H. M. (2019). Challenges faced by rural people in mitigating the effects of climate change in the Mazungunye communal lands, Zimbabwe. *Jàmbá Journal of Disaster Risk Studies, 11*(1), 1–9. https://doi.org/10.4102/jamba.v11i1.596

Anshory Yusuf, A., & Francisco, H. (2009). *Climate Change Vulnerability Mapping for Southeast Asia.* Economy and Environment Program for Southeast Asia (EEPSEA). Singapore. http://www.eepsea.org

CDRI, MRD, UNDP (2019). *Impact of Climate Change Programs in Cambodia: Vulnerability, Poverty, and Gender. Research Finding 2019. CDRI (unpublished, due in May 2021)*

Khim, Phearum & Chin, Samphors. (2016). *Climate-Proofing Integration Rural Community Development.* Ministry of Rural Development. Phnom Penh, Cambodia

Khoday, Kishan ; Ali, W. (n.d.). Climate Change and the Rise of Poverty | UNDP. Retrieved September 23, 2020, from https://www.undp.org/content/undp/en/home/blog/2018/Climate_Change_and_the_Rise_of_Poverty.html

Nang, P., & Chhuong, O. (2014). *Gender and Water Governance: Women's Role in Irrigation Management and Development in the Context of Climate Change.* CDRI Working Paper Series No. 89

National Institute of Statistics (NIS). (2010). 2008 *census map layers and databases.* Phnom Penh: National Institute of Statistics.

NCDM. (2020). Cambodia Disaster Damage & Loss Information System: Kampong Thom Province. Retrieved August 3, 2020, from http://camdi.ncdm.gov.kh/DesInventar/profiletab.jsp

NIS. (2018). *Commune database 2018.* Phnom Penh, Cambodia.

NIS (Nation Insitute of Statistics of the Ministry of Planning). (2019). *General Population Census of the Kingdom of Cambodia 2019: Provisional Population Totals.*

Nyahunda, L., & Tirivangasi, H. M. (2019). Challenges faced by rural people in mitigating the effects of climate change in the Mazungunye communal lands, Zimbabwe. *Jàmbá Journal of Disaster Risk Studies,* 11(1), 1–9. https://doi.org/10.4102/jamba.v11i1.596

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ...**

អ្នកគ្រប់គ្រងមួយចំនួននៃ AGID និង នាយកនិងបុគ្គលិកជាច្រើននៃ CDRI ក៏បានចូលរួមក្នុងពិធីចុះហត្ថលេខានេះដែរ។

នាឱកាសនោះ លោក ចាន់ សុភក្តិ បានចែករំលែកបទពិសោធន៍បានពីគម្រោងការរបស់ AGID លើការធ្វើកសិកម្មតាមកិច្ចសន្យាការនាំចេញផ្លែស្វាយទៅជប៉ុន គំនិតផ្តួចផ្តើមធ្វើយន្តកម្មកសិកម្ម និងនវានុវត្តន៍ក្នុងអាជីវកម្មផ្នែកកសិកម្ម។

**ជំនួបជាមួយ គណៈកម្មាធិការសម្រាប់លើកកម្ពស់ផលិតភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

នៅថ្ងៃទី១៨ ឧសភា CDRI បានទទួលស្វាគមន៍ គណៈប្រតិភូមួយរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការផលិតភាពជាតិ ដែលដឹកនាំដោយ ឯ.ឧ ស៊ីសុវត្ថិ ដួង ចាន់តូ ជាអគ្គលេខាធិការ។ CDRI មានកត្តិយសដោយបានចូលរួមក្នុងវេទិកាដ៏សំខាន់នេះ ដើម្បីជួយជំរុញកំណើនផលិតភាពនៅកម្ពុជា គុណភាពអភិបាលកិច្ច សមត្ថភាពធនធានមនុស្ស (ចំណេះដឹង ជំនាញ ឥរិយាបទ) នវានុវត្តន៍ និងការអភិវឌ្ឍបច្ចេកវិទ្យា។ ដោយសារ CDRI មានឋានៈជា វិទ្យាស្ថានស្រាវជ្រាវ ផ្នែកគោលនយោបាយអភិវឌ្ឍឯករាជ្យ និងឈានមុខគេនៅកម្ពុជា ឯ.ឧ អគ្គលេខាធិការ បានលើកមតិថា CDRI និង គណៈកម្មាធិការជាតិសម្រាប់សេដ្ឋកិច្ចមានផលិតភាពនៅកម្ពុជា (NCCPE) គួររួមសហការគ្នាឲ្យបានច្រើន ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមានផលិតភាពនៅកម្ពុជា។ នាយកប្រតិបត្តិនៃ CDRI បានទទួលស្វាគមន៍មតិនេះ ហើយត្រៀមចូលរួមសហការឲ្យមានផ្លែផ្កា។

**ទស្សនកិច្ចរបស់ ឯ.ឧ ទាន សំណាង ប្រធានវិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

នៅថ្ងៃទី២១ ឧសភា ឯ.ឧ ទាន សំណាង ប្រធានវិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ (NIDIR) បានជួបជាមួយតំណាងវិទ្យាស្ថាន CDRI រួមមាន នាយកប្រតិបត្តិ នាយកស្រាវជ្រាវ នាយកមជ្ឈមណ្ឌលសម្រាប់ធនធានធម្មជាតិនិងបរិស្ថាន និង នាយកមជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយកសិកម្ម និងអភិវឌ្ឍន៍ជនបទ ដើម្បីពិភាក្សា និងពង្រឹងសហប្រតិបត្តិការរវាងវិទ្យាស្ថានទាំងពីរ។ គណៈប្រតិភូ NIDIR រួមមាន លោក ចាន់ ប៊ុណ្ណារិទ្ធិ ប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និង បណ្ឌិត ផុន សុខបញ្ញា ជាជំនួយការ។

**ឯ.ឧ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជួបជាមួយ ថ្នាក់ដឹកនាំ និងអ្នកស្រាវជ្រាវ CDRI**

នៅថ្ងៃទី២៦ ឧសភា ឯ.ឧ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន បានទទួលស្វាគមន៍គណៈប្រតិភូ CDRI រួមមាន នាយកប្រតិបត្តិ នាយកស្រាវជ្រាវ នាយកមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ចនិង

ពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ និង មន្ត្រីទំនាក់ទំនងខាងក្រៅនិងពិធីការ និងបានចែករំលែកព័ត៌មានពីទិសដៅជាយុទ្ធសាស្ត្រ និងតម្រូវការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវព័ត៌មានបានពីការស្រាវជ្រាវ ជាពិសេសទាក់ទងនឹងបញ្ហា សកលនីយកម្មនិងតំបន់នីយកម្ម ទល់នឹង ឯកតោនិយម (unilateralism) ដែលទើបផុសថ្មីបន្ទាប់ពីមានជំងឺឆ្លងរាលដាល កូវីដ១៩ ក៏ដូចជាបញ្ហាម្ចាស់ការ សេដ្ឋកិច្ចឌីជីថល រដ្ឋាភិបាលអេឡិចត្រូនិក ពាណិជ្ជកម្មអេឡិចត្រូនិក និង តម្រូវការចំណេះដឹងនិងជំនាញ។ ឯកឧត្តមបានស្នើឲ្យ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រសួងហិរញ្ញវត្ថុ និង CDRI បង្កើត MOU មួយស្តីពី កិច្ចសហការក្នុងការស្រាវជ្រាវពីគោលនយោបាយពាក់ព័ន្ធ និងគោលនយោបាយអនុវត្តជាក់ស្តែងសម្រាប់ផ្តល់ព័ត៌មានដល់ការធ្វើសេចក្តីសម្រេចចិត្ត។ ថ្នាក់គ្រប់គ្រងនិងអ្នកស្រាវជ្រាវ CDRI បានថ្លែងអំណរគុណដល់គំនិតស៊ីជម្រៅនេះ និងប្តេជ្ញាចិត្តធ្វើការកាន់តែជិតស្និទ្ធជាមួយ ក្រសួងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ព្រមទាំងក្រសួង និងដៃគូដទៃទៀត។

ឯ.ឧ អូន ព័ន្ធមុនីរ័ត្ន បានបន្ថែមថា សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ដែល CDRI រៀបចំប្រចាំឆ្នាំតាំងពីឆ្នាំ២០០៧ មកជាព្រឹត្តិការណ៍ដ៏សំខាន់ ដែល សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមជាអធិបតីជារៀងរាល់ឆ្នាំ លើកលែងតែមួយឆ្នាំចេញ។ ពេលនោះមានការព្រមព្រៀងគ្នាថា ក្រសួងហិរញ្ញវត្ថុ និង CDRI នឹងទទួលរៀបចំរួមគ្នានូវ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា និងព្រឹត្តិការណ៍ជាតិសំខាន់ៗជាច្រើនទៀត។

ដើម្បីមានមូលដ្ឋាន សម្រាប់សហប្រតិបត្តិការកាន់តែរឹងមាំ និងមានផលិតភាព ឯ.ឧ ឧបនាយករដ្ឋមន្ត្រី និង នាយកប្រតិបត្តិ CDRI បានចុះហត្ថលេខាលើ MOU មួយរវាងក្រសួងហិរញ្ញវត្ថុ និង CDRI នៅថ្ងៃទី១០ កក្កដា។

**ទស្សនកិច្ចនៅអង្គការ អុកស្វាមកម្ពុជា**

នៅថ្ងៃទី១២ មិថុនា លោកស្រី លឹម សូលីន នាយកប្រចាំប្រទេសនៃអង្គការអុកស្វាមកម្ពុជា បានទទួលស្វាគមន៍នៅទីស្នាក់ការរបស់អង្គការនូវ ថ្នាក់ដឹកនាំ និងអ្នកស្រាវជ្រាវរបស់ CDRI ។ អង្គការអុកស្វាម និង CDRI មានប្រវត្តិធ្វើជាដៃគូ និងរួមសហប្រតិបត្តិការជាយូរមកហើយ ក្នុងការកសាងសមត្ថភាពការស្រាវជ្រាវនិងកិច្ចសន្ទនាផ្នែកគោលនយោបាយ និងការជំរុញសហប្រតិបត្តិការរវាងក្រសួងមន្ទីររដ្ឋនឹងសង្គមស៊ីវិល តាំងពីទសវត្សរ៍១៩៩០ មក។

**ការចុះហត្ថលេខាលើ MOU រវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹង CDRI**

នៅថ្ងៃទី១៩ កក្កដា ឯ.ឧ ស្រី វុទ្ធី អគ្គលេខាធិការនៃក្រសួងកសិកម្ម និង នាយកប្រតិបត្តិ CDRI បានចុះហត្ថលេខាលើ MOU មួយ ដើម្បីពង្រឹងសហប្រតិបត្តិការលើការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍កសិកម្ម។ ក្នុង MOU នេះ ក្រសួងកសិកម្ម និង CDRI បានព្រមព្រៀងគ្នា៖

- ធ្វើការកំណត់ប្រធានបទស្រាវជ្រាវ និងអនុវត្តគម្រោងស្រាវជ្រាវដែលមានផលប្រយោជន៍ដល់ទាំងសងខាង ក្នុងរយៈពេល៤ឆ្នាំ
- ជួយសម្រួលការផ្លាស់ប្តូរគ្នានូវ ស្ថិតិ ព័ត៌មាន និងឯកសារ
- រួមសហប្រតិបត្តិការក្នុងការរៀបចំសិក្ខាសាលា និងសន្និសីទ
- ចូលរួមក្នុង ការប្រជុំ សិក្ខាសាលា ការបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា នៅកម្ពុជា និងនៅបរទេស។

ពិធីចុះហត្ថលេខា មានការចូលរួមពីមន្ត្រីជាន់ខ្ពស់ជាច្រើននៃក្រសួងកសិកម្ម ជាពិសេស នាយកដ្ឋានផែនការ និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងពី នាយកស្រាវជ្រាវ និងនាយកមជ្ឈមណ្ឌលស្រាវជ្រាវមួយចំនួននៃ CDRI ។

**ជំនួបជាមួយលោកស្រី Jenny Pearson អ្នកពិគ្រោះយោបល់របស់ធនាគារពិភពលោកផ្នែកមជ្ឈមណ្ឌលសិក្សា**

នៅថ្ងៃទី២ មិថុនា នាយកប្រតិបត្តិ នាយកស្រាវជ្រាវ និងនាយកមជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយកសិកម្ម និងអភិវឌ្ឍន៍ជនបទ បានជួបជាមួយលោកស្រី Jenny Pearson អតីតប្រធានក្រុមប្រឹក្សាភិបាល CDRI ពីឆ្នាំ២០០១-២០០៦។ នាបច្ចុប្បន្ន លោកស្រីកំពុងធ្វើការវាយតម្លៃពីភាពអាចធ្វើបាននូវមជ្ឈមណ្ឌលសិក្សាមួយនៅកម្ពុជា សម្រាប់ស្តង់ដាសង្គមនិងបរិស្ថាន ដែលសំខាន់បំផុតនៅពេលកម្ពុជាកំពុងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធយ៉ាងលឿនបែបនេះ។ សកម្មភាពសិក្សាស្រាវជ្រាវនេះជាចំណែកមួយនៃ ភាពជាដៃគូផ្នែកប្រព័ន្ធសុវត្ថិភាពរវាងធនាគារពិភពលោកនឹងអូស្ត្រាលីដំណាក់កាលទី២ ដែលមានគោលដៅបង្កើនសមត្ថភាពក្នុងមូលដ្ឋាននៅទូទាំងប្រទេសស្តីពី ហានិភ័យផ្នែកសង្គមនិងបរិស្ថាន និងការគ្រប់គ្រងលើផលប៉ះពាល់ ដើម្បីជំរុញឲ្យមានហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព និងការដាក់បញ្ចូលទិដ្ឋភាពផ្សេងៗ នៃបរិស្ថាននិងសង្គម នៅក្នុងវដ្តនៃជីវិតគម្រោង។

**ជំនួបពិគ្រោះយោបល់ជាមួយ ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC)**

នៅថ្ងៃទី៥ មិថុនា នៅ ការិយាល័យសហប្រតិបត្តិការ និងកុងស៊ុលស្វីស លោកស្រី Carin Salerno នាយកសហប្រតិបត្តិការអន្តរជាតិ/ទីប្រឹក្សាផ្នែកអភិវឌ្ឍន៍ លោកស្រី Nadia Ottiger នាយករង និង មន្ត្រីជាន់ខ្ពស់ជាច្រើនទៀតនៃ SDC បានជួបជាមួយនាយកប្រតិបត្តិ នាយកស្រាវជ្រាវ និង នាយកមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវផ្នែកអប់រំនិងនវានុវត្តន៍ នៃវិទ្យាស្ថាន CDRI ដើម្បីពិភាក្សាពីជំនួយគាំទ្រ និងសហប្រតិបត្តិការនាបច្ចុប្បន្ននិងទៅអនាគតខាងផ្នែកTVET សហប្រតិបត្តិការផ្នែកអភិវឌ្ឍន៍របស់សហភាពអឺរ៉ុបនិងចិន និង ផែនការយុទ្ធសាស្ត្រថ្មីរបស់ CDRI ។

**ការប្រជុំធ្វើផែនការសម្រាប់ របាយការណ៍ស្តីពី ស្ថានភាពបរិស្ថានកម្ពុជា**

នៅថ្ងៃទី៩ មិថុនា នាយកប្រតិបត្តិ និង អ្នកហាត់ការម្នាក់ នៃ CDRI បានចូលរួមក្នុងការប្រជុំធ្វើផែនការមួយដែលរៀបចំឡើងដោយ បណ្ឌិត ជួប ប៉ារីស អគ្គនាយក នៃក្រសួងបរិស្ថាន ដើម្បីបានព័ត៌មានសម្រាប់អនុវត្តកិច្ចសន្យាដែល CDRI បានទទួលពីអង្គការស្បៀងអាហារនិងកសិកម្ម (FAO) ដើម្បីដឹកនាំការចងក្រង "ជំពូកស្តីពីទឹក" នៃរបាយការណ៍ទី៤ ស្តីពីស្ថានភាពបរិស្ថាន សម្រាប់កម្ពុជា។

**ការផ្លាស់ប្តូរបទពិសោធន៍ស្រាវជ្រាវជាមួយ វិទ្យាស្ថានជាតិបារាំងសម្រាប់ការអភិវឌ្ឍមានចីរភាព (IRD)**

នៅថ្ងៃទី១០ មិថុនា បណ្ឌិត Jean-Philipe Venot អ្នកស្រាវជ្រាវជាន់ខ្ពស់នៃ IRD បានជួបជាមួយអ្នកស្រាវជ្រាវនៃ

CDRI ដើម្បីផ្លាស់ប្ដូរបទពិសោធន៍ និងពិភាក្សាពី ឱកាសសម្រាប់ទស្សនកិច្ចសិក្សា អាហារូបករណ៍ថ្នាក់បណ្ឌិត និងការស្រាវជ្រាវដោយរួមសហការគ្នា។ លទ្ធផលស្រាវជ្រាវនៅកម្ពុជាថ្មីៗបំផុតរបស់ បណ្ឌិត Venot ស្ដីពីការគ្រប់គ្រងជលផល ការស្រោចស្រព (រួមទាំងតួនាទីរបស់អង្គការសហគមន៍ និងអ្នកផ្គត់ផ្គង់ទឹកឯកជន) បញ្ហាប្រឈមក្នុងការសម្រេចបានផលិតភាព និងផលចំណេញសម្រាប់កសិករ និង ដំណើការទីផ្សារពលកម្មសម្រាប់កសិកម្ម និងវិស័យផ្សេងៗទៀត ក៏មានលើកយកមកចែករំលែក និងពិភាក្សាផងដែរ។

**អាហារថ្ងៃត្រង់ដោយមានពិភាក្សាការងារ រៀបចំឡើងដោយអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជា**

នៅថ្ងៃទី១៦ មិថុនា នាយកប្រតិបត្តិ នាយកស្រាវជ្រាវ និងមន្ត្រីទំនាក់ទំនងខាងក្រៅនិងពិធីការ នៃ CDRI បានចូលរួមអាហារថ្ងៃត្រង់ ដោយមានពិភាក្សាការងារជាមួយ អគ្គរដ្ឋទូតអូស្ត្រាលី Pablo Kang អគ្គរដ្ឋទូតរង Luke Arnold និង អ្នកគ្រប់គ្រងកម្មវិធីផ្នែកអភិបាលកិច្ច សេង សុខា ដើម្បីបង្ហាញសមាសភាពនាយកស្រាវជ្រាវថ្មីរបស់ CDRI ដែលជាអតីតនិស្សិតនៅសាកលវិទ្យាល័យ Monash នៅអូស្ត្រាលី។ នាឱកាសនោះ ក៏មានការផ្លាស់ប្ដូរព័ត៌មានស្ដីពី ទិសដៅយុទ្ធសាស្ត្រ និងស្ថានភាព "ធម្មតាថ្មី" ក្រោយពេលមានជំងឺឆ្លងរាលដាល កូវីដ១៩។

**ជំនួបផ្លាស់ប្ដូរព័ត៌មានជាមួយ បណ្ឌិត Anindya Chatterjee នាយកប្រចាំតំបន់នៃ មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC)**

នៅថ្ងៃទី១៧ មិថុនា នាយកប្រតិបត្តិ នាយកស្រាវជ្រាវ និងនាយកមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ចនិងពាណិជ្ជកម្ម នៃ CDRI បានជួបជាមួយ បណ្ឌិត Anindya Chatterjee នាយកប្រចាំតំបន់នៃ IDRC តាមរយៈ Zoom ដើម្បីពិភាក្សាពីកិច្ចសហការរវាង IDRC នឹង CDRI ដោយទាំងសងខាងត្រៀមខ្លួនសហការគ្នាឲ្យបានកាន់តែសកម្មខាងផ្នែក ការប្រែប្រួលអាកាសធាតុ ការវាយតម្លៃផលប៉ះពាល់នៃ កូវីដ១៩ និងការស្ដារស្ថានភាពឡើងវិញ និងបណ្ដាញក្រុមផ្ដល់គំនិតនៅក្នុងតំបន់។

**ជំនួបផ្លាស់ប្ដូរព័ត៌មាន និងពិភាក្សាការងារជាមួយ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida)**

នៅថ្ងៃទី១៨ មិថុនា លោក Samuel Hurtig ប្រធានផ្នែកសហប្រតិបត្តិការអភិវឌ្ឍន៍ និង សាស្ត្រាចារ្យ Magnus Saemundsson លេខាធិការទី១/អ្នកឯកទេសផ្នែកអប់រំ នៃស្ថានទូតស៊ុយអែតនៅកម្ពុជា បានចូលរួមសន្និសីទតាម Skype ជាមួយនាយកប្រតិបត្តិ និង នាយកស្រាវជ្រាវ CDRI ដើម្បីពិភាក្សាពីភាពជាដៃគូផ្ដល់ធនធាន Sida-CDRI និង សហប្រតិបត្តិការផ្នែកអភិវឌ្ឍន៍ របស់រដ្ឋាភិបាលស៊ុយអែត ជាមួយកម្ពុជា និងយុទ្ធសាស្ត្ររបស់ស៊ុយអែតខាងផ្នែក សុខភាព បរិស្ថាន និងការប្រែប្រួលអាកាសធាតុ តាមរយៈសហប្រតិបត្តិការអភិវឌ្ឍន៍កម្រិតតំបន់របស់ស៊ុយអែតនៅអាស៊ី។

**ជំនួបអនឡាញ ជាមួយលោក ចាន់ វីរៈ នៃធនាគារពិភពលោក**

នៅថ្ងៃទី១៩ មិថុនា នាយកប្រតិបត្តិ CDRI បានជួបអនឡាញជាមួយ លោក ចាន់ វីរៈ អ្នកឯកទេសផ្នែកទឹកនិងអនាម័យ ក្នុងកម្មវិធីរបៀបរបបអនុវត្តសកលផ្នែកទឹក របស់ធនាគារពិភពលោក។ ទាំងសងខាង មានការយកចិត្តទុកដាក់ដូចគ្នាលើការកសាងសមត្ថភាព និងអភិបាលកិច្ចល្អនៅតាមមូលដ្ឋាន។

## ការស្រាវជ្រាវ

### មជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ (CDET)

មជ្ឈមណ្ឌលនេះមាន ៦គម្រោងកំពុងដំណើរការ៖

*ពាណិជ្ជកម្មផ្នែកកសិកម្មរវាងប្រទេសចិន នឹងបណ្ដាប្រទេសនៅតំបន់មេគង្គ-ឡានឆាង។* គម្រោងថ្នាក់តំបន់នេះសំដៅពិនិត្យអង្កេតពី ខ្សែសង្វាក់តម្លៃនៃផលិតផលកសិកម្មជ្រើសរើសពីរដែលនាំចេញពី កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និង វៀតណាម ទៅប្រទេសចិន ដើម្បីស្រាវជ្រាវមើលពីតួអង្គសំខាន់ៗ និងអន្តរកម្មរវាងតួអង្គទាំងនេះ អត្ថប្រយោជន៍ តម្លៃបន្ថែម និង បញ្ហាប្រឈមផ្សេងៗ។ គម្រោងនេះ ក៏មានផែនការបូកសរុបវិធានការមិនមែនពន្ធនានា ដែលបណ្ដាប្រទេសក្នុងតំបន់មេគង្គ-ឡានឆាងបានដាក់អនុវត្ត ប្រៀបធៀបវិធានការពីប្រទេសមួយទៅប្រទេសមួយ និងពិនិត្យមតិយោបល់របស់អ្នកនាំចេញ/សហគ្រាសពី ឥទ្ធិពលនៃវិធានការ ទៅលើការនាំចេញទៅប្រទេសចិន។ លទ្ធផលរកឃើញនឹងយកទៅដោះពុម្ពផ្សាយជា ឯកសារមួយខ្សែនៅចុងឆ្នាំនេះ។ ដោយបានជំនួយថវិកាពី មូលនិធិពិសេសនៃសហប្រតិបត្តិការមេគង្គ-ឡានឆាង គម្រោងនេះកំពុងអនុវត្តទៅមុខដោយរួមសហការជាដៃគូ ជាមួយបណ្ឌិតសភាចិននៃវិទ្យាសាស្ត្រសង្គម (CASS, China) វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្ម (ERIT, Lao) មជ្ឈមណ្ឌលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម (CESD, Myanmar) វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍ថៃ (TDRI, Thailand) និង មជ្ឈមណ្ឌលសម្រាប់ការវិភាគនិងព្យាករណ៍ នៃបណ្ឌិតសភាវៀតណាមនៃវិទ្យាសាស្ត្រសង្គម (CAF, VASS, Vietnam)។

*ការចូលរួមចំណែកនៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ដល់ កំណើន និងការប្រែក្លាយឧស្សាហកម្មសម្រាប់គ្រប់គ្នា៖ ការវិភាគពីកត្តាសំខាន់ៗនៅកម្ពុជា (ជំនាញសម្រាប់ឧស្សហកម្ម)។* គម្រោងនេះកំពុងអនុវត្តជាពីរដំណាក់កាល។ ដំណាក់កាលទី១ ផ្ដោតខាងតម្រូវការក្នុងទីផ្សារពលកម្ម នៃឧស្សាហកម្មផ្នែក កាត់ដេរសម្លៀកបំពាក់ ផ្គុំតម្លើងគ្រឿងអេឡិចត្រូនិកនិងអគ្គិសនី និងកែច្នៃស្បៀងអាហារ។ គម្រោងនេះសំដៅស្វែងយល់ពីចំណងទាក់ទងរវាង ការរីកចម្រើននិងការប្រែក្លាយក្រុមហ៊ុន ជាមួយនឹងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ។ ដំណាក់កាលទី២ គឺ សិក្សាខាងផ្នែកផ្គត់ផ្គង់ ដែលមានជាអាទិ៍ អ្នកផ្ដល់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងអ្នកកសាងគោលនយោបាយ។ គម្រោងនេះទទួលបានមូលនិធិពី កម្មវិធីស្វីសសម្រាប់ការស្រាវជ្រាវពីបញ្ហាសកលក្នុងការអភិវឌ្ឍ (r4d) និងអនុវត្តឡើងដោយរួមសហការជាដៃគូជាមួយសាកលវិទ្យាល័យហ្ស៊ូរិកនៃការអប់រំគ្រូ (PH Zurich, Switzerland) សាកលវិទ្យាល័យហ្ស៊ូរិក (UZH, Switzerland) សាកលវិទ្យាល័យ BRAC (Bangladesh) សាកលវិទ្យាល័យ Mekelle (MU, Ethiopia) សាកលវិទ្យាល័យជាតិនៃប្រទេសឡាវ (NUOL, Laos) សាកលវិទ្យាល័យ Witwatersrand (Wits,

South Africa) និង សាកលវិទ្យាល័យក្រុងហូជីមិញនៃបច្ចេកវិទ្យា និងការអប់រំ (HCMUTE, Vietnam)។

***អង្កេតគ្រួសារក្នុង ៥០ឃុំនៅជុំវិញបឹងទន្លេសាប។*** គម្រោងនេះ អនុវត្តឡើងដោយរួមសហការជាមួយក្រុមស្រាវជ្រាវ នៃសាកលវិទ្យាល័យ Ludwig-Maximilians, Munich ដើម្បីពិនិត្យអង្កេតពីផលប៉ះពាល់នៃការចងចាំមិនភ្លេចពី អំពើហិង្សា និងផលប៉ះពាល់នៃការចងចាំដែលជិតជាមខ្លាំងជាងគេ។ អង្កេតនេះគ្រោងដំណើរការក្នុង ៥០ឃុំនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប និងអនុវត្តលើ ១.៥០០គ្រួសារ ជ្រើសយកដោយចៃដន្យ។ គម្រោងនេះទទួលបានមូលនិធិពី សាកលវិទ្យាល័យ Ludwig-Maximilians នៃក្រុង Munich ប្រទេសអាឡឺម៉ង់។

***ជុំឆ្នាំ២០២០ នៃការប្រមូលទិន្នន័យជាបន្តបន្ទាប់សម្រាប់កសិកម្ម ការអភិវឌ្ឍជនបទ និងការកាត់បន្ថយភាពក្រីក្រ។*** វិទ្យាស្ថាន CDRI បានប្រមូល និងរក្សាទិន្នន័យទទួលបានពីអង្កេតជាបន្តបន្ទាប់លើគ្រួសារនៅជនបទកម្ពុជា។ ការងារបានចាប់ផ្តើមនៅឆ្នាំ១៩៩៦-៩៧ នៅពេល CDRI ធ្វើអង្កេតគោលមួយក្នុងបីភូមិ គឺ ព្រៃកក្អែង បាបោង និង ត្រពាំងប្រិយ។ ការប្រមូលទិន្នន័យនេះបានអនុវត្តជាទៀងទាត់ (មួយជុំក្នុងបីឆ្នាំម្តង) តាមរយៈអង្កេតលើ ១.១៨៣គ្រួសារសំណាក ក្នុង ១១ភូមិនៅជនបទ ដែលតំណាងឲ្យតំបន់ភូមិសាស្ត្របួននៅកម្ពុជា (តំបន់វាលទំនាបទន្លេមេគង្គ តំបន់បឹងទន្លេសាប តំបន់ភ្នំ និង តំបន់ឆ្នេរ)។ គម្រោងនេះទទួលបានមូលនិធិពី ភាពជាដៃគូផ្តល់ធនធានរវាង CDRI-Sida ដែលមានដំណើរការជាយូរឆ្នាំមកហើយ។

***ការវាយតម្លៃពីជំនាញផ្នែកឌីជីថលនៅកម្ពុជា។*** ការសិក្សានេះប្រើវិធីសាស្ត្រមានអ្នកពាក់ព័ន្ធច្រើននាក់ ក្នុងការពិនិត្យអង្កេតពីការផ្គត់ផ្គង់ និងតម្រូវការនូវ ជំនាញផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) និងកម្រិតជាទូទៅនៃចំណេះដឹងផ្នែកឌីជីថលនៅកម្ពុជា។ លទ្ធផលនៃការសិក្សានេះ ចូលរួមចំណែកដល់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីបង្កើនតំណភ្ជាប់ (connectivity) និងកសាងគ្រឹះរឹងមាំ សម្រាប់សេដ្ឋកិច្ចឌីជីថលនៅកម្ពុជា និងត្រៀមរៀបចំសម្រាប់បដិវត្តន៍ឧស្សាហកម្មលើកទី៤។ គម្រោងនេះទទួលបានមូលនិធិពី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលរួមសហការជាមួយ វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (NIPTICT)។

***អ្នកលក់ដូរតាមចិញ្ចើមថ្នល់ ការងាររបស់យុវជន និងការកាត់បន្ថយភាពក្រីក្រ។*** គម្រោងនេះ មានគោលដៅពិនិត្យពីលក្ខណៈសម្បត្តិរបស់អ្នកលក់ដូរតាមចិញ្ចើមថ្នល់ ក្នុង ៩ខណ្ឌនៅក្រុងភ្នំពេញ។ អង្កេតក្នុងគម្រោងនេះ ពិនិត្យពី ការអប់រំ សកម្មភាពសេដ្ឋកិច្ច ចំណូលនិងចំណាយ និង ការពេញចិត្តនឹងជីវិតរស់នៅ។ ដំណាក់កាលទី១ មានការធ្វើផែនទីអ្នកលក់ដូរតាមចិញ្ចើមថ្នល់ ១.១៤១នាក់ នៅ ៥៣កន្លែង និងការជ្រើសយកដោយចៃដន្យនូវ អ្នកលក់ដូរតាមចិញ្ចើមថ្នល់ ៥៥៣នាក់ ឲ្យចូលរួមក្នុងដំណាក់កាលទី២។ លទ្ធផលរកឃើញ នឹងយកទៅបោះពុម្ពផ្សាយជាឯកសារពិភាក្សារបស់ CDRI។ គម្រោងរយៈពេលពីរឆ្នាំនេះ ទទួលបានមូលនិធិពី Sida ហើយគ្រោងចប់រួចរាល់នៅចុងឆ្នាំនេះ។

**មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ (CERI)**

មជ្ឈមណ្ឌលនេះបានចេញផ្សាយ ឯកសារពិភាក្សាពីរ ស្តីពី ១) *លក្ខណៈសំគាល់ និងបញ្ហាផ្សេងៗ នៃការហាត់ការនៅតាមសហគ្រាសឯកជននៅកម្ពុជា* និង ២) *ការស្វែងយល់ពីទស្សនៈ និងវិធីសាស្ត្ររបស់ព្រឹទ្ធបុរសកម្ពុជា លើគណនេយ្យភាពនៃសាកលវិទ្យាល័យ។* ឯកសារទាំងនេះ ចងក្រងលទ្ធផលរកឃើញក្នុងការសិក្សាបែបគុណវិស័យផ្តល់មូលនិធិដោយ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) និងទីភ្នាក់ងារស្វីស សម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការ (SDC) ដោយមានបង្ហាញពី ទិដ្ឋភាពនិងលក្ខណៈសំគាល់សំខាន់ៗនៃការហាត់ការនៅតាមសហគ្រាសឯកជន និង វប្បធម៌និងការអនុវត្តគណនេយ្យភាពនៅតាមសាកលវិទ្យាល័យសាធារណៈ និងឯកជននៅកម្ពុជា។

ឯកសារពិភាក្សាពីរផ្សេងទៀត ស្តីពី ១) ***ការអភិវឌ្ឍ និងអនុវត្តការអប់រំនិងបណ្តុះបណ្តាលផ្អែកលើសមត្ថភាព នៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) នៅកម្ពុជា៖ គំនិតនិងបទពិសោធន៍បានពីអ្នកពាក់ព័ន្ធបីប្រភេទ*** និង ២) ***ការអប់រំនិងបណ្តុះបណ្តាលបែបកូនកាត់៖ លទ្ធភាព និងការអនុវត្ត*** គឺបានឆ្លងកាត់ការពិនិត្យខ្លឹមសារឡើងវិញ និងកែសម្រួលអត្ថបទរួចហើយ។ ជាចំណែកមួយនៃគម្រោងស្រាវជ្រាវពី TVET ដែលឧបត្ថម្ភគាំទ្រដោយ SDC ការសិក្សាទាំងនេះ មានគោលដៅពីរយ៉ាង គឺ ១) ពិនិត្យពីរបៀបរបបអនុវត្ត គោលនយោបាយ និងលទ្ធភាពក្នុងការកែលំអគុណភាព និងភាពជាប់ពាក់ព័ន្ធល្អនៃ TVET ដើម្បីដោះស្រាយតម្រូវការនៃទីផ្សារក្នុងស្រុក និងក្នុងតំបន់ និង ២) ពិនិត្យស្រាវជ្រាវពីអភិបាលកិច្ចក្នុងប្រព័ន្ធ TVET នៅកម្ពុជា។

ដោយសារមានបញ្ហាប្រឈមធំធេងនៃជំងឺឆ្លងរាលដាល កូវីដ-១៩ មជ្ឈមណ្ឌល CERI បានធ្វើការសិក្សាមួយហៅថា ការអនុវត្តដោយបង្ខំនូវបច្ចេកវិទ្យាអប់រំ ក្នុងពេលមានជំងឺឆ្លងរាលដាលកូវីដ-១៩៖ ករណីស្ថាប័នឧត្តមសិក្សានៅក្នុងប្រទេសកំពុងអភិវឌ្ឍមួយ ដើម្បីវាស់វែងភាពត្រៀមខ្លួនផ្នែកបច្ចេកវិទ្យា និងការអនុវត្តបច្ចេកវិទ្យារៀនសូត្រតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងឧត្តមសិក្សានៅកម្ពុជា។ ការសិក្សាតំណាងឲ្យទូទាំងប្រទេសនេះ សព្វថ្ងៃកំពុងធ្វើការប្រមូលទិន្នន័យ ហើយក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលីតាមរយៈមូលនិធិអាស៊ី និង មូលនិធិពិសេសនៃសហប្រតិបត្តិការមេគង្គ-ឡានឆាង បានរួមគ្នាផ្តល់ថវិកាឲ្យ។ ការសិក្សានេះរំពឹងថា នឹងជួយរួមចំណែកដល់ការកសាងគោលនយោបាយ និងការពិភាក្សាលើ ការសម្របខ្លួននឹង កូវីដ-១៩ នៅក្នុង ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

នៅខែមិថុនា មជ្ឈមណ្ឌល CERI បានបញ្ចប់ការស្រាវជ្រាវ **កិច្ចសន្ទនាផ្នែកគោលនយោបាយ និង គម្រោងកសាងសមត្ថភាពលើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** ដែលផ្តល់មូលនិធិដោយ SDC។ គម្រោងនេះបានចូលរួមចំណែកយ៉ាងច្រើនដល់ការកាត់បន្ថយភាពក្រីក្រ និងការកសាងសមត្ថភាពសម្រាប់ការងារសមរម្យក្នុងចំណោមយុវជន និងស្ត្រី នៅកម្ពុជា តាមរយៈការស្រាវជ្រាវម៉ត់ចត់ពាក់ព័ន្ធនឹងគោលនយោបាយ និងការផ្តល់

ព័ត៌មានផ្អែកលើភស្តុតាង ដល់ការកសាងគោលនយោបាយនៅតាមស្ថាប័នសំខាន់ៗ ដូចជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងទេសចរណ៍ជាដើម។ ម្យ៉ាងទៀត គម្រោងនេះក៏បញ្ជាក់គាំទ្រដល់កម្មវិធីអភិវឌ្ឍន៍សមត្ថភាពផ្សេងៗនៅវិទ្យាស្ថាន CDRI និងស្ថាប័នដៃគូនានាដែរ។

## មជ្ឈមណ្ឌលពង្រឹងអភិបាលកិច្ច និងសង្គមសម្រាប់គ្រប់គ្នា (CGIS)

មជ្ឈមណ្ឌលនេះ បានចាប់អនុវត្តការសិក្សាស្រាវជ្រាវថ្មីចំនួនបីគម្រោង។ គម្រោងទី១ **ពាក់ព័ន្ធនឹងកិច្ចគាំពារសង្គម និងផលប៉ះពាល់ផ្នែកយេនឌ័រនៃ កូវីដ-១៩ នៅកម្ពុជា៖ ការសិក្សាជាបន្តបន្ទាប់ ដើម្បី "កសាងឡើងវិញឲ្យបានកាន់តែល្អ" ក្នុងឧស្សាហកម្មផលិតសម្លៀកបំពាក់សកល។** គម្រោងស្រាវជ្រាវនេះមានគោលដៅជារួមបង្កើតការយល់ដឹងថ្មីមួយពី ហានិភ័យ និងភាពធន់នៃកិច្ចគាំពារសង្គម សម្រាប់វិស័យក្នុងប្រព័ន្ធ និងវិស័យក្រៅប្រព័ន្ធនៅកម្ពុជា ដោយផ្តោតជាសំខាន់លើស្ថានភាពកម្មការិនីរោងចក្រកាត់ដេរ និងមានគោលដៅជាក់លាក់ផ្តល់នូវ ភស្តុតាងជាក់ស្តែងសម្រាប់ការសម្រាលឥទ្ធិពលរយៈពេលវែង នៃវិធានការទប់ទល់ជំងឺឆ្លងរាលដាល កូវីដ-១៩ ទៅលើកម្មការិនី។ ក្នុងគោលដៅនេះ ការសិក្សានឹងពិនិត្យតាមដានបទពិសោធន៍ និងយន្តការទប់ទល់របស់កម្មការិនីរោងចក្រកាត់ដេរ ២០០នាក់ ក្នុងរយៈពេលមានជំងឺឆ្លង កូវីដ-១៩ ដោយបច្ចុប្បន្នកំពុងរៀបចំការចុះអង្កេតដល់កន្លែង ហើយការប្រមូលទិន្នន័យនឹងចាប់ផ្តើមនៅខែកញ្ញា។

*យេនឌ័រ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ៖* ស្ត្រីមានទំនួលខុសត្រូវចម្បងលើអាហារូបត្ថម្ភរបស់គ្រួសារ នៅពេលមានគ្រោះធម្មជាតិ (ឧ. ការរាំងស្ងួត ទឹកជំនន់) ប៉ះពាល់ដល់ផលិតកម្មកសិកម្ម។ ក្នុងសកលលោក ចំនួនស្ត្រីដែលត្រូវខ្ចីបុលដើម្បីឆ្លើយតបនឹងហានិភ័យ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបានកើនឡើងយ៉ាងខ្លាំង។ ស្ថានភាពនេះ បានរាំងស្ទះកិច្ចប្រឹងប្រែងដើម្បីសម្រេចបាន តាមចំណុចស្នូលនៃគោលដៅអភិវឌ្ឍន៍មានចីរភាព (SDG) ទី១៣ (សកម្មភាពផ្នែកអាកាសធាតុ) ដែលសំដៅលើកកម្ពស់យន្តការសម្រាប់កែលំអសមត្ថភាពរបស់ ស្ត្រី យុវជន សហគមន៍ក្នុងមូលដ្ឋាន និងសហគមន៍ទន់ខ្សោយ និងញ៉ាំងឲ្យមានការធ្វើផែនការ និងការគ្រប់គ្រងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព។ បញ្ហា ឥណទាន/ការខ្ចីបុល និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ វាជំពាក់ជាក់រឹងជាមួយនឹងបន្ទុកធ្ងន់ធ្ងរនៃការថែទាំ និងការងារក្នុងផ្ទះ ដែលស្ត្រីនិងក្មេងស្រីត្រូវរ៉ាប់រង និងដែលហាក់ដូចជះឥទ្ធិពលផ្ទុយពីគោលដៅនៃ SDG ទី៥ (សមភាពផ្នែកយេនឌ័រ)។ ក្នុងនេះក្រុមស្រាវជ្រាវបានបង្ហើយការរចនារៀបចំអង្កេត និងការបណ្តុះបណ្តាលអ្នកធ្វើអង្កេត បានសម្របសម្រួលជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីបានការអនុញ្ញាតឲ្យធ្វើការស្រាវជ្រាវ និងបានត្រៀមរៀបចំផ្នែកឡូជីស្ទិក។

*ថ្នាក់ដឹកនាំក្នុងមូលដ្ឋាននៅកម្ពុជា៖* គម្រោងនេះ ធ្វើវិភាគឡើងវិញលើការសិក្សាគោលមួយ ដែលបានអនុវត្តនៅឆ្នាំ២០០៧ ក្នុងបីឃុំនៅកម្ពុជា។ ការសិក្សាលើកនេះនឹងប្រើវិធីដូចគ្នា និងធ្វើឡើងក្នុងឃុំដូចគ្នា នឹងការសិក្សាលើកទី១ ហើយមានគោលដៅចងក្រងព័ត៌មានលើ ការផ្លាស់ប្តូរក្នុងក្រុមអ្នកដឹកនាំ ឥរិយាបថរបស់អ្នកភូមិចំពោះថ្នាក់ដឹកនាំ និងយុទ្ធសាស្ត្រដែលអ្នកដឹកនាំប្រើប្រាស់ ដើម្បីលើកកម្ពស់ភាពពេញច្បាប់ និងដោះស្រាយបញ្ហាប្រឈមផ្សេងៗ។ ដោយសារមានជំងឺឆ្លង កូវីដ-១៩ ក្រុមស្រាវជ្រាវត្រូវពន្យាពេលការចុះសិក្សាដល់កន្លែងរហូតដល់ខែកញ្ញា។

*គម្រោងស្រាវជ្រាវឆ្លងស្ថាប័ន៖* បុគ្គលិកមជ្ឈមណ្ឌល CGIS បានផ្តល់ជំនួយគាំទ្រផ្នែកបច្ចេកទេសដល់ បីគម្រោងស្រាវជ្រាវឆ្លងស្ថាប័ន។ ទី១ របៀបរៀបចំផ្នែករដ្ឋបាលនិងឡូជីស្ទិក ការកសាងបញ្ជីសំណួរ ការប្រមូលទិន្នន័យនិងការសិក្សាឯកសារមានស្រាប់ ជាការងារមួយចំនួនត្រូវបានប្រគល់ទៅឲ្យបុគ្គលិក CGIS ដែលជួយគាំទ្រការធ្វើអង្កេតរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) សម្រាប់គម្រោងវិភាគផ្នែក **យេនឌ័រ និងការអភិវឌ្ឍសម្រាប់គ្រប់គ្នា**ដែលផ្តោតលើសហគមន៍នៃអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ អ្នកកែភេទ និង ក្រុមជនពិការ។ ទី២ តារាងផ្ទៀងផ្ទាត់ (checklist) ផ្នែកយេនឌ័រមួយ ត្រូវបានកសាងឡើងសម្រាប់**របាយការណ៍វាយតម្លៃថ្នាក់ជាតិនៅកម្ពុជា** របស់មជ្ឈមណ្ឌលធនធានធម្មជាតិនិងបរិស្ថាន (CNRE)។ ទី៣ បុគ្គលិក CGIS បានចូលរួមចំណែកក្នុងការប្រមូលទិន្នន័យបែបគុណវិស័យ សម្រាប់ការវាយតម្លៃជំនាញផ្នែកឌីជីថល របស់មជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ចនិងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍(CERI)។

*ការបោះពុម្ពផ្សាយ៖* មានអត្ថបទពីរ បានយកទៅបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីបើកទូលាយ (open access journal) ដោយមានការពិនិត្យផ្ទៀងផ្ទាត់ពីអ្នកមានជំនាញដូចគ្នានៅអន្តរជាតិ ឈ្មោះថា នយោបាយ និងអភិបាលកិច្ច (Politics and Governance (2020, Volume 8, Issue 3))។ អត្ថបទទី១ មានចំណងជើងថា ផ្លូវក្លាយជាអ្នកដឹកនាំនៅក្នុង និងនៅក្រៅសង្គមស៊ីវិលកម្ពុជា៖ ស្ថានភាពជាជនមានឋានៈខ្ពស់ និងការឆ្លងឋានៈ ហើយអត្ថបទទី២ គឺ បទបញ្ញត្តិរបស់រដ្ឋ និងការក្លាយជាអ្នកមានឋានៈខ្ពស់៖ ការសិក្សាពីអ្នកមានឋានៈខ្ពស់ក្នុងសង្គមស៊ីវិល នៅឥណ្ឌូនេស៊ី និងកម្ពុជា។

## មជ្ឈមណ្ឌលធនធានធម្មជាតិនិងបរិស្ថាន (CNRE)

មជ្ឈមណ្ឌល CNRE បានធ្វើសកម្មភាពស្រាវជ្រាវសម្រាប់គម្រោងជាច្រើន ក្នុងនេះមានគម្រោងបីទទួលបានមូលនិធិពី Sida និងមានប្រធានបទជាប់ទាក់ទងគ្នា។ សម្រាប់គម្រោង **ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ** គឺមានឯកសារពិភាក្សាមួយ ស្តីពី *ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើកសិកម្ម និងធនធានទឹកនៅកម្ពុជា៖ ការយល់ឃើញរបស់សហគមន៍ក្នុងមូលដ្ឋាន* គឺកំពុងធ្វើការកែសម្រួលអត្ថបទ។ ក្រុមស្រាវជ្រាវដែលអនុវត្តគម្រោង **ការបញ្ជ្រាបយេនឌ័រទៅក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ** នៅក្នុងសហគមន៍ ក៏កំពុងធ្វើផែនការសម្រាប់ការចុះសិក្សាដល់កន្លែង ដែលគ្រោងធ្វើនៅខែសីហា/កញ្ញា។ សម្រាប់គម្រោងទី៣ ស្តីពី **បញ្ហាប្រឈមនៃអេកូទេសចរណ៍ផ្អែកលើសហគមន៍ ក្នុងការអភិរក្សព្រៃឈើ និងកែលំអជីវភាពរស់នៅ** មជ្ឈមណ្ឌលនេះបានកសាងរួចរាល់ នូវក្របខ័ណ្ឌនិងវិធីសាស្ត្រស្រាវជ្រាវ ហើយគ្រោងចុះសិក្សាដល់កន្លែងនៅខែសីហា/កញ្ញា។

មជ្ឈមណ្ឌល CNRE ក៏បានបង្ហើយការប្រមូលទិន្នន័យជុំទី២ សម្រាប់គម្រោងផ្ដល់មូលនិធិដោយ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ស្ដីពី ផលប៉ះពាល់នៃកម្មវិធីពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ដែលពិនិត្យលើ កម្មវិធីពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុចំនួនពីរ អនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ គឺមាន ១) ការអភិវឌ្ឍផ្លូវជនបទមានភាពធន់ល្អ នៅប្រាំកោះក្នុងទន្លេមេគង្គ នៅខេត្តកំពង់ចាម និង ត្បូងឃ្មុំ និង ២) ការកែលំអផ្នែកទឹកនិងអនាម័យ នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ គម្រោងនេះ សព្វថ្ងៃកំពុងស្ថិតក្នុងដំណាក់កាលវិភាគទិន្នន័យ និងសរសេររបាយការណ៍ ហើយលទ្ធផលរកឃើញនឹងយកទៅចែករំលែក និងប្រមូលយកព័ត៌មានត្រឡប់ ក្នុងសិក្ខាសាលាកម្រិតឃុំមួយនៅខែតុលា។

គម្រោង **"ការទូតក្នុងការគ្រប់គ្រងទឹកនៅអាងទន្លេមេគង្គ ដើម្បីឲ្យមានការប្រើប្រាស់អាងទន្លេជារួម និងសម្រេចបាននូវភាពរុងរឿង"** ដែលទទួលបានមូលនិធិពី សហប្រតិបត្តិការមេគង្គ-ឡានឆាង គ្រោងចប់រួចរាល់នៅខែឧសភា។ CDRI ជាអ្នកដឹកនាំការអនុវត្តគម្រោងនេះ ដោយរួមសហការជាដៃគូជាមួយ និងរាយការណ៍ជូន លេខាធិការដ្ឋានជាតិកម្ពុជា សម្រាប់សហប្រតិបត្តិការមេគង្គ-ឡានឆាង នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ដៃគូស្រាវជ្រាវផ្សេងទៀត រួមមាន វិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ,គណៈកម្មការជាតិទន្លេមេគង្គកម្ពុជា, សាកលវិទ្យាល័យបញ្ញាសាស្ត្រ, សាលាវិទ្យាសាស្ត្របរិស្ថាន និងវិស្វកម្មនៃសាកលវិទ្យាល័យភាគខាងត្បូងនៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា (SUSTech, Shenzhen, China), មហាវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ នៃសាកលវិទ្យាល័យ Chulalongkorn (ប្រទេសថៃ), គណៈកម្មការជាតិទន្លេមេគង្គវៀតណាម។ គម្រោងនេះ ក៏មានអង្គការថ្នាក់ជាតិ និងថ្នាក់តំបន់បួនទៀតចូលរួមជាដៃគូដែរ គឺមាន លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ, គណៈកម្មការជាតិទន្លេមេគង្គឡាវ, គណៈកម្មការជាតិទន្លេមេគង្គថៃ, ការិយាល័យជាតិនៃធនធានទឹក (ONWR) នៃឧទ្ទកាល័យនាយករដ្ឋមន្ត្រីថៃ, សម្រាប់ជួយមតិ និងបញ្ជាក់ភាពត្រឹមត្រូវនៃលទ្ធផលស្រាវជ្រាវ។ នាបច្ចុប្បន្ន គម្រោងនេះកំពុងស្ថិតក្នុងដំណាក់កាលពិគ្រោះយោបល់ វិភាគទិន្នន័យ និងចងក្រងលទ្ធផលស្រាវជ្រាវ។

ទាក់ទិននឹងគម្រោង ស្ដីពី **ការធ្វើកសិកម្មតាមកិច្ចសន្យាក្នុងតំបន់មេគង្គ-ឡានឆាង** ដែលទទួលជំនួយគាំទ្រពីមូលនិធិពិសេសនៃសហប្រតិបត្តិការមេគង្គ-ឡានឆាង គឺ ដៃគូស្រាវជ្រាវនៅ ថៃ វៀតណាម កម្ពុជា និង ចិន បានផ្ដល់របាយការណ៍តាមប្រទេសដោយមានអត្ថបទសង្ខេបផ្នែកគោលនយោបាយអមផង។ CDRI ក៏បានដំណើរការសិក្ខាសាលាផ្សព្វផ្សាយអនឡាញថ្នាក់តំបន់មួយនៅថ្ងៃទី២៤ សីហា ដែរ និងកំពុងរៀបចំបោះពុម្ពផ្សាយឯកសារពីរ គឺ ១) របាយការណ៍សំយោគក្នុងតំបន់ និងរបាយការណ៍តាមប្រទេសនីមួយៗ និង ២) អត្ថបទសង្ខេបផ្នែកគោលនយោបាយមួយឈុត ដែលបង្ហាញត្រួសៗ ពីគម្រោងការធ្វើកសិកម្មតាមកិច្ចសន្យានានា ព្រមទាំង ជោគជ័យ បញ្ហាប្រឈម និងបទពិសោធន៍រៀនសូត្របានសម្រាប់តំបន់មេគង្គ-ឡានឆាង។

គម្រោងស្រាវជ្រាវផ្នែកគោលនយោបាយពីរ កំពុងអនុវត្តទៅមុខៗ។ គម្រោងទី១ ***របាយការណ៍ស្ដីពីស្ថានភាពនៃការប្រែប្រួលអាកាសធាតុនៅតំបន់អាស៊ាន (របាយការណ៍របស់ប្រទេសកម្ពុជា)*** ដែលផ្ដល់មូលនិធិដោយ វិទ្យាស្ថានសម្រាប់យុទ្ធសាស្ត្របរិស្ថានសកល (IGES) គ្រោងដំណើរការរហូតដល់ខែមីនា ២០២១ ហើយសព្វថ្ងៃក្រុមស្រាវជ្រាវកំពុងពិគ្រោះយោបល់ ជាមួយក្រសួងបរិស្ថាន ដើម្បីកំណត់វិស័យជាអាទិភាពសម្រាប់យុទ្ធសាស្ត្រសម្រាលផលប៉ះពាល់ និងបន្សាំរបស់កម្ពុជា។ គម្រោងទី២ **របាយការណ៍វាយតម្លៃពីស្ថានភាពសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ** ដែលផ្ដល់មូលនិធិដោយ ស្ត្រីអង្គការសហប្រជាជាតិនៅកម្ពុជា (UN Women Cambodia) ខាងក្រុមស្រាវជ្រាវកំពុងត្រៀមប្រមូលយកព័ត៌មានត្រឡប់ និងធាតុចូលពីសិក្ខាសាលាថ្នាក់ជាតិមួយដែលគ្រោងធ្វើនៅថ្ងៃទី១៥ កក្កដា ដើម្បីកសាងប្លង់របាយការណ៍។ នាបច្ចុប្បន្នក្រុមស្រាវជ្រាវកំពុងពិនិត្យឡើងវិញនូវសេចក្ដីព្រាង និងប្រមូលយកទិន្នន័យពីអ្នកពាក់ព័ន្ធនានា រួមមាន ក្រសួងកិច្ចការនារី ក្រសួងបរិស្ថាន ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតរបស់កម្ពុជា។ គម្រោងនេះគ្រោងចប់រួចរាល់នៅខែធ្នូ ឆ្នាំនេះ។

## មជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយកសិកម្ម និងអភិវឌ្ឍន៍ជនបទ (CARD)

មានគម្រោងប្រាំ កំពុងអនុវត្តទៅមុខៗ។ ការបណ្ដុះបណ្ដាលអ្នកធ្វើអង្កេតសម្រាប់គម្រោងផ្ដល់មូលនិធិដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ស្ដីពី ការវិភាគ**ផ្នែកយេនឌ័រ និងការអភិវឌ្ឍសម្រាប់គ្រប់គ្នា** (GIDA) បានចាប់ដំណើការ ហើយការចុះប្រមូលទិន្នន័យ គ្រោងចាប់អនុវត្តនៅខែសីហា។ ការវិភាគទិន្នន័យ និងការសរសេររបាយការណ៍សម្រាប់គម្រោងផ្ដល់មូលនិធិដោយ Sida ស្ដីពី **ការអនុវត្តស្តង់ដាសុវត្ថិភាពក្នុងសាកវប្បកម្មនៅកម្ពុជា៖ ករណីដំណាំបន្លែ** បានចប់រួចរាល់ ហើយរបាយការណ៍បានផ្ញើជូនអ្នកជួយពិនិត្យ ដើម្បីប្រមូលយោបល់ និងព័ត៌មានត្រឡប់។ អនុស្សរណៈយោគយល់គ្នាមួយបានធ្វើឡើងជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តគម្រោងថ្នាក់តំបន់មួយ ផ្ដល់ថវិកាដោយ មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) ស្ដីពី **បណ្ដាញក្រុមផ្ដល់គំនិតផ្នែកកសិកម្ម និងអភិវឌ្ឍន៍ជនបទ សម្រាប់បណ្ដាប្រទេសនៅមហាអនុតំបន់មេគង្គ** (NARDT)។ មជ្ឈមណ្ឌល CARD ក៏កំពុងបង្ហើយឯកសារគោលគំនិតសម្រាប់គម្រោង **ការដាក់បញ្ចូលកសិករខ្នាតតូចទៅក្នុងបណ្ដាញពាណិជ្ជកម្ម តាមរយៈ ភាពជាដៃគូរវាងផលិតករក្នុងវិស័យសាធារណៈនឹងឯកជន** (PPPP)។ ការសរសេររបាយការណ៍សម្រាប់គម្រោងផ្ដល់មូលនិធិដោយ Sida ស្ដីពី ការវិភាគខ្សែសង្វាក់តម្លៃផ្លែស្វាយ ត្រូវពន្យាពេលយ៉ាងហោចណាស់ដល់ខែកញ្ញា ដោយសារក្រុមស្រាវជ្រាវកំពុងមមាញឹកក្នុងគម្រោង GIDA។ ម្យ៉ាងទៀត ក្រុមស្រាវជ្រាវក៏កំពុងរៀបចំឯកសារគោលគំនិត សម្រាប់គម្រោងផ្ដល់មូលនិធិដោយ Sida ស្ដីពី **ស្ថានភាពបច្ចុប្បន្ន នៃការចងក្រងឯកសារលើឧស្សាហកម្មកែច្នៃកសិផល និងការកំណត់សក្ដានុពលសម្រាប់វិនិយោគទៅអនាគត។**

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

**ជំនួបជាមួយ ឯ.ឧ លុយ ដាវីឌ រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

នៅថ្ងៃទី២៤ មេសា ឯ.ឧ លុយ ដាវីឌ រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង អ្នកតំណាងជាន់ខ្ពស់មួយចំនួន នៃលេខាធិការដ្ឋានជាតិកម្ពុជាសម្រាប់សហប្រតិបត្តិការមេគង្គ-ឡានឆាង បានជួបជាមួយនាយកប្រតិបត្តិ នាយកស្រាវជ្រាវ និង នាយកមជ្ឈមណ្ឌលស្រាវជ្រាវមួយចំនួននៃ CDRI ដើម្បីទទួលព័ត៌មានថ្មីៗបំផុតលើភាពជឿនលឿននៃគម្រោងបួនដែល CDRI កំពុងអនុវត្តជាមួយក្រសួងការបរទេស និងដៃគូផ្សេងៗទៀត។ គម្រោងទាំងនេះពាក់ព័ន្ធនឹង ការទូតទឹកទន្លេមេគង្គ លទ្ធផលនៃខ្សែសង្វាក់តម្លៃផ្នែកកសិកម្ម ការធ្វើកសិកម្មតាមកិច្ចសន្យា និង ការអភិវឌ្ឍឧត្តមសិក្សា។ គណៈប្រតិភូក៏បានទទួលព័ត៌មានពីជំនួយគាំទ្ររបស់ CDRI ដល់កម្មវិធីថ្នាក់តំបន់របស់ក្រសួងការបរទេស លើការគ្រប់គ្រងការអភិវឌ្ឍសមត្ថភាពដែរ។

**ជំនួបជាមួយ លោក គីមយៀត ដារារិទ្ធិ នាយកប្រតិបត្តិនៃវិទ្យាស្ថានសភាកម្ពុជា(PIC)**

នាយកប្រតិបត្តិ នាយកស្រាវជ្រាវ និងមន្ត្រីទំនាក់ទំនងខាងក្រៅនិងពិធីការ នៃ CDRI បានធ្វើទស្សនកិច្ចនៅ វិទ្យាស្ថានសភាកម្ពុជា (PIC) ដើម្បីជួបជាមួយ នាយកប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់មួយចំនួននៃវិទ្យាស្ថាននេះ។ គួរកត់សំគាល់ថា PIC មានបុគ្គលិកជាច្រើននាក់ធ្លាប់ធ្វើការនៅ CDRI ក្នុងនេះ នាយកប្រតិបត្តិ PIC ធ្លាប់ធ្វើជានាយកប្រតិបត្តិរងនៅ CDRI និងធ្វើការយ៉ាងជិតស្និទ្ធជាមួយ លោកស្រី អេវ៉ា មីស្លីវិក ជានាយកស្ថានិកនៃ CDRI ក្នុងរយៈពេលកសាងសន្តិភាពបន្ទាប់ពីមានកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩២ ។ ក្នុងពេលទស្សនកិច្ច មានការពិភាក្សាពីភាពជាដៃគូក្នុងការស្រាវជ្រាវ ឱកាសសហការស្វែងរកធនធានខួបឆ្នាំទី៣០ របស់ CDRI និង ការប្រែក្លាយ PIC ទៅជាមជ្ឈមណ្ឌលសភាសម្រាប់អាស៊ី នៅចុងឆ្នាំ២០២០ ។

**គណៈប្រតិភូ CDRI បានធ្វើទស្សនកិច្ចសំដែងការគួរសមចំពោះ ឯ.ឧ បណ្ឌិត ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

ឯ.ឧ បណ្ឌិត ហង់ជួន ណារ៉ុន បានទទួលស្វាគមន៍គណៈប្រតិភូ CDRI រួមមាន នាយកប្រតិបត្តិ នាយកស្រាវជ្រាវ និងនាយកមជ្ឈមណ្ឌលសម្រាប់ ការស្រាវជ្រាវផ្នែកអប់រំនិងនវានុវត្តន៍ ដែលមកជួបសំដែងការគួរសមនៅក្រសួងអប់រំ។ CDRI វាយតម្លៃខ្ពស់លើទំនាក់ទំនងពិសេសជាមួយ ឯ.ឧ រដ្ឋមន្ត្រី ដែលធ្លាប់ធ្វើជាអ្នកស្រាវជ្រាវនៅ CDRI ពីឆ្នាំ១៩៩០-១៩៩៣ និងជាប្រធានក្រុមប្រឹក្សាភិបាល CDRI ពីឆ្នាំ២០០៦-១២។ ឯ.ឧ រដ្ឋមន្ត្រីបានផ្ដល់មតិពី ផ្នែកសំខាន់ៗជាយុទ្ធសាស្ត្រមួយចំនួនទាក់ទងនឹងការអប់រំ និងគុណភាពធនធានមនុស្ស សម្រាប់ដោះស្រាយតម្រូវការទីផ្សារពលកម្មបច្ចុប្បន្ននិងទើបផុសថ្មី និងត្រៀមកម្លាំងពលកម្មសម្រាប់សេដ្ឋកិច្ចឌីជីថល។ ឯ.ឧ រដ្ឋមន្ត្រីបានលើកទឹកចិត្ត CDRI ឲ្យកសាងសហប្រតិបត្តិការកាន់តែរឹងប៉ឹង និងមានផលិតភាពខ្ពស់ជាមួយក្រសួងអប់រំ និងបានស្វាគមន៍ការធ្វើទស្សនកិច្ចដល់កន្លែងរួមគ្នាទៅកាន់សាលារៀន និងកន្លែងបណ្ដុះបណ្ដាលវិជ្ជាជីវៈមួយចំនួន ក៏ដូចជាលទ្ធភាពធ្វើការស្រាវជ្រាវដោយរួមសហការគ្នាថែមទៀត។

**វិទ្យាស្ថាន CDRI និងក្រុមហ៊ុនអង្គរហ្វ្រីដ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU)**

នៅថ្ងៃទី២៦ មិថុនា លោក ចាន់ សុភក្តិ អគ្គនាយកនៃក្រុមហ៊ុនអង្គរហ្វ្រីដ (AGID) និងនាយកប្រតិបត្តិនៃ CDRI បានចុះហត្ថលេខាលើ MOU មួយ ស្ដីពី សហប្រតិបត្តិការដើម្បីពង្រឹងសមត្ថភាពស្រាវជ្រាវ ភាពធន់ក្នុងខ្សែសង្វាក់តម្លៃផ្នែកកសិកម្ម ការអភិវឌ្ឍកសិពាណិជ្ជកម្ម នវានុវត្តន៍ និង បច្ចេកវិទ្យា។ ឆ្លងតាមអនុស្សរណៈនេះ AGID និង CDRI នឹងសិក្សាស្រាវជ្រាវពិភាក្សាគ្នាពីការបង្កើត និងអនុវត្តគម្រោងសហប្រតិបត្តិការ និងសហការជាក់លាក់មួយចំនួន ដែលមានផលប្រយោជន៍ដល់ទាំងសងខាង។

*តទៅទំព័រ ១៨*


ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា**

ឆ្នាំទី២៤ លេខ២ ខែមិថុនា ឆ្នាំ២០២០

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ សម្រាប់ការពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់នូវការវាយតម្លៃឯករាជ្យពីដំណើរការសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក្ដី។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ពផ្សាយ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ពផ្សាយ ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។



**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
+៨៥៥២៣៨៨១៧០១/៨៨១៩១៦/៨៨៣៦០៣ +៨៥៥២៣៨៨០៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh



9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសម្រួលៈ អ៊ុំ ចាន់ថា
កែសម្រួលផលិតកម្មៈ ម៉េន ច័ន្ទធីតា
សហគ្រាសបោះពុម្ព Go Invent Media (GIM), រូបភាពទំព័រមុខៈ រូបភាព វបសអ


© រក្សាសិទ្ធិ ២០១៩ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ជូនដោយឥតគិតថ្លៃតាមរយៈវេបសាយ www.cdri.org.kh